ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩**
**សវនាការលើកទី៣៨**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង
លោកស្រី សែ កុលវុឌ្ឍី
លោក ឌុច ផារី
លោក ម៉ាត្ធេ គ្រីប៉្ពា *(Mr. Matteo Crippa)*
កញ្ញា អាលីណា ប្រៃអត *(Ms. Alina BRIOT)*
កញ្ញា ណាថាក់ វិចស៊ែល
*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វីលៀម ស្មីត *(Mr. William SMITH)*

លោក តាន់ សេណារ៉ុង

លោក ពេជ្រ សម្បត្តិ

លោក *ហ្សាឆិរី ឡាំប៉ែល (Mr.Zachery LAMPEL)*

លោក ជា ផល្លា

**ជនជាប់ចោទ៖**

លោក កាំង ហ្គេក អ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារ

*(Mrs.Marie-Paule Canizares)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក គឹម ម៉េងឃី

លោក យ៉ុង ផានិត

កញ្ញា ទី ស្រ៊ីនណា

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ម៉ាទីន ហ្សាកកាំង

*(Mrs. Martine Jacquin)*

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## សាក្សី

### លោក នង ចាន់ផល

សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ១៥
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្ដើមពី ....................ទំព័រ ៣២
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ....................ទំព័រ ៣៥
សួរដោយ ចៅក្រម ចៅក្រម ធូ មណី ផ្ដើមពី ....................ទំព័រ ៤២
សួរដោយ ចៅក្រម យ៉ា សុខន ផ្ដើមពី ....................ទំព័រ ៤៤
សួរដោយ លោក តាន់ សេណារ៉ុង ផ្ដើមពី ....................ទំព័រ ៤៥
សួរដោយ លោក វីលៀម ស្មីត ផ្ដើមពី....................ទំព័រ ៤៩
សួរដោយ លោក អាឡាំង វែនណឺ ផ្ដើមពី ....................ទំព័រ ៥២
សួរដោយ លោកស្រី ម៉ាទីន ហ្សាកាំង ផ្ដើមពី....................ទំព័រ ៥៨
សួរដោយ លោក គីម ម៉េងឃី ផ្ដើមពី....................ទំព័រ ៦០
សួរដោយ លោក ហុង គីមសួន ផ្ដើមពី ....................ទំព័រ ៦២
សួរបន្តដោយ ប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ៦៤
សួរបន្តដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្ដើមពី ....................ទំព័រ ៧៣
សួរបន្តដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ....................ទំព័រ ៧៣
សួរដោយ លោកស្រី ម៉ារីប៉ូល កានីហ្សារ ផ្ដើមពី....................ទំព័រ ៧៤

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោកស្រី ម៉ារីប៉ូល កានីហ្សារ | បារាំង |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែរ៍ | បារាំង |
| លោក នង ចាន់ផល | ខ្មែរ |
| លោក វីលៀម ស្មីត | អង់គ្លេស |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| លោកស្រី ស៊ីលឃី ស្ទូតហ្សឺនស្គី | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ-បារាំង |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| ចៅក្រម ធូ មណី | ខ្មែរ |
| កញ្ញា ទី ស្រ៊ុនណា | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | បារាំង |
| ចៅក្រម យ៉ា សុខន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០២:៥៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនការ ពិភាក្សាដេញដោលលើសាក្សីអ្នកដែលរស់រានមានជីវិតពីមន្ទីរសន្តិសុខស-២១ ។

ជាដំបូងនេះក្រឡាបញ្ជីឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលត្រូវអញ្ជើញចូលរួមក្នុងកិច្ចដំណើរការ នីតិវិធីពិភាក្សាដេញដោលនៅថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការ នីតិវិធីសវនាការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ។ ចំណែកឯ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងព្រឹកនេះដែរក៏មានវត្តមានដែរ ។ ខ្ញុំបានត្រួតពិនិត្យអត្តសញ្ញាណរបស់សាក្សីរួចហើយ គឺគាត់មិនមានចំណងលោហិតជាមួយនិងជនជាប់ចោទ ឬក៏ភាគីនៃរដ្ឋប្បវេណីទេ ។ សាក្សីបានធ្វើការស្បថរួចហើយ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការនាំអញ្ជើញសាក្សី នង ចាន់ផល ចូលមកកាន់បន្ទប់សវនាការ ។

**លោក វីលៀម ស្មីត៖**

លោកប្រធានជាទីគោរព! លោកចៅក្រម ហើយនិងមេធាវី ខ្ញុំសូមបញ្ជាក់ដោយសង្ខេបមុននឹងសាក្សីចូលមកដល់ ហើយមុននឹងធ្វើសក្ខីកម្មរបស់សាក្សីរូបនេះនៅព្រឹកនេះ ។

ប្រហែលជា--

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការនាំសាក្សីត្រឡប់ទៅវិញ ។

**លោក វីលៀម ស្មីត៖**

សូមគោរពលោកប្រធាន ខ្ញុំអាចនឹងសម្តែងពេលខ្លីទេ ។ ចំណុចដែលខ្ញុំចង់លើកឡើងនោះទីមួយ

គឺទាក់ទងទៅនឹងកំណត់ហេតុសួរចម្លើយសាក្សីរូបនេះ ។ មុននឹងខ្ញុំចាប់ផ្តើម ខ្ញុំជឿជាក់ថាសាក្សីរូបនេះមិនត្រូវបានទទួលការការពារទេ មែនទេ? ខ្ញុំគិតថា យើងអាចប្រើឈ្មោះរបស់គាត់បាន ។

[០៩:០៦:៣៥]

ទាក់ទងទៅនឹងកំណត់ហេតុសួរចម្លើយរបស់គាត់ ដែលគាត់បានផ្តល់ជូនទៅឲ្យមជ្ឈមណ្ឌលកម្ពុជានៅថ្ងៃទី១៣ ខែមេសា ឆ្នាំនេះ វាទាក់ទងទៅនឹងខ្សែភាពយន្ត ទាក់ទងទៅនឹងដែលវៀតណាមគេធ្វើ ដែលថា ទាក់ទងទៅនឹងសេចក្តីថ្លែងការរបស់គាត់នោះ គឺពីម្សិលមិញនោះ គឺអត្ថបទមួយច្បាប់នៃ--ដែលធ្វើឡើងនៅថ្ងៃទី១៣ ខែមេសា គឺថាខ្ញុំបានចែកជូនទៅឲ្យភាគីទាំងអស់ហ្នឹង ទៅភាគីទាំងអស់ពីល្ងាចម្សិលមិញ គឺថាមិនទាន់បានបកប្រែទៅជាភាសាអង់គ្លេសទេ ។ អ៊ីចឹងយើងបានល្ងាចមិញនេះ គឺយើងបានខាង *ស៊ីអឹមអេស*(CMS) បានបកប្រែទៅជាភាសាអង់គ្លេស ហើយយើងមានជាភាសាអង់គ្លេស ហើយបានចែកជូនដល់ភាគីនៅម៉ោងបួនសាមសិបល្ងាចមិញ ។ ហើយអ៊ីចឹងហើយ ពីឆ្នាំនេះ ខែមេសានោះ គឺគាត់បានផ្តល់ជាសេចក្តីថ្លែងការណ៍ អ៊ីចឹងដំណាក់កាលនោះ គឺយើងមិនអាចនឹងផ្តល់កំណត់ហេតុហ្នឹងទេ មិនបានដាក់ចូលទៅនឹងតាមនីតិវិធីធម្មតារបស់ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ ដូចដែលលោកចៅក្រមយល់ហើយ គឺថាពាក្យសុំរបស់គាត់ហ្នឹងត្រូវបានបដិសេធនៅខែឧសភា ហើយក្រោយមកក៏យើងបានដាក់ចូលថា ជាសាក្សី ។ សហព្រះរាជអាជ្ញាសូមស្នើថា សេចក្តីថ្លែងការណ៍របស់គាត់ ឬកំណត់ហេតុរបស់គាត់ហ្នឹងត្រូវបានផ្តល់ដោយសហព្រះរាជអាជ្ញា ប៉ុន្តែដោយសារថា ការកាត់ផ្តាច់រវាងការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបដិសេធនោះ ហើយការសុំដាក់ជាសាក្សីហ្នឹងចេះតែបន្តទៅទៀត ។ អ៊ីចឹងហើយម្សិលមិញនោះ គឺយើងបានពិនិត្យឃើញថា ក្នុងការរៀបចំសាក្សីនេះសេចក្តីថ្លែងការណ៍ហ្នឹងមិនទាន់បានផ្តល់ទាន់ពេល គឺថាបានផ្តល់ភ្លាមៗ គឺថាយើងប្រើវិធីដែលបានឆាប់បំផុតគឺតាមអ៊ីម៉ែលនោះឯង ។

ដូចបានបញ្ជាក់ពីបញ្ហាហ្នឹង ខ្ញុំម្សិលមិញនេះយើងមិនទាន់មានចេតនាថាដាក់ចូលសំណុំរឿងប៉ុន្តែដើម្បីបំភ្លឺ ព្រឹកនេះយើងបានដាក់ពាក្យសុំ ដើម្បីដាក់ពាក្យសុំមួយ ដើម្បីដាក់ឯកសារនេះចូលក្នុងសំណុំរឿង ទាំងអត្ថបទបកប្រែផង ហើយឲ្យបានទៅដល់ដៃលោកចៅក្រម ។ ដូច្នេះ ខាងសហព្រះរាជអាជ្ញាមិនជាអ្នកបានទទួលមុនពេលសមស្របទេ ដែលនាំឲ្យអង្គជំនុំជម្រះក៏មិនទាន់បានទទួលបាន ភាគីក៏មិនទាន់បានទទួលបាន ។ មូលហេតុហ្នឹងហើយដែលតុលាការមិនទាន់បានដូចគ្នានោះដែរ ។ អ៊ីចឹងហើយយើងមិនទាន់បានដាក់សំណើអ្វីតាមវិធាន៨៧ ដើម្បីដាក់ចូលនៅក្នុងសំណុំរឿងនៅពេលនេះទេ គឺចាត់

ទុកថា ជាសារសំខាន់យើងត្រូវតែគោរពតាមវិធានហ្នឹង ដែលថាត្រូវដើម្បីធ្វើដូច្នោះបាន យើងត្រូវផ្តល់ឲ្យភាគីទាំងអស់ ដើម្បីឲ្យអាចស្ទួរនាំទៅដល់ ចំពោះជំនុំជម្រះបាន ។

[០៩:០៩០:៥៨]

អ៊ីចឹងគឺទាក់ទងទៅនឹងការបញ្ជាក់យថាភាព ឬក៏តម្លៃនៃវីដេអូ VI លេខ ERN V00271181 គឺថាមានប្រាំពីរមីនុត និង E5/V00271182 មានរយៈពេលបួនមីនុត គឺថា យើងចាប់ពីដំបូងដល់ចប់ហ្នឹង គឺថាប្រាំមួយមីនុត ។ អ៊ីចឹងហើយយើងចង់បញ្ជាក់ឲ្យច្បាស់ថា យើងមិនស្នើសុំឲ្យមានសេចក្តីសម្រេចថាវីដេអូទាំងពីរនេះនឹងត្រូវចាត់ទុកថា ជាភស្តុតាងតាមវិធាន៨៧.៣ ។

អ៊ីចឹងហើយលោកចៅក្រមអាចនឹងពិនិត្យមើលខ្សែវីដេអូហ្នឹង ហើយធ្វើសេចក្តីសម្រេច ។ នេះហើយជា យើងបានស្តាប់ការសម្រេចហើយ ការណែនាំយ៉ាងច្បាស់ដល់យើងហើយថា យើងសម្រេចថា តើពិនិត្យមើលតាមថានឹងភស្តុតាង ឬមិនភស្តុតាងតាមវិធាន៨៧.៣ នោះឯង?

ប៉ុន្តែអ្វីដែលយើងស្នើសុំព្រឹកនេះគឺថា វីដេអូ ទាំងពីរនេះគឺត្រូវធ្វើ បញ្ចាំងជូនឲ្យសាក្សី ដើម្បីកំណត់ថា វាមានតម្លៃត្រឹមត្រូវឬអត់ ដូចដែលលោកចៅក្រមជ្រាបហើយ គឺថាមេធាវីបានអះអាងថា វីដេអូនេះ ដែលធ្វើឡើង ហើយគេអះអាងថាជាវីដេអូក្លែងក្លាយ ដែលចង់បង្ហាញថា មិនមែនជាឯកសារល្អ ដូចដែលព្រះរាជអាជ្ញាអះអាងទេ ។ ដូចដែលលោកចៅក្រមជ្រាបហើយ គឺសាក្សីនេះជាអ្នកគុកកុមារ គាត់បានចាកចេញពីស-២១ នៅថ្ងៃដែលកងទ័ពវៀតណាមចូលមកដល់ភ្នំពេញ ហើយយើងជឿជាក់ថា សាក្សីនេះយើងជាសាក្សីមួយដែលស្ថិតនៅក្នុងវីដេអូនោះ ។

អ៊ីចឹងហើយទាក់ទងទៅនឹងសក្ខីកម្ម ដែលបានផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ គាត់អាចជួយឲ្យអង្គជំនុំជម្រះយល់បានពីតម្លៃនៃវីដេអូទាំងពីរនេះ ។ ជាពិសេសនៅពេលដែលយើងនឹងមើលសេចក្តីសង្ខេបដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងពាក្យសុំនោះ ដើមខែកុម្ភៈ ឬមីនា នោះនៅថ្ងៃដែលវៀតណាមបានចូលមកដល់ស-២១ ។ គាត់បានធ្វើកិច្ចប្រឹងប្រែងអស់លទ្ធភាព ដើម្បីស្វែងរកម្តាយរបស់គាត់ គាត់បានទៅគ្រប់អគារ គ្រប់បន្ទប់ ហើយគាត់បានឃើញទិដ្ឋភាពមួយចំនួន ដែលទាក់ទងទៅថា មានអ្នកទោសស្លាប់នៅក្នុងបន្ទប់នោះ ។ នេះហើយអ្វីដែលជាវីដេអូបង្ហាញទៅវាស្របទៅហ្នឹងសម្តីរបស់គាត់ ។

អ៊ីចឹងសាក្សីនេះ គឺជាសាក្សីពិសេសណាស់ ក្នុងការផ្តល់បញ្ជាក់តម្លៃពីវីដេអូនោះ ។ គាត់ជាសាក្សីល្អបំផុត ដែលថាគាត់អាចកំណត់ថា តើគាត់បានមានរូបនៅក្នុងវីដេអូហ្នឹងដែរឬអត់?

យើងខ្ញុំស្នើថា ថ្ងៃនេះជាឱកាសដ៏ពិសេសបំផុត ដើម្បីឲ្យសាក្សីនេះបញ្ជាក់ពីតម្លៃនៃវីដេអូនេះ ដើម្បីឲ្យអង្គជំនុំជម្រះអាចធ្វើសេចក្តីបាន ដើម្បីកុំឲ្យបាត់បង់ឱកាសនូវលទ្ធភាពមួយ ហើយពិសេសបំផុតគាត់ជាសាក្សីដ៏ល្អបំផុត ដើម្បីបង្ហាញដែលបញ្ជាក់នូវភស្តុតាង ថាតើថាវីដេអូហ្នឹងមានតម្លៃពិតប្រាកដត្រឹមត្រូវដែរឬអត់? នេះជាសំណើរបស់សហព្រះរាជអាជ្ញា ។

ខ្ញុំសូមសំណើដោយសង្ខេបរបស់ខ្ញុំគឺប៉ុណ្ណឹង និងការពន្យល់ ។ សូមអរគុណ ។

[០៩:១៣:៥៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំចង់បន្ថែមសុំការបំភ្លឺមួយចំនួនទាក់ទងទៅនឹងការលើកឡើង និងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ។

ចំណុចទីមួយ ទាក់ទងទៅនឹងឯកសារ ខ្ញុំហាក់ដូចជាមិនដឹងទេ ថាតើស្នើសុំឲ្យបញ្ចូលឯកសារហ្នឹងនៅក្នុងសំណុំរឿង ឬក៏បង្ហាញនៅក្នុងអង្គសវនាការ? ចំណុចពីរនេះវាខុសគ្នា ប៉ុន្តែខ្ញុំជឿថា គោលបំណងនោះ គឺចង់ប្រើឯកសារនេះនៅគ្រប់ករណីទាំងអស់ ។ ដូច្នេះខ្ញុំយល់ឃើញថា សហព្រះរាជអាជ្ញាស្នើសុំឲ្យឯកសារនេះបង្កើតនៅក្នុងអង្គសវនាការ ហើយបញ្ចូលទៅក្នុងសំណុំរឿងផងដែរ ។ ថាតើនេះជាគោលបំណងរបស់សហព្រះរាជអាជ្ញាឬយ៉ាងម៉េច? ហើយថាតើស្នើសុំឲ្យបង្កើតឯកសារនេះនៅពេលអង្គសវនាការមិនបញ្ចូលទៅក្នុងសំណុំរឿង ឬក៏យ៉ាងម៉េច?

**លោក វីលៀម ស្មីត៖**

យើងមានការរីករាយដែលថា ឯកសារនេះបញ្ចូលនៅក្នុងនីតិវិធីរបស់យើង ហើយចែកជូនទៅភាគីផ្សេងៗ ហើយគឺសំណើរបស់ខ្ញុំសូមដាក់ឯកសារនេះ នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់យើង ។

[០៩:១៥:១១]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំក៏យល់ត្រឹមត្រូវផងដែរនូវអ្វីដែលបានលើកឡើងព្រឹកមិញនេះ ។ ពាក្យសុំនេះ គឺផ្អែកទៅលើវិធាន៨៧.៤ នៅក្នុងវិធានផ្ទៃក្នុង តើត្រឹមត្រូវដែរឬទេ?

**លោក វីលៀម ស្មីត៖**

ពាក្យសុំ គឺមានជាលាយលក្ខណ៍អក្សរ គឺខ្ញុំសូមដាក់ចម្លើយនេះនៅក្នុងសំណុំរឿង ។ ហើយខ្ញុំរីករាយថា គួរតែយកឯកសារនេះមកធ្វើជាភស្តុតាងតាមវិធាន ៨៧.៣ ។ ប៉ុន្តែចំណុចសំខាន់ សម្រាប់

សហព្រះរាជអាជ្ញាហ្នឹង គឺយើងគួរតែផ្តល់ឯកសារនេះទៅដល់ភាគី ដើម្បីជួយផ្តល់ជាព័ត៌មាននៅពេលដែលសួរសំណួរ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះប្រសិនបើខ្ញុំយល់នោះ គឺយើងឃើញមានសំណើពីរ ។ សំណើទីមួយ គឺសំណើក្នុងការសុំដាក់បញ្ចូលឯកសារនេះទៅក្នុងសំណុំរឿង ។ ហើយសំណើទីពីរ គឺស្នើសុំឲ្យផលិតឯកសារ និងបង្កើតឯកសារនេះដាក់ជូននៅក្នុងកិច្ចនីតិវិធីដើម្បីបង្ហាញជូនអង្គសវនាការទាំងមូល ។ តើត្រឹមត្រូវដែរឬទេ?

**លោក វីលៀម ស្មីត៖**

គឺត្រឹមត្រូវហើយ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ប្រសិនបើខ្ញុំយល់ត្រឹមត្រូវនោះផងដែរ គឺយើងនៅពេលនេះនិយាយអំពីកិច្ចសម្ភាសន៍ដែលបានធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាលមួយ គឺមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រឹមត្រូវដែរឬទេ? ដូច្នេះខ្ញុំសូមឲ្យលោកបញ្ជាក់ថ្ងៃពិតប្រាកដ ថាតើកិច្ចសម្ភាសន៍នោះធ្វើឡើងនៅពេលណា?

**លោក វីលៀម ស្មីត៖**

កិច្ចសម្ភាសន៍នោះ គឺធ្វើឡើងនៅថ្ងៃ១៣ កុម្ភៈ ឆ្នាំ២០០៩ គឺឆ្នាំនេះ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះ តាំងពីថ្ងៃ១៣ ខែកុម្ភៈ ឆ្នាំ២០០៩ ហើយខ្ញុំជឿថា កិច្ចសម្ភាសន៍នេះគួរតែវាមានហើយ ឯកសារនេះគួរតែមានហើយចាប់ពីថ្ងៃទី១៣ កុម្ភៈ ឆ្នាំ២០០៩ ហើយខ្ញុំជឿថា ឯកសារនេះក៏ធ្វើឡើង-- ការសម្ភាសន៍នេះធ្វើឡើងជាភាសាខ្មែរ ។ ដូច្នេះ សំណួរបន្ទាប់របស់ខ្ញុំនោះ គឺថាតើឯកសារខ្មែរគួរតែបានដាក់បញ្ចូលទៅក្នុងសំណុំរឿងបានហើយឬនៅ? ឬក៏វានៅក្នុងសំណុំរឿងអត់ មានឯកសារនេះតែម្តង ទាំងភាសាខ្មែរ ទាំងភាសាអង់គ្លេស?

[០៩:១៧:៥៩]

**លោក វីលៀម ស្មីត៖**

ឯកសារខ្មែរបានដាក់នៅក្នុងសំណុំរឿងព្រឹកមិញនេះ មុនពេលដែលយើងចូលមកអង្គសវនាការ ហើយមុនពេលហ្នឹង គឺអត់មានឯកសារហ្នឹងដាក់ចូលទៅក្នុង-- ឯកសារហ្នឹងជាភាសាខ្មែរ ដាក់ចូលជាសំណុំរឿងនោះទេ ដោយសារតែនៅពេលនោះ គឺវាមិនសមស្របក្នុងការដាក់ចូលទៅក្នុងសំណុំរឿង ។

ហើយដោយសារតែវាជាការដាក់ដោយដើមបណ្ដឹងរដ្ឋប្បវេណី ។ នៅពេលដែលយើងរកឃើញ ឬក៏សម្រេចពាក្យសុំរបស់អង្គសវនាការពីភាគីនោះ គឺអ្នកដែលក្លាយទៅជាសាក្សីនោះ ភាពដែលពាក់ព័ន្ធគ្នាទៅនឹងសក្ខីកម្ម គឺមិនបានលើកឡើងនៅពេលនោះ ។ ហើយការលើកឡើងពីម្សិលមិញ ចំណុចសំខាន់សម្រាប់សហព្រះរាជអាជ្ញានោះ គឺថា យើងគួរតែផ្ដល់ឯកសារនេះទៅដល់ភាគី និងអង្គសវនាការដើម្បីធ្វើយ៉ាង ណាឱ្យពួកគេមានព័ត៌មានគ្រប់សម្រាប់ខ្លួន ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ចំណុចតែមួយ ដែលខ្ញុំចង់សុំឱ្យបំភ្លឺនៅពេលនេះគឺ ហេតុអ្វីបានជាឯកសារនេះមិនបានបញ្ចូលទៅក្នុងសំណុំរឿង១មកទល់ពេលនេះ? ហើយហេតុអ្វីទើបតែមានសំណើនៅពេលនេះ? ហើយខ្ញុំជឿថាលោកបានពន្យល់ហេតុផលជូនយើងខ្ញុំហើយ ដោយយើងដឹងថា មានការដាក់សំណើពីដើមបណ្ដឹងរដ្ឋ-ប្បវេណី និងសំណើនោះ គឺវាហាក់ដូចជាមិនបានទទួលយកដោយសារតែការដាក់យឺត ហើយក៏ឃើញមានសំណើពីក្រុមដើមបណ្ដឹងរដ្ឋប្បវេណីដែលថា បុគ្គលនេះគួរតែដេញដោលជាសាក្សី ហើយឯកសារខ្មែរនៃកិច្ចសម្ភាសន៍នេះ គឺមិនបានដាក់ចូលនៅក្នុងសំណុំរឿងទេ តើយើងយល់ដូច្នេះដែរឬទេ?

ខ្ញុំគិតថាមីក្រូហ្វូនរបស់លោកអត់បើកទេ ដូច្នេះយើងអត់ឮទេ ។

**លោក វីលៀម ស្មីត៖**

គឺអ្វីដែលលោកចៅក្រមលើក ឡើង គឺត្រឹមត្រូវ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដូច្នេះ គឺវាច្បាស់ណាស់ដែលថា យើងមានបញ្ហាកើតឡើងទាក់ទងទៅនឹងភាពយឺតយ៉ាវនៃការដាក់ឯកសារនេះ ។ ដូច្នេះហើយ មេធាវីការពារក្ដី គួរតែលើកសេចក្ដីសង្កេតរបស់ខ្លួន ទាក់ទងទៅនឹងរូបភាពខ្សែវីដេអូ ខ្ញុំហាក់ដូចជាមិនយល់សំណើរបស់លោកឱ្យបានជាក់លាក់នោះទេ ។ លោកបានស្នើយើងខ្ញុំឱ្យធ្វើការសម្រេចឬយ៉ាងម៉េច? ហើយសំណួររបស់ខ្ញុំនោះ គឺយើង ថាតើយើងគួរតែទទួលយកសំណើនោះនៅក្នុងកិច្ចនីតិវិធីរបស់យើងឬយ៉ាងម៉េច? យើងទទួលយកវាថា ជាឯកសារថ្មីហើយ ប៉ុន្តែយើងគួរតែដឹងថា តើយើងគួរតែដាក់ក្នុងកិច្ចនីតិវិធីរបស់យើងនោះទេ? ហើយលោកស្នើសុំថា ខ្សែវីដេអូនោះគួរតែបង្ហាញ ហើយដើម្បីឱ្យសាក្សីបញ្ជាក់ថា វាមានភាពត្រឹមត្រូវឬមានតម្លៃដែរឬទេ? ហើយលោក ចង់ឱ្យបង្ហាញពេលនៅពេលយើងធ្វើសវនាការ ឬក៏យើងធ្វើការបញ្ចាំងនៅក្រៅសវនាការរបស់យើង ខ្ញុំហាក់ដូចជាអត់យល់ច្បាស់សោះទៅលើចំណុចនេះ ។

[០៩:២១:៥០]

**លោក វីលៀម ស្មីត៖**

ខ្ញុំស្នើសុំថា ឲ្យបញ្ចាំងខ្សែរូបភាពវីដេអូនេះក្នុងពេលដំណើរការក្តី ដើម្បីឲ្យសាក្សីនេះ ជាសាក្សីដែលល្អផ្តល់នូវយោបល់របស់គាត់បញ្ជាក់អំពីភាពត្រឹមត្រូវជូនអង្គសវនាការ ។ ហើយថាតើយើងជឿជាក់ទៅលើចំណុចនេះដែរឬទេ ដូចដែលបានជំទាស់ដោយមេធាវីការពារក្តី ហើយចំពោះការដែលទទួលយក ឬក៏មិនទទួលយកទៅលើយោបល់របស់សាក្សី ឬអ្នកផ្សេងនោះ ហើយខ្ញុំជឿថា វាជាជំហរក្នុងការសម្រេចរបស់លោក លោកស្រីចៅក្រម ថាតើវាខ្សែរូបភាពនេះ គឺវាមានភាពត្រឹមត្រូវដែរឬទេ?

ខ្ញុំស្នើនៅទីនេះ យើងខ្ញុំគ្រាន់តែស្នើថាតើខ្សែភាពយន្តនេះគួរតែយកមកផ្អែកជាសាលក្រមដែរឬទេ? តាមវិធាន ៨៧.៣ ។ ដូច្នេះហើយទើបខ្ញុំស្នើសុំនៅពេលនេះ ដែលថា លោក លោកស្រីចៅក្រម យើងគួរតែគិតថា វាគួរជា យើងផ្តល់ឲ្យមានការផ្តល់ជាយោបល់ល្អណាមួយ ដើម្បីផ្តល់តម្លៃទៅលើខ្សែវីដេអូ ។ ដូច្នេះហើយវាជាឱកាសល្អមួយ។ ហើយខ្សែវីដេអូនេះ វាទាក់ទងទៅនឹងបញ្ហាផ្លូវច្បាប់ដែលថា យើងគួរផ្អែកតាមវិធាន ៨៧.៣ ហើយថាតើវាមានភាពសំខាន់យ៉ាងម៉េចក្នុងការស្នើសុំយោបល់របស់សាក្សីមួយនេះ ដែលគាត់មានរូបភាពនៅក្នុងខ្សែវីដេអូនេះ ហើយឲ្យគាត់បញ្ជាក់ថាតើ វាយ៉ាងម៉េចដែរ ហើយវាដូចនូវអ្វីដែលគេថត និងដូចនឹងអ្វីដែលខ្សែរូបភាព នៅពេលដែលវៀតណាមគាត់ចូលមកក្នុងទឹកដីកម្ពុជាដែរឬទេ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកស្មីត ចំពោះការបំភ្លឺរបស់លោក ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមានចំណុចមួយទៀតទាក់ទងទៅនឹងខ្សែវីដេអូ ។ លោកបានស្នើឡើងថា សាក្សីនេះអាចជាសាក្សីដែលអាចបញ្ជាក់អំពីភាពត្រឹមត្រូវនៃខ្សែរូបភាព ហើយលោកបានស្នើថា ឲ្យបញ្ចាំងខ្សែរូបភាពវីដេអូនេះជាសាធារណៈ ហើយថាតើវាមានការលំបាកដែរឬទេនៅពេលដែលយើងបង្ហាញជាសាធារណៈ ដោយសារតែវាមានភាពមិនប្រាកដប្រជាអំពីយថាភាព ឬក៏ភាពត្រឹមត្រូវនៃខ្សែវីដេអូនុ៎ងនោះ?

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកចៅក្រម ។ ខ្ញុំ គឺឲ្យលោក លោកស្រីចៅក្រមសម្រេចថា គួរបញ្ចាំងជា

សាធារណៈ ឬក៏អសាធារណៈ ហើយទាក់ទងទៅនឹងបញ្ហាផ្លូវច្បាប់ ចំណុចនេះ គឺជាដំណើរការសម្រេចរបស់អង្គសវនាការទាក់ទងទៅនឹងភាពតម្លាភាព ហើយថាតើយើងគួរតែធ្វើជាសាធារណៈ ឬយ៉ាងណា? ប៉ុន្តែយ៉ាងណាក៏ដោយ គឺខ្ញុំទុកឲ្យលោក លោកស្រីចៅក្រម ថាយើងគួរតែធ្វើឡើងជាសាធារណៈ ឬក៏អសាធារណៈ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមគោរពលោកប្រធាន អស់លោក លោកស្រីចៅក្រម ហើយយើងបានចង្អុលបង្ហាញថា យើងជាភាគីដែលបានស្នើសុំឲ្យធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ។ ប៉ុន្តែក្រោយមក លោកស្មីតបានបញ្ជាក់ថាគាត់បញ្ជាក់ត្រឹមត្រូវហើយ ។ ខ្ញុំចង់ជម្រាបថា ចង់លើកឡើងពីគោលជំហរមួយ យើងមិនទាន់ច្បាស់លាស់នៅក្នុងសេចក្តីថ្លែងការណ៍ណ៍របស់គាត់នោះ ដើម្បីកត់ត្រាឲ្យបានច្បាស់លាស់នោះ តាមពិតនៅក្នុងថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៩ ដែលសាក្សីនេះបានទៅដល់អង្គភាពជនរងគ្រោះ ហើយប៉ុនប៉ងនឹងដាក់ពាក្យសុំ ប៉ុន្តែគាត់បានមកដាក់នោះយឺតពេលពេក ។ អ៊ីចឹងនៅថ្ងៃ១៦ ខែកុម្ភៈ ឆ្នាំ២០០៩ គឺថាមុនពេលសវនាការបឋម គាត់បានចុះហត្ថលេខាលើលិខិតប្រទានសិទ្ធិ គឺថាឲ្យសិទ្ធិទៅឲ្យលោក ការីមខាន ហើយនិងខ្ញុំ ហើយនិងគឺជាពេល ដែលតាមពិតយើងបានដាក់ពាក្យសុំ យើងស្នើសុំទៅលោកប្រធានដើម្បីពន្យាររយៈពេលពីរថ្ងៃសម្រាប់គាត់ ដើម្បីឲ្យសាក្សីហ្នឹងក្លាយទៅជាដើមបណ្តឹងរដ្ឋប្បវេណី ។

ហើយលោក ស្មីត បានបញ្ជាក់ត្រឹមត្រូវហើយ ហើយគឺថាត្រូវបានច្រានចោលពាក្យសុំនោះ ។ អ៊ីចឹងដោយហេតុថា សវនាការបឋមហ្នឹង គឺនៅថ្ងៃទី១៧ ហើយគឺថា យើងមានពេលរវល់ខ្លាំងណាស់ គឺយើងមានកង្វះទំនាក់ទំនងខ្លះ ជាមួយក្រុមយើង ហើយនិង *ឌីស៊ីខេម* (DC-Cam) ហើយយើងមិនដឹងថាកំណត់ហេតុហ្នឹងធ្វើឡើងនៅថ្ងៃ១៣ ខែ កុម្ភៈ ឆ្នាំ២០០៩ ខ្ញុំមិនបានដឹងទេ ។ ខ្ញុំទើបតែដឹងពីម្សិលមិញថា មានសេចក្តីថ្លែងការណ៍ហ្នឹង កំណត់ហេតុហ្នឹង ខ្ញុំចង់ជម្រាបឲ្យច្បាស់ថា យើងដូចគ្នានឹងភាគីផ្សេងទៀតដែរ ខ្ញុំបានដឹងថាមានកំណត់ហេតុហ្នឹងពីយប់មិញទេ ។ អ៊ីចឹងដើម្បីឲ្យកត់ត្រាបានច្បាស់ ហើយដូចមេធាវី ប្រធានក្រុមរបស់ខ្ញុំ ខារីមខាន ហ្នឹង គឺថានៅពេលដែលអង្គជំនុំជម្រះសម្រេចនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ ថាទទួលស្គាល់ថា ជាសាក្សី-- ឃើញថា មិនសមសម្រួបដើម្បីឲ្យយើងនិយាយជាមួយ នង ចាន់ផល ទេ ពីព្រោះគាត់មិន មែនដើម្បីរដ្ឋប្បវេណី គាត់ជាសាក្សី ។ អ៊ីចឹងហើយយើងមិន

បាននិយាយជាមួយគាត់នោះទេ នង ចាន់ផល ។ ប៉ុន្តែ យើងបានសម្រេចអ៊ីចឹងដោយហេតុថា សាក្សីរបស់តុលាការ មិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីទេ យើងមិនអាចនិយាយជាមួយគាត់ទេ ។ អ៊ីចឹងសូមឲ្យកត់ត្រាឲ្យបានត្រឹមត្រូវក្នុងកម្រិតនេះ ។ អរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តី ។

**លោក ការ សាវុត្ថ៖**

សូមអរគុណ ។ សូមគោរពលោកប្រធាន ចំពោះកិច្ចសម្ភាសន៍របស់លោក នង ចាន់ផល ដែលសហព្រះរាជអាជ្ញាមានបំណងនឹងដាក់នៅពេលនេះ មេធាវីការពារក្តីយល់ថា មិនអាចដាក់នៅពេលនេះបាន ហើយយកមកជជែកដេញដោលគ្នានៅពេលនេះបានភ្លាមទេ ។ ហេតុអ្វី? ពីព្រោះថា សហព្រះរាជអាជ្ញាបានទទួលកិច្ចសម្ភាសន៍នេះពីមជ្ឈមណ្ឌលឯកសារ *ឌីស៊ីខេម* បើគិតទៅចង់កន្លះឆ្នាំហើយ ។ ចំណែកមេធាវីការពារ ទើបតែទទួលបានល្ងាចមិញនេះនៅម៉ោងបួន ដប់ប៉ុន្មាននាទីជាងបួន ហើយខ្ញុំអត់នៅទៀត ខ្ញុំទៅបាត់ ចេញទៅបាត់ហើយ ។ ទើបតែព្រឹកមិញនេះ បានទទួលបាន ។ អ៊ីចឹងយើងខ្ញុំជាភាគីម្ខាងនេះ គឺអត់បានមើលឯកសារហ្នឹងទេ អត់ទាន់បានមើលទេ អ៊ីចឹងដើម្បីពិភាក្សាដេញដោលគ្នារកហេតុផលខុសត្រូវ ល្អ អាក្រក់ ដាក់បាន ទទួលយកបាន ឬមិនបានអាស្រ័យទៅលើការពិចារណាឲ្យបានល្អិតល្អន់នៅលើបទសម្ភាសន៍នេះ ។ អ៊ីចឹងបើមេធាវី មិនទាន់បានមើលផង ហើយយកមកដាក់ អ៊ីចឹងវាចាញ់ប្រៀបខាងព្រះរាជអាជ្ញាជាងកន្លះឆ្នាំ ជាប់កន្លះឆ្នាំមុនទៅហើយ ។

ដូច្នេះ ខ្ញុំមិនអាចទទួលយកបានទេ សុំឲ្យដាក់នៅពេលក្រោយ ពេលណាដែលមេធាវីបានមើលចប់ល្អិតល្អន់ នេះជាចំណុចទីមួយ ។ ឯចំណុចទីពីរ ខ្សែវីដេអូពីរឈុត ឃើញថា សហព្រះរាជអាជ្ញាខ្ញុំតាមសង្កេតរបស់ខ្ញុំ តាមការកត់សម្គាល់របស់ខ្ញុំ សហព្រះរាជអាជ្ញាបានស្នើរាល់ថ្ងៃ ។ តែព្រឹកឡើងស្នើសុំដាក់បញ្ចូលខ្សែវីដេអូហ្នឹងហើយ ។ ហើយលោកប្រធានតុលាការតែងតែប្រាប់ទៅសហព្រះរាជអាជ្ញាថា នឹងកំណត់ថ្ងៃណាមួយ នឹងធ្វើការដេញដោលគ្នា ដោយលោកប្រធាននឹងកំណត់និងជូនព័ត៌មានថ្ងៃខែជាមុន ។ ហើយឥឡូវលោកប្រធានមិនទាន់បានជូនព័ត៌មានថា ដេញដោលថ្ងៃណា អីថ្ងៃណាផង ហើយសូមមកសម្រេចថ្ងៃហ្នឹង ។ ភាគីការពារក្តី គឺទទួលយកមិនបាន ពីព្រោះមិនទាន់បានត្រៀមអ្វីទាំងអស់ ។ ខ្ញុំមានមតិតែប៉ុណ្ណោះ ជាការកត់សម្គាល់ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី ។

**លោកស្រី ម៉ារីប៉ូល ការីហ្សរ៖**

សូមអរគុណលោកប្រធាន! ខ្ញុំគ្រាន់តែបញ្ជាក់ចំណុចមួយតូច ទាក់ទងទៅនឹងសហសេវិកមេធាវីរបស់ខ្ញុំ គាត់បានបញ្ជាក់នោះ ។ យើងមិនបានដឹងថា តើលក្ខខណ្ឌណាមួយ ដែលថាឯកសារដែលត្រូវយោង ដែលយោងដោយសហព្រះរាជអាជ្ញានៅក្នុងពាក្យសុំរបស់គាត់នោះ ។ អ៊ីចឹងគឺថា យើងពិនិត្យឃើញថា ចម្លើយរបស់សាក្សីនេះ កំណត់ហេតុនោះ គឺត្រូវបានធ្វើឡើងដោយអ្នកដែលធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាល មិនមែនដោយស្ថាប័នណាមួយរបស់ អ.វ.ត.ក ទេ ។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមគោរពលោកប្រធានលោក លោកស្រីចៅក្រម ។ ខ្ញុំមានយោបល់ទាក់ទងនឹងចំណុចនេះគឺថា ឯកសារវីដេអូនេះ ត្រូវបានចែករំលែកជាសាធារណៈហើយ ។ អ៊ីចឹងហើយ ឯកសារនេះគប្បីតែបង្ហាញជូនសាក្សី ដើម្បីឱ្យសាក្សីរូបនេះអាចមើលវីដេអូនេះបាន ហើយឃើញ អាចនឹងគាត់បញ្ជាក់ពីមតិយោបល់របស់គាត់ថាតើអាចទទួលយកបានដែរឬទេចំណុចហ្នឹង? ថាតើអាចទាក់ទងទៅនឹងភាពមិនប្រាកដក្នុងចិត្ត ។ អ៊ីចឹង គឺថាចំណុចសំខាន់ណាស់ ដើម្បីឱ្យសាក្សី ដែលជា ដូចជាអ្នកសម្តែងមួយ អ្នកមានរូបក្នុងហ្នឹង ឱ្យគាត់សម្តែងមតិរបស់គាត់អំពីខ្សែវីដេអូនេះ ជាចំណុចសំខាន់ណាស់ ដើម្បីបំភ្លឺដល់អង្គសវនាការហ្នឹង ។ ហើយពិនិត្យនៅក្នុងបទសម្ភាសន៍ ហើយយើងក៏មានយល់ថា មានការយឺតយ៉ាវ ហើយក៏មានបញ្ហាមួយចំនួនដែលយើងអាចនឹងបំពេញបន្ថែមបាន ។ ប៉ុន្តែឯកសារនេះជាឯកសារសំខាន់ ប៉ុន្តែយើងមានការសោកស្តាយ ប្រសិនបើអាចធ្វើឱ្យបញ្ជូនមកឱ្យយើងយឺតពេក ហើយយើងមិនទាន់បានអង់គ្លេសទាន់ពេល ។ សូមអរគុណ ។

[០៩:៣៣:២៦]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៌៖**

លោកស្រី ហ្សាកកាំង គឺយើងមានតែជាភាសាខ្មែរទេ តាមដែលខ្ញុំដឹង ។ តើលោកស្រីមិនប្រកាន់ជំហរហ្នឹង ឬក៏យ៉ាងម៉េច?

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

លោកស្រីចៅក្រម យើងមិនបានទទួលថា មានអត្ថបទខ្មែរ អ៊ីចឹងហើយគឺយើងមានការលំបាក

យើងមិននិយាយភាសាខ្មែរ ។ ហើយយើងអាចនឹងមានជាភាសាណាមួយ ដែលយើងធ្វើការបាន ដូចជាអង់គ្លេស ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អ៊ីចឹងក្នុងវិធានតម្រូវឲ្យមានភាសាពីរ មួយជាភាសាខ្មែរ ។ អ៊ីចឹងគេបានគោរពហើយ អ៊ីចឹងជាអកុសល គឺថាភាសាទីបីមិនទាន់មាននៅឡើយនោះ ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៥:៤០]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះបានស្តាប់នូវការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា លើបញ្ហាពីរ ។ ទីមួយ គឺឯកសារកំណត់ហេតុនៃការធ្វើសម្ភាសលើសាក្សី ដែលត្រូវធ្វើសក្ខីកម្មនាពេលនេះ ដែលធ្វើឡើងដោយ *ឌីស៊ីខេម* ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ និងបញ្ហាទីពីរ គឺសុំបញ្ចាំងនូវខ្សែវីដេអូចំនួនពីរខ្សែជាសាធារណៈ ឬអសាធារណៈ ដើម្បីឲ្យសាក្សីនោះធ្វើការកត់សម្គាល់ ។ ហើយទីពីរ គឺបញ្ហានេះ ក៏មានការគាំទ្រពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីខ្លះ ប៉ុន្តែក៏មានការជំទាស់ពីមេធាវីការពារក្តីដែរ ហើយដោយសារបញ្ហានេះ មានភាពស្មុគស្មាញផ្នែកខាងផ្លូវច្បាប់ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកសែសិបប្រាំមីនុតដើម្បីថយទៅពិចារណា ដើម្បីសម្រេចលើបញ្ហាស្នើសុំនេះ ។ ដោយឡែក ក៏សូមបញ្ជាក់ផងដែរថាសូមអភ័យទោសចំពោះសាក្សី នង ចាន់ផល ដែលការអាក់ខាន មិនបានឲ្យលោកធ្វើការផ្តល់សក្ខីកម្មភ្លាមៗតាមកាលបរិច្ឆេទតាមពេលវេលាដែលបានគ្រោងទុក ដោយមានហេតុផលនៃបញ្ហាច្បាប់ មិនមែនដោយសារហេតុនៃបុគ្គលរបស់លោក នង ចាន់ផល ផ្ទាល់ទេ អ៊ីចឹងសូមអត់ធ្មត់ និងសូមអធ្យាស្រ័យ ។ អ៊ីចឹង អង្គជំនុំជម្រះប្រកាសសម្រាកសែសិបប្រាំមីនុត ។ សូមអញ្ជើញ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន សូមអនុញ្ញាតជម្រាបជូន សូមអធ្យាស្រ័យ ។ សូមគ្រាន់តែជូនជាយោបល់មួយ ភាគីខាងដើមបណ្តឹងរដ្ឋប្បវេណី បានមានប្រសាសន៍ថា “ឲ្យបញ្ចាំងខ្សែវីដេអូពីរឈុតហ្នឹងទៅ ពីព្រោះ នង ចាន់ផល មកដល់ហើយ វាស្រួលនឹងគេបញ្ជាក់” ។ ហើយចុះអង្កាល់ពីមុន មុនថ្ងៃហ្នឹង ពីម្សិលមិញ ពីថ្ងៃមុនទៅទៀតនោះ ដែលព្រះរាជអាជ្ញាបានសុំស្នើបញ្ចាំងខ្សែវីដេអូនោះ តើមាន នង ចាន់ផលនៅហ្នឹងទេ? អត់មានទេ ។ អាអង្កាល់ថ្ងៃមុនហ្នឹង ដូច្នេះខ្ញុំយល់ថា ចាំថ្ងៃក្រោយ ចាំបញ្ចាំង

ទៅក៏បានដែរ ហើយបើចង់បាន នង ចាន់ផល មក គាត់មានរត់ទៅណា! នៅហ្នឹងតើ អញ្ជើញគាត់មកម្តងទៀតទៅឲ្យគាត់មកបញ្ជាក់ និងជាយោបល់របស់ខ្ញុំ ។ សូមជូនប៉ុណ្ណឹងសូមអរគុណលោកប្រធាន ។

**លោក វីលៀម ស្មីត៖**

លោកប្រធាន! ប្រសិនបើខ្ញុំលើកជាយោបល់សង្ខេបមួយ ខ្ញុំដូចជាមិនយល់អ្វីដែលមេធាវីការពារក្តីបានលើកឡើងនោះទេ ។ ហើយគឺ នង ចាន់ផល គឺជាតួអង្គនៅក្នុងខ្សែវីដេអូនេះ គឺគាត់មានអាយុ៨ ឬ ៩ឆ្នាំ ហើយខ្ញុំជឿថា ពិតជារូប នង ចាន់ផល មែន ដែលយើងឃើញរូបគាត់នៅក្នុងរូបខ្សែវីដេអូនោះ ។

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញនេះ យើងបានប្រកាសសំរាកដកខ្លួនថយហ្នឹង គឺដើម្បីទៅពិភាក្សាសម្រេចលើបញ្ហាសំណើធំដែលកំពុងតែមានបញ្ហាចម្រូងចម្រាស់ ។ ការស្នើសុំ និងការជំទាស់ពីភាគីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង ចំណាយពេលវេលាសែសិបប្រាំនាទី ចាប់ពីម៉ោងនេះទៅ ផុតប្រហែលជាសែសិបប្រាំនាទីហ្នឹងយើងនឹងត្រឡប់ចូលវិញ ដើម្បីប្រកាសអំពីលទ្ធផលនៃសេចក្តីសម្រេចពាក់ព័ន្ធនឹងបញ្ហាចម្រូងចម្រាស់នាពេលនេះ ។

*[សវនាការសម្រាកពីម៉ោង ០៩:៤០នាទី ដល់ម៉ោង ១០:២៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ ហើយជាដំបូងនេះ មន្ត្រីតុលាការសូមអញ្ជើញលោក នង ចាន់ផល ចូលមកកាន់បន្ទប់សវនាការវិញ ។

*(សាក្សីចូលមកកាន់បន្ទប់សវនាការ)*

[១០:២៧:០០]

ជាដំបូងនេះ អង្គជំនុំជម្រះប្រកាសនូវសេចក្តីសម្រេច ទាក់ទងនូវសំណើសុំរបស់សហព្រះរាជអាជ្ញា អំពីកំណត់ហេតុនៃកិច្ចសម្ភាសន៍លើ នង ចាន់ផល ដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ ដូចខាងក្រោម៖

អង្គជំនុំជម្រះកត់សម្គាល់ថា ការដាក់កិច្ចសម្ភាសន៍របស់ នង ចាន់ផល ដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងរួចហើយ

អង្គជំនុំជម្រះបដិសេធនូវសំណើសុំដាក់ឯកសារនេះ មកដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ដោយផ្អែកតាមវិធាន៨៧.៤ នៃវិធានផ្ទៃក្នុង ។ មូលហេតុដោយសារ កិច្ចសម្ភាសន៍នេះត្រូវបានធ្វើឡើង កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ ហើយសហព្រះរាជអាជ្ញា បានទទួលកិច្ចសម្ភាសនេះជាភាសាខ្មែរជាច្រើនខែមកហើយ ។ ប៉ុន្តែ ទើបតែយកកិច្ចសម្ភាសនេះ មកដាក់នៅក្នុងសំណុំរឿងនៅព្រឹកនេះ ដែលមិនអាចឱ្យភាគី ជាពិសេសភាគីមេធាវីការពារក្តី មិនមានលទ្ធភាពក្នុងការពារកូនក្តីរបស់ខ្លួនបាន ។

ចំណែកឯបញ្ហាសំណើមួយទៀត ពាក់ព័ន្ធនឹងខ្សែវីដេអូពីរខ្សែ ខ្ញុំសូមប្រគល់ភារៈនេះ ជូនទៅលោកស្រីចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ដើម្បីធ្វើការបញ្ជាក់ជូនភាគី និងអង្គសវនាការ ។ សូមអញ្ជើញលោកស្រី ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ សហព្រះរាជអាជ្ញាបានស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យខ្លួនដាក់បញ្ចាំងខ្សែវីដេអូខ្លីៗចំនួនពីរ ដែលផ្តល់ដោយរដ្ឋាភិបាលវៀតណាមមកឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ព្រឹកមិញនេះ សហព្រះរាជអាជ្ញាបានបញ្ជាក់ពីសំណើនេះឡើងវិញ ដោយមានការចង្អុលបង្ហាញថា សាក្សីរូបនេះឈ្មោះ នង ចាន់ផល នោះគាត់គឺជាអ្នកអាចបញ្ជាក់ពីភាពត្រឹមត្រូវ នូវខ្សែវីដេអូខ្លីៗនេះបាន ។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា ខ្សែវីដេអូទាំងនេះបានដាក់ចូលក្នុងសំណុំរឿងរួចហើយ ហើយក៏បានកត់សម្គាល់ឃើញដែរថា ខ្លួនមិនទាន់នឹងសម្រេចថាតើខ្សែវីដេអូខ្លីនេះ អាចនឹងដាក់មកដេញដោល នៅចំពោះមុខអង្គជំនុំជម្រះនៅឡើងយទេ ។

[១០:៣០:០៥]

ខ្ញុំសូមបំភ្លឺជូនសហព្រះរាជអាជ្ញាថា ដែលទាក់ទងទៅនឹងថា តើហេតុផលរបស់ខ្លួនក្នុងការចង់ដាក់ឱ្យខ្សែវីដេអូនេះដេញដោលចំពោះមុខតុលាការនៅដដែលឬទេ? អ៊ីចឹងហើយ គោលបំណងពីដំបូងរបស់សហព្រះរាជអាជ្ញានោះ ដែលបានបញ្ជាក់ព្រឹកមិញផងដែរ នេះជាខ្សែវីដេអូតែពីរគត់ ដែលបានថតនៅទួលស្លែង ដែលភ្លាមៗបន្ទាប់ពីចប់របបសម័យនោះ ដែលថា ក្រោយពីគេបានប្រើជាគុករបស់កម្ពុជាប្រជាធិបតេយ្យ ដែលធ្វើឱ្យភស្តុតាងនេះ ជាពិសេសនោះវាមានលក្ខណៈតម្លៃជាពិសេសដាច់ខាតមួយ ។ ហើយសហព្រះរាជអាជ្ញាក៏បានអះអាងពីដំបូងផងដែរថា ខ្សែវីដេអូមួយនេះវាមានការទាក់ទងដោយថា គឺថាវាស្របគ្នាជាមួយសក្ខីកម្មរបស់សាក្សីផ្សេងៗទៀត ដែលថា កូនរបស់កម្មាភិបាលក៏ត្រូវបានគេយកទៅស-២១ ផងដែរ ។

ហើយចំណុចទីពីរ កុមារដែលមានរូបនៅក្នុងខ្សែវីដេអូនេះ គឺថាមានរូបភាពដូចជាមានសុខភាពអន់ខ្សោយ ដោយថាលក្ខខណ្ឌចំពោះកុមារនៅក្នុងស-២១ គឺមានលក្ខណៈអមនុស្សធម៌ ។ អ៊ីចឹង ខ្ញុំចង់ស្តាប់មតិពីសហព្រះរាជអាជ្ញា ថាតើមូលហេតុទាំងអស់ហ្នឹង ដែលលោកបញ្ជាក់នៅដដែលដែរឬទេ? ហើយចំណុចទីពីរ ថាតើលោកចាត់ទុកថា គឺជាសក្ខីកម្មគ្រប់គ្រាន់ដែរឬទេ ទាក់ទងនឹងពីរចំណុចដែលទាក់ទងទៅនឹងភាពទាក់ទង នៃវីដេអូនេះទៅនឹងសំណុំរឿងនៃរឿងក្តីនេះ?

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកចៅក្រម ។ យើងឃើញមានភស្តុតាងទាក់ទងទៅនឹងស្ថានភាពអមនុស្សធម៌ ដែលកូនក្មេងត្រូវបានឃុំនៅស-២១ ។ ភស្តុតាងទាំងអស់នោះ គឺវាមានការគាំទ្រ ហើយមានតម្លៃចំពោះអង្គហេតុ ដោយសារមូលហេតុនេះហើយ គឺយើងសូមឲ្យធ្វើការបញ្ចូលរូបភាពវីដេអូនោះក្នុងលក្ខណៈជាភស្តុតាង ។ ហើយហេតុអ្វីបានជាខ្សែវីដេអូនេះ វាមានលក្ខណៈពាក់ព័ន្ធនិងមានតម្លៃ ហេតុផលដែលពាក់ព័ន្ធនោះ គឺថាខ្សែវីដេអូនេះ គឺជាឯកសារសម្ភារៈល្អបំផុតដែលបង្ហាញស-២១ នៅពេលនោះ ។

ដូចដែលលោក លោកស្រីចៅក្រម បានជ្រាបហើយ ខ្សែភាពយន្តនៃស-២១ នៅពេលក្រោយមកនៅពេលដែលទីកន្លែងត្រូវបានរៀបចំនោះ ឯកសារវីដេអូនោះ កាលពីមុននោះ គឺបានបង្ហាញអំពីស្ថានភាពរស់នៅដែលគេរស់នៅនាពេលនោះ ។ ហើយវាជាភស្តុតាងសំខាន់ចំពោះការកាប់សម្លាប់នៅស-២១ ដែលលោក លោកស្រីបានជ្រាបនិងមើលនៅក្នុងខ្សែភាពយន្តនោះ ហើយយើងឃើញមានរូបភាពសាកសពបួន ត្រូវបានគេសម្លាប់នៅពេលដែលវៀតណាមចាកចេញពីទីនោះ ។

[១០:៣៣:២៩]

ហើយវាក៏បានផ្តល់ភស្តុតាងផងដែរ អំពីស្ថានភាពនៃការឃុំខ្លួន អំពីអង្គហេតុនៃការឃុំខ្លួន ឧបករណ៍ធ្វើទារុណកម្ម ។ ដូច្នេះ សហព្រះរាជអាជ្ញា សូមដាក់លើសអ្វីដែលលោកស្រីចៅក្រម បានលើកឡើងថា ខ្សែវីដេអូនេះគឺវាបង្ហាញអំពីទិដ្ឋភាពច្រើនណាស់ទៅលើអង្គហេតុ ។ ហើយដោយសារខ្សែវីដេអូថតនៅពេលនោះ គឺជាភស្តុតាងដែលល្អបំផុត ហើយលោក លោកស្រីចៅក្រម គួរតែយកមកពិចារណាចំពោះលក្ខណៈដែលថា វានឹងបង្ហាញទៅដល់សេចក្តីពិតនៅក្នុងរឿងក្តីនេះ ។ សូមអរគុណ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៌៖**

សូមអរគុណលោក ស្មីត ។ អង្គសវនាការបានលើកឡើងថា អង្គសវនាការមិនទាន់បានសម្រេចថា យើងបញ្ចូលខ្សែវីដេអូនេះនៅក្នុងចំពោះមុខអង្គសវនាការនៅឡើយនោះទេ ។ ប៉ុន្តែ នៅដំណាក់កាល

ក្រោយបន្ទាប់ពី សាក្សីរូបនេះបានផ្តល់សក្ខីកម្ម យើងអាចធ្វើការសម្រេចទៅលើផ្នែកខ្លីៗ ផ្នែករូបភាពខ្លីៗនៅពេលនោះ ។ ហើយយើងនៅពេលនេះ មិនទាន់បានសម្រេចទៅលើខ្សែវីដេអូទាំងមូលនៅឡើយទេ ។ សូមអរគុណ ។

**សួរដោយប្រធានអង្គជំនុំ៖**

ឥឡូវនេះ យើងធ្វើការសាកសួរដល់សាក្សី នង ចាន់ផល ។

**ស៖** លោកឈ្មោះ នង ចាន់ផល អ៊ីចឹងមែនទេ?

**ឆ៖** បាទ, ខ្ញុំឈ្មោះដូច្នេះមែន ។

**ស៖** លោកមានឈ្មោះហៅក្រៅផ្សេងទៀតពី ចាន់ផល ដែរទេ?

**ឆ៖** បាទ, គ្មានទេបាទ ។

**ស៖** លោកដឹងអំពីថ្ងៃខែឆ្នាំកំណើតរបស់លោកពិតប្រាកដដែរឬទេ? តើលោកកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ចំពោះថ្ងៃខែ ខ្ញុំបាទអត់បានចាំទេ ដោយថា ខ្ញុំនៅក្មេងពេក ។ ប៉ុន្តែខ្ញុំចាំបាននៅឆ្នាំ គឺខ្ញុំកើតនៅឆ្នាំ១៩៧០ ។

[១០:៣៦:១១]

**ស៖** អ៊ីចឹង មកដល់ឆ្នាំនេះ លោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** មកដល់ឆ្នាំនេះ ខ្ញុំបាទមានអាយុ៣៩ ឆ្នាំហើយ ។

**ស៖** ឪពុកបង្កើតរបស់លោកគាត់ឈ្មោះអ្វីដែរ?

**ឆ៖** ឪពុករបស់ខ្ញុំបាទ ឈ្មោះ នង ចិន ។

**ស៖** ហើយគាត់មានមុខរបរធ្វើអ្វីមុន ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥? ហើយគាត់ធ្វើការនុ៎ងនៅឯណា?

**ឆ៖** បាទ, សុំម្តងទៀត ខ្ញុំអត់ច្បាស់ ។ ស្តាប់អត់ច្បាស់ ។

**ស៖** ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើឪពុករបស់លោកហ្នឹង គាត់ធ្វើការងារអ្វី? ហើយការងារដែលគាត់ធ្វើនោះ នៅទីកន្លែងណា?

**ឆ៖** ខ្ញុំបាទនៅក្មេង អត់បានចាំគាត់ធ្វើអ្វីទេ កាលពីឆ្នាំនោះ ។

**ស៖** លោកដឹងថា ស្រុកកំណើតរបស់ឪពុកលោកហ្នឹងនៅទីណាដែរទេ?

**ឆ៖** បាទ, ស្រុកកំណើតឪពុកខ្ញុំ ខ្ញុំអត់បានចាំស្គាល់ទេ ស្គាល់តែខាងម្ដាយ ។

**ស៖** ចុះម្ដាយរបស់លោកគាត់ឈ្មោះអ្វីដែរ?

**ឆ៖** ម្ដាយរបស់ខ្ញុំបាទឈ្មោះ មុំ យ៉ូវ ។

**ស៖** គាត់មានឈ្មោះហៅក្រៅផ្សេងពីឈ្មោះ យ៉ូវ ដែរទេ?

**ឆ៖** បាទ, មានគាត់ឈ្មោះនៅក្រៅគាត់យាយ អ៊ីក១ បាទ ។

**ស៖** ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើម្ដាយរបស់លោកគាត់ប្រកបមុខរបរអ្វីដែរ? ហើយគាត់នៅឯណាដែរ?

**ឆ៖** ក្រោយឆ្នាំ១៩៧៥ ខ្ញុំបាទនៅក្មេងអត់សូវបានចាំ ប៉ុន្តែខ្ញុំដឹងថា មកដល់រស់នៅសហករណ៍មួយនៅឯភូមិត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ជាសហករណ៍មួយអារឈើជាកំណល់រទេះភ្លើង បាទ ។

**ស៖** លោកមានបងប្អូនបង្កើតប៉ុន្មាននាក់? ហើយប្រុសប៉ុន្មានស្រីប៉ុន្មាន?

**ឆ៖** ខ្ញុំបាទមានបងប្អូន ៧នាក់ ស្រី៣ ប្រុស៤ ។ ហើយដែលខ្ញុំមកជាមួយម្ដាយខ្ញុំនៅទួលស្លែងនេះ មានពីរនាក់តែខ្ញុំ និងប្អូនខ្ញុំ ។

[១០:៤០:១០]

**ស៖** នៅមុនឆ្នាំ១៩៧៨ លោករស់នៅទីកន្លែងណា?

**ឆ៖** មុនឆ្នាំ១៩៧៨ ខ្ញុំបាទរស់នៅភូមិដូចខ្ញុំបានជម្រាបលោកខាងលើអំមិញ នៅភូមិត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ យើងនេះជាសហករណ៍មួយ មានរោងចក្រម៉ាស៊ីនអារឈើធ្វើជាកំណល់រទេះភ្លើង ហ្នឹងជាមួយនឹងឪពុកនិងម្ដាយខ្ញុំបាទ ។

**ស៖** នៅក្នុងជំនាន់កាលពីឆ្នាំ១៩៧៧ ឬ១៩៧៨នោះ មុខរបររបស់ឪពុកលោក និងម្ដាយរបស់លោកហ្នឹងមានមុខរបរដោយឡែកផ្សេងពីគ្នា ឬក៏គាត់ធ្វើការងារដូចគ្នា?

**ឆ៖** ឪពុកខ្ញុំគាត់ជាកម្មាភិបាលខ្មែរក្រហម នៅក្នុងសហករណ៍រោងម៉ាស៊ីនអារឈើនោះ ហើយម្ដាយខ្ញុំគាត់ជាកសិករធម្មតា ។

**ស៖** លោកបានដឹងថា ឪពុករបស់លោកត្រូវបានឃ្លាតឆ្ងាយពីលោក និងម្ដាយគ្រួសាររបស់លោក ហ្នឹងពីពេលណាមក? ដែលគាត់បាត់ចេញឃ្លាតឆ្ងាយពីលោក និងគ្រួសាររបស់លោក? លោកចាំទេ?

**ឆ៖** ខ្ញុំសូមម្តងទៀតឲ្យច្បាស់។

**ស៖** លោករកនឹកឡើងវិញ ពីព្រោះកាលនោះលោកនៅតូច បានន័យថា បើគិតដល់ឆ្នាំ១៩៨៧ លោកមានអាយុត្រឹមតែ៧ឆ្នាំប៉ុណ្ណោះ ហើយបើដល់ឆ្នាំ១៩៧៨ អំមិញគឺ ១៩៧៧ គឺមានអាយុ៧ឆ្នាំ ហើយបើដល់១៩៧៨ គឺមានអាយុតែ៨ឆ្នាំប៉ុណ្ណោះ ។ អ៊ីចឹងកាលដែលវាមានវ័យនៅក្មេង អ៊ីចឹងឲ្យលោករកនឹកបន្តិច តើលោកបានដឹងថា លោកបានឃ្លាតឆ្ងាយ ឬក៏ពុករបស់លោកបានឃ្លាតចាកចេញឆ្ងាយពីលោកទៅនោះ គាត់ចាកចេញទៅនៅក្នុងអំឡុងពេលណា?

**ឆ៖** រឿងពេលវេលា ខ្ញុំបាទអត់បានចាំ ព្រោះខ្ញុំបាទនៅក្មេងពេក ប៉ុន្តែដឹងថាគេត្រូវបានយក គេមានសំបុត្រគេផ្ញើមកឲ្យគាត់ ហើយគាត់ក៏បានទៅជាមួយគេមកភ្នំពេញ ហើយថាមករៀនសូត្រ ហើយពូរបស់ខ្ញុំជាប្អូនឪពុកខ្ញុំ គាត់ជាកម្មករលីកំណល់រទេះនៅក្នុងម៉ាស៊ីននោះ ល្ងាចនុំងបានរត់មកប្រាប់ម្តាយខ្ញុំ ថាបងត្រូវបានគេ-- មានលិខិតសំបុត្រអីឲ្យអញ្ជើញគាត់ទៅភ្នំពេញហើយ តែខ្ញុំមិនបានចាំថ្ងៃខែ ឬក៏ឆ្នាំទេពេលនោះ។ ខ្ញុំអត់បានរៀន បានដឹងអីទេ ។ ទាល់តែពេលក្រោយមកបានគេមកយកម្តាយខ្ញុំទៅទៀត និងខ្ញុំហ្នឹង ។

[១០:៤៣:៥៧]

**ស៖** លោកចាំដែរទេថា ពេលដែលគេមកយកម្តាយរបស់លោក លោកជាមួយហ្នឹងប្អូនរបស់លោកម្នាក់ទៀតហ្នឹងនៅក្នុងឆ្នាំណាទៅ? ឬក៏ក្រោយពីគេកោះហៅ គេចេញលិខិតហៅឪពុករបស់លោកមកភ្នំពេញហ្នឹងរយៈពេលប៉ុន្មានដែរ បើគិតពីពេលដែលឪពុកលោកមកភ្នំពេញ ហើយនិងពេលដែលម្តាយរបស់លោក លោកនិងប្អូនរបស់លោកដែលគេនាំយកមកទីក្រុងភ្នំពេញនោះ ?

**ឆ៖** បាទ, ខ្ញុំដូចជាមិនចាំទេ ។ ដោយសារតែខ្ញុំនៅក្មេង ហើយកាលពេលគេយកឪពុកខ្ញុំមកហ្នឹង ក្នុងរយៈពេលហ្នឹងម្តាយខ្ញុំរង់ចាំ ខ្ញុំសួរថា ថ្ងៃណាបានពុកគាត់ត្រឡប់មកវិញ? ម្តាយខ្ញុំគាត់ចេះតែរង់ចាំមើលផ្លូវគាត់ ។ តែបើតាមម្តាយខ្ញុំចេះតែប្រាប់ខ្ញុំបណ្តើរៗថា ប្រហែលជារយៈពេលយូរហើយប្រហែលជាបីខែ ។ ក្រោយមកផុតរយៈពេលបីខែហ្នឹង បានគេមកយកម្តាយខ្ញុំម្តងទៀត យកទាំងខ្ញុំនិងប្អូនខ្ញុំទៅ ។

**ស៖** ប្អូនរបស់លោកដែលមកភ្នំពេញជាមួយនឹងលោកនិងម្តាយរបស់លោកហ្នឹង ឈ្មោះអ្វីទៅ? ហើយប្រុស ឬក៏ស្រី?

**ឆ៖** ប្អូនខ្ញុំបាទមកជាមួយនោះ ឈ្មោះ នង ចាន់លី ហៅ អាឡិត ហើយវាប្រុសដែរ ប្រុសដូចខ្ញុំ ក្មេងប្រុស ។

**ស៖** នង ចាន់លី ហៅ ឡិត ហ្នឹង គាត់មានអាយុប្អូនលោកប៉ុន្មានឆ្នាំ? ជាប្អូនបន្ទាប់លោក ឬក៏មានប្អូនទីពីរបន្ទាប់ពីលោក? ហើយគាត់ឥឡូវនេះ ប្អូនលោកប៉ុន្មានឆ្នាំទៅ?

**ឆ៖** បាទ, វាប្អូនខ្ញុំបួនឆ្នាំ ។ វាប្អូនពៅ ខ្ញុំទីប្រាំមួយ វាទីប្រាំពីរ វាប្អូនពៅ ។

**ស៖** លោករកនឹកមើលថា ពេលដែលលោកធ្វើដំណើរមកក្រុងភ្នំពេញ ដោយមានការបញ្ជូនពីកម្លាំងរបស់ខ្មែរក្រហមនុ៎ង តើលោកធ្វើដំណើរដោយមធ្យោបាយអ្វី? ហើយមកដល់ទីណាខ្លះ? មុននឹងគេបញ្ជូនទៅដល់មន្ទីរសន្តិសុខស-២១ នោះ?

**ឆ៖** បាទ, ខ្ញុំនៅចាំដោយឆ្នាំហ្នឹងមានរថយន្តពីរគ្រឿងអាហ្ស៊ីបនុ៎ងមកយកម្តាយខ្ញុំហ្នឹង ហើយខ្ញុំឃើញឡាននោះពីរ ហើយមានស្ត្រីពីរនាក់នៅលើនុ៎ងហើយ។ ស្ត្រីមួយមានកូនពីរនាក់ ប្រុសមួយ ស្រីមួយ ។ ហើយម្នាក់ទៀតមានកូនប្រុសមួយបីនឹងដៃ ។ ហើយស្ត្រីដែលមានកូនពីរនាក់ស្រីមួយ ប្រុសមួយ អាតូចមួយក៏បីនឹងដៃដែរ ។ ហើយនិងម្តាយខ្ញុំមួយទៀត ស្រីបីនាក់ ហើយនិងខ្ញុំពីរនាក់បងប្អូនទៀត វាក្មេងប្រាំនាក់ ។ ហើយ--

**ស៖** គេដឹកជញ្ជូនលោកពីភ្នំស្រួច កំពង់ស្ពឺ មកកាន់ភ្នំពេញមក ធ្វើដំណើរពេលយប់ ឬក៏ពេលថ្ងៃ?

[១០:៤៨:០០]

**ឆ៖** បាទ, ធ្វើដំណើរមកហ្នឹងនៅពេលថ្ងៃ ។

**ស៖** ហើយគេនាំមកដំបូង មកដល់កន្លែងណាទៅ? ឬក៏គេនាំចូលទៅមន្ទីរសន្តិសុខស-២១ បច្ចុប្បន្នគេហៅថាគុកទួលស្លែងតែម្តង? ឬក៏មកដល់នៅកន្លែងណាស្នាក់ សំណាក់នៅកន្លែងណាមុនមួយរយៈមុនពេលទៅដល់មន្ទីរនោះ?

**ឆ៖** បាទ, ខ្ញុំបាទធ្វើដំណើរមកដល់ទីក្រុងភ្នំពេញហ្នឹង ចូលមកដល់សម្រាកនៅវ៉ារទេះភ្លើង បើខ្ញុំនៅចាំបាន ។ សម្រាកក្នុងវ៉ារទេះភ្លើងហ្នឹងបីថ្ងៃដោយម្តាយខ្ញុំគាត់ឈឺហើមផង គាត់មានកំសៀវទឹកដាំថ្នាំ មួយកំសៀវ ហើយគាត់បានសុំគេដាំថ្នាំហ្នឹងនៅក្នុងវ៉ារទេះភ្លើង ហើយគេបានបដិសេធថា នៅទីនេះអត់ឲ្យមានបង្កាត់ភ្លើងដាំថ្នាំដាំអីទេ ហើយមានអ្នកយាមនៅហ្នឹងអត់ឲ្យចេញទៅណាដែរ។

**ស៖** ហើយនៅពេលគេបញ្ជូនប្អូននិងម្តាយរបស់លោក ប្អូនរបស់លោកមកកាន់មន្ទីរស-២១ហ្នឹង គេបញ្ជូនដោយមធ្យោបាយអី? ហើយបញ្ជូនមកពេលណា? យប់ឬក៏ពេលថ្ងៃ?

**ឆ៖** បាទ, បើខ្ញុំនៅចាំបាន ពេលល្ងាចថ្ងៃទីបីហ្នឹងគេបញ្ជូនដោយរថយន្តដដែលហ្នឹង ចូលមកដល់ទួលស្លែងហ្នឹងពេលល្ងាច ថ្ងៃរៀងរសៀលហើយ ចូលមកដូចជារៀងស្រាងៗដូចចង់ថ្ងៃលិច ចូលមកដល់ មកដល់ទួលស្លែងហ្នឹង ។

**ស៖** ពេលចូលមកដល់ទួលស្លែងលោក គិតឡើងវិញមើលថាតើលោកនៅចងចាំស្ថានភាព ឬក៏ទិដ្ឋភាពយ៉ាងម៉េចខ្លះទៅ? ក្នុងការប្រព្រឹត្តម្តាយរបស់លោក និងលោក និងប្អូនរបស់លោកមកដល់ជាលើកដំបូងមកដល់នូវមន្ទីរសន្តិសុខស-២១ ដែលយើងហៅបច្ចុប្បន្ននេះថា“គុកទួលស្លែង”នោះ? ទិដ្ឋភាពយ៉ាងម៉េច និងយ៉ាងណាខ្លះដែលលោកនៅចងចាំ?

**ឆ៖** បាទ, ខ្ញុំនៅចងចាំពេលដែលរថយន្ត ពេលឡានខ្ញុំមកដល់ហ្នឹង ខ្ញុំក្មេងៗមានការសប្បាយណាស់ ព្រោះបានជិះឡានជិះអីអ៊ីចឹង ប្អូនខ្ញុំអីហ្នឹង ។ ទាល់ពេលមកដល់ចូលក្នុងច្រកទ្វារទួលស្លែងហ្នឹងមានការ សម្លុតគំរាម ដោយរុញច្រានម្តាយខ្ញុំចុះពីលើឡានហ្នឹង ហើយដោយគាត់ឈឺហើមផង គាត់ដើរទៅមុខ ទៅក្រោយមិនបានល្អអ៊ីចឹង។ ដើរ-- មានការរុញច្រានហើយស្រែកសំឡុតគាត់ ហើយខ្ញុំមានការតក់ស្លុតកន្លែងហ្នឹងបាទ ។

**ស៖** ហើយបន្ទាប់មកគេធ្វើយ៉ាងម៉េចទៀត?

**ឆ៖** បន្ទាប់មកចូលទៅក្នុងប៊ុយរ៉ូនៅខាងមុខហ្នឹង បើខ្ញុំនៅចាំ ចូលទៅដល់ក្នុងហ្នឹងមានបន្ទប់មួយគេហៅ បន្ទប់ហ្នឹងមានឥដ្ឋការ៉ូ ហើយនិងជញ្ជាំងពណ៌ស ហើយមានម៉ាស៊ីនថតឈរ ដោយគេបង្គាប់បញ្ជាម្តាយខ្ញុំឲ្យឈរហើយនិងអង្គុយ ហើយឈរចំហៀង ហើយកាន់លេខ ដូចកាន់ជាក្រដាសលេខអីម៉េច ខ្ញុំនៅក្មេងមិនដឹងជាលេខប៉ុន្មាន ។

[១០:៥១:២៩]

**ស៖** បន្ទាប់មកគេប្រព្រឹត្តយ៉ាងម៉េចទៀតចំពោះគាត់ ហើយនិងចំពោះលោកទៅ?

**ឆ៖** ទាល់តែពេលខ្ញុំឃើញគេសម្លុតគាត់ទៅ រុញច្រានគាត់ទៅ ដោយថាគាត់ឈរនៅចំពោះមុខម៉ាស៊ីនថត ដូចគាត់មិនដែលធ្លាប់ឈរនៅពីមុខម៉ាស៊ីនថត ថតខុសថតឡើងទៅ គេមានការទះតប់គាត់ រុញច្រានទៅមុខ ហើយខ្ញុំភ័យខ្លាចកន្លែងនុ៎ងបាទ ។ *(សាក្សីយំ)*

**ស៖** លោក នង ចាន់ផល លោកពង្រឹងស្មារតី ពង្រឹងស្មារតីឲ្យបានល្អនេះជាឱកាសមួយដែលលោកអាចលាតត្រដាងនូវអំពើផ្សេងៗដែលបានរំលោភបំពានដែលអយុត្តិធម៌មកលើរូបលោក ឬក៏គ្រួសាររបស់លោក ហើយលោកនឹងអាចលាតត្រដាងនូវបញ្ហានេះដល់អង្គជំនុំជម្រះបានយល់អំពីហេតុការណ៍ផ្សេងៗដែលកើតមានចំពោះលោក និងគ្រួសារលោក ដើម្បីអង្គជំនុំជម្រះហ្នឹងគឺមានមូលដ្ឋានក្នុងការបកស្រាយក្នុងការពិចារណា ហើយនិងយកបញ្ហានេះទៅសម្រេចសេចក្តី ។ ហើយអ៊ីចឹង គឺលោកអាចធ្វើការធ្វើអារម្មណ៍ឲ្យបានល្អ ឲ្យបានរឹងមាំ រឹងប៉ឹងឡើង ។

ម៉េចទៅមេធាវី?

**លោក អាឡាំង វ៉ែនណឺ៖**

ខ្ញុំសុំទោសដែលខ្ញុំឡើងកាត់នេះ ។ ប្រសិនបើ ប្រហែលជាគាត់ត្រូវការប៉ុន្មាននាទី ឲ្យគាត់សម្រួលអារម្មណ៍នៅខាងក្រៅ ។ ហើយនេះគឺជាបញ្ហាដែលថាយើងត្រូវការប្រាំនាទីដើម្បីឲ្យគាត់ធ្វើការសម្រាកចេញក្រៅ ហើយសម្រួលអារម្មណ៍របស់គាត់ ។ ខ្ញុំសូមអរគុណ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ម៉េចទៅលោក នង ចាន់ផល? អាចត្រូវសុំសម្រាកសិន ឬក៏អាចបន្តទៅទៀតបាន? បើសម្រាកប្រាំនាទីអី ចូលមកវិញអាចបន្តការងារបានទេ ឬក៏នៅតែដូច្នេះទៀត? ឬក៏យ៉ាងម៉េច?

**ផ៖** បាទ, អាចបន្តទៅទៀត ។

[១០:៥៥:00]

**ស៖** ពេលមកដល់ហ្នឹង ក្រោយគេថតរូបរួច តើគេចាត់ការលើម្តាយរបស់លោកយ៉ាងម៉េច ហើយគេចាត់ការចំពោះលោកនិងប្អូនរបស់លោកយ៉ាងម៉េច?

**ផ៖** បាទ, ខ្ញុំនៅចាំបានថា កាលពីឪពុកម្តាយខ្ញុំនៅកន្លែងសហករណ៍នោះ ឃើញគេមានការគោរពគាត់ គេហៅ “លោកពូៗ អ្នកមីង” អ៊ីចឹង ។ តែពេលមកដល់ ទួលស្លែង ខ្ញុំក្មេងអត់ដឹងថាកន្លែងហ្នឹងជាគុកឃុំឃាំងអីទេ ខ្ញុំគ្រាន់តែឃើញគេធ្វើបាបខ្ញុំអ៊ីចឹង ខ្ញុំមានការកត់ស្គុត ។ ហើយនៅពេលដែលខ្ញុំចេញពីបន្ទប់ថតហ្នឹងជាមួយម្តាយខ្ញុំហ្នឹង គឺត្រូវបញ្ជូននឹងទៅឡើងអគារទីបីហ្នឹង បន្ទប់ជាន់ទីពីរ បន្ទប់ទីពីរ ។

**ស៖** គេបញ្ជូនលោកហ្នឹងឡើងទាំងលោក និងប្អូនរបស់លោកទៅជាមួយម្តាយរបស់លោកតែម្តង ឬក៏មានការធ្វើយ៉ាងម៉េច?

**ឆ៖** បាទ, គេបញ្ជូនទៅទាំងអស់តាំងពីមកជាមួយគ្នាហ្នឹងទាំងស្ត្រីបីនាក់ ហើយក្មេងទាំងអស់ប្រាំនាក់ឡើងទៅបន្ទប់តែមួយទាំងអស់គ្នា បន្ទប់ធំមួយ ហើយបានបើកសោឲ្យចូលសម្រាននៅក្នុងហ្នឹង ហើយគេចាក់សោរពីក្រៅ ។

**សៈ** លោកទៅនៅក្នុងបន្ទប់ឃុំឃាំងជាមួយម្ដាយនៅជាន់ទី២ហ្នឹង អស់រយៈពេលប៉ុន្មានទៅបានលោកចាកចេញពីទីនោះមកនៅខាងក្រោមវិញ?

**ឆ៖** បាទ, ទៅដល់លើ បន្ទប់លើហ្នឹងសម្រាកបានមួយយប់ ។ ដល់ពេលព្រឹកឡើងគេបញ្ជូនក្មេងៗពួកខ្ញុំប្រាំនាក់ហ្នឹង មានក្មេងតូចៗខ្លះបីខ្លះអីហ្នឹង គេបីយកមកដាក់រោងជាងខាងក្រោយ រោងជាងខាងក្រោយគុកហ្នឹង វាមានទ្រុង កន្លែងនោះមានទ្រុងជ្រូក ទ្រុងអី មានចាស់ៗធ្វើជាងធ្វើអីមើលទៅខាងស្ដាំដៃ អីចេះមាន មានចាស់ៗនៅធ្វើឈើអារឈើអីហ្នឹង ។

**សៈ** ហើយលោកបាន-- ចាប់ពីគេដែលគេ ចាប់បំបែកចេញពីម្ដាយរបស់លោកហ្នឹង លោកដែលបានជួបម្ដាយរបស់លោកទៀតទេ?

**ឆ៖** បាទ, នៅថ្ងៃចុងក្រោយហ្នឹង ខ្ញុំរត់នៅលេងខាងក្រោយ មិនបានរត់លេង គ្រាន់តែនៅអង្គុយជាមួយជុំ ហើយមានស្ត្រីម្នាក់ ហើយមើលពួកខ្ញុំអត់ឲ្យដើរទៅណាទេ ។ ហើយខ្ញុំបានសម្លឹងទៅបន្ទប់ម្ដាយខ្ញុំនៅបន្ទប់ទីពីរ ជាន់ទីពីរហ្នឹង ខ្ញុំមើលទៅឃើញគាត់ឈរតោងចម្រឹងបង្អួច គាត់សម្លឹងមករកខ្ញុំដោយគាត់មិនបានិយាយមកកាន់ពួកខ្ញុំយ៉ាងម៉េចទេ ។

[១០:៥៧:០៣]

**សៈ** លោក នង ចាន់ផល អង្គជំនុំជម្រះរំឭកម្ដងទៀតដោយលោកពង្រឹងស្មារតីឡើងវិញ ហើយឲ្យមានលក្ខណៈរឹងប៉ឹងឡើង ។ ហើយដូចថាពេលនេះជាឱកាសល្អដែលលោកអាចរៀបរាប់អំពីទុក្ខសោកផ្ទាល់ខ្លួនក៏ដូចជាអ្វីដែលមានការប៉ះពាល់ទៅលើឪពុក ឬម្ដាយ លើគ្រួសាររបស់លោកនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ ។ ហើយប្រសិនបើ លោកទន់ជ្រាយ លោកមិនមានឱកាសនៅក្នុងការសម្ដែងចេញនូវអ្វីដែលជាទុក្ខសោករបស់លោក នូវអ្វីដែលជាទិដ្ឋភាពដែលលោកបានមើលឃើញ បានដឹង បានឮ នូវអំពើអយុត្តិធម៌ទាំងឡាយដែលរំលោភបំពានមកលើរូបលោកផ្ទាល់ រំលោភបំពានលើឪពុកម្ដាយរបស់លោកនោះបានទេ ។ ហើយប្រសិនបើ លោកទន់ជ្រាយនោះគឺ ទោះបីអង្គជំនុំជម្រះលើកសវនាការច្រើនលើកច្រើនសា បើស្ថានភាពលោកមិនរឹងប៉ឹង គឺនៅតែមិនអាចធ្វើបាន ។ អ៊ីចឹងឱកាសដែលអាចបកស្រាយនៅលើបញ្ហាអំពើផ្សេងៗដែលអយុត្តិធម៌ ដែលយង់ឃ្នង ដែលអមនុស្សធម៌

មកលើរូបលោកគឺមិនបានក្បោះក្បាយទេ ។

អ៊ីចឹង សូមលោកគិតធ្វើពង្រឹងសតិអារម្មណ៍ប្រកាន់ជំហររឹងប៉ឹងជាមនុស្សមួយដ៏រឹងមាំ ដើម្បីវែកញែក ដើម្បីបកស្រាយបំភ្លឺអំពីបញ្ហាហេតុការណ៍ផ្សេងៗដែលលោកបានឃើញ បានជួបប្រទះ ដើម្បីឲ្យស្ថានភាពនេះ-- ហើយថ្ងៃក្រោយយើងនឹងអាចមានការរម្ងាប់ ស្ងប់អារម្មណ៍ ដោយសារយើងមាននិយាយ បានសម្តែងចេញជាសាធារណៈនៅពេលនេះជាឱកាសល្អហើយ ។

ហើយក្រោយមកទៀត ក្រោយពីលោកជួបបានមើលតាមបង្គួចអ៊ីចឹងទៅ ។ សួរថាតើលោកប្អូនរបស់លោកនិងក្មេងៗបីនាក់ទៀតដែលរស់នៅជាមួយលោកនុ៎ង បានដេកនៅទីណា? ហើយរបបហូបចុកអីយ៉ាងម៉េចដែរ?

**ឆ៖** បាទ, ពួកខ្ញុំហ្នឹងសម្រាកនៅខាងក្រោយរោងជាងហ្នឹង ជាមួយនឹងក្មេងៗទាំងអស់ហើយនិងស្ត្រីចំណាស់ម្នាក់ហ្នឹង ជួយមើលពួកខ្ញុំហ្នឹង ។ ហើយហូបហ្នឹងបបរ បបរខ្ទះហ្នឹងមួយខ្ទះគេដាំជាបបរហ្នឹង គាត់ដួសមកឲ្យពួកខ្ញុំហូបចម្មតាអ៊ីចឹង ។

**ស៖** មួយថ្ងៃ គេឲ្យបបរលោក និងអ្នកក្មេងៗប្អូននាក់ទៀតជាមួយលោកហ្នឹងប៉ុន្មានពេលទៅ?

[១១:០១:០០]

**ឆ៖** បាទ, នៅក្នុងមួយថ្ងៃពីរពេល ព្រឹកមួយពេល ល្ងាចមួយពេល ។

**ស៖** ចុះពេលសម្រាកពេលយប់ទៅដេកនៅទីណា?

**ឆ៖** បាទ, នៅខាងក្រោយហ្នឹងដដែល ។ ខាងក្រោយរោងជាង ខាងក្រោយគុកហ្នឹងដដែលក្នុងរោងជាងហ្នឹង ។

**ស៖** ចុះមានស្ត្រីៗមើលថែហ្នឹង គេដេកនៅជាមួយពួកលោកដែរឬទេ?

**ឆ៖** ខ្ញុំដូចអត់ចាំច្បាស់សោះ អត់ចាំទេ ។

**ស៖** ចុះពេលលោកត្រូវងូតទឹកអី តើមានទៅងូតទឹកនៅកន្លែងណា?

**ឆ៖** ខ្ញុំអត់ចាំសោះ ដូចអត់មានដែលងូតទឹកសោះ ។

**ស៖** ជីវិតលោករស់នៅក្នុងស្ថានភាពដូចលោកនិយាយអ៊ីចឹង ពេលដែលបែកពីម្តាយទៅ ហើយលោកនៅទីនោះ នៅផ្នែកខាងម្តុំរោងជាងគឺខាងក្រោយអគារនៃកន្លែងឃុំឃាំងម្តាយហ្នឹង អស់រយៈពេលប្រហែលជាប៉ុន្មានទៅលោកបានលោកគិត សាកល្បងគិតមើល រយៈពេលយូរទេ ឬក៏មិនជាយូរប៉ុន្មានទេ? ពីព្រោះលោកបាននិយាយអំមិញថា លោកកាលណោះ គឺមិនចាំទេ បើយើងថា យ៉ាងច្រើនក្នុងឆ្នាំ

១៩៧៨ លោកមានអាយុត្រឹមតែ៨ឆ្នាំ ប៉ុណ្ណោះ ។ ហើយបើគិតប្អូនរបស់លោកឈ្មោះ ឡិត ហ្នឹង វាមានអាយុតិចជាងលោក៤ឆ្នាំ មានន័យថាកាលណោះគឺ បើមិនអាយុ៣ឆ្នាំ ឬក៏៤ឆ្នាំ ប៉ុណ្ណោះ ។ អ៊ីចឹងស្ថានភាពនៃកុមារដែលតូចនេះ របៀបនេះគឺឃើញថា មានការទាមទារឲ្យមានការថែរក្សាយកចិត្តទុកដាក់ពីមនុស្សចាស់ពីឪពុកម្តាយ ប៉ុន្តែស្ថានភាពដែលលោកបានលើកឡើងអំមិញ គឺទាំងប្រាំនាក់ មានទាំងក្មេងតូចជាងនេះទៀតផងតាមលោកនិយាយ ប៉ុន្តែស្ថានភាពនៃការរស់នៅរបៀបនេះ វាជាការងារមួយដែលអង្គជំនុំជម្រះចង់ដឹងណាស់ ព្រោះតើស្ថានភាពពិតវាយ៉ាងដូចម្តេច? អ៊ីចឹង អាតូចៗវារស់នៅយ៉ាងម៉េចទៅ? វាដេក រស់នៅយ៉ាងម៉េចទៅជាមួយនឹងលោកពេលនោះ?

**ឆ៖** បាទ, ខ្ញុំអត់បានចាំពេលវេលាវាយូរប៉ុន្មាន ឬក៏ឆាប់ប៉ុន្មាន ប៉ុន្តែបើតាមខ្ញុំយល់ថា វាមិនយូរពេកដែរទេ ដោយសារពួកខ្ញុំនៅខាងក្រោយនោះ មានមូសមានអីខាំ។ ហើយបើសិនណាជាខ្ញុំនៅយូរប្រហែលជាមិនរស់ទេ ។ ប៉ុន្តែ ខ្ញុំគិតថាវាមិនយូរប៉ុន្មានទេក្នុងរយៈពេលនៅខាងក្រោយរោងជាង ប្រហែលជាអត់យូរប៉ុន្មានទេ ។ ហើយខ្ញុំ--

[១១:០៤:០៦]

**ស៖** ហើយរបបហូបចុកដែលគេផ្តល់ឲ្យលោកហូបហ្នឹង ទាំងកុមារប្អូននាក់ផ្សេងទៀតហ្នឹង រួមទាំងប្អូនរបស់លោកផង គេឲ្យជាហូរហែរជារៀងរាល់ថ្ងៃរហូតអ៊ីចឹងទេ ឬក៏មានអាក់ខានដែរ?

**ឆ៖** បាទ, គេឲ្យរហូតដែរ ជួនកាលអាក់ខានដោយសារពេលថ្ងៃគេរើចូលមកបែកដោយសារបបរហ្នឹង វាដុះផ្សិតស្អុយ ។ ខ្ញុំបង្ខំហូបបបរស្អុយហ្នឹង ប៉ុន្តែប្អូនខ្ញុំហូបអត់កើតទេ បានតែខ្ញុំម្នាក់ឯង ។

**ស៖** ហើយលោកក្រោយមកទៀត លោកជួបព្រឹត្តការណ៍យ៉ាងម៉េចទៀតចំពោះរូបលោកក្រោយពេលដែលមានការ-- ថ្ងៃរំដោះ? ថ្ងៃនោះតើមានព្រឹត្តកាណ៍យ៉ាងម៉េចចំពោះលោកដែរទេ នៅក្នុងអំឡុងពេលដែលលោករស់នៅក្នុងមន្ទីរស-២១ នោះ?

**ឆ៖** បាទ, ខ្ញុំសូមម្តងទៀត ដែលស្តាប់អត់ច្បាស់ដោយសំណួរពិបាកយល់ពេក ។

**ស៖** តើលោកមានបានជួបនូវព្រឹត្តការណ៍ ឬហេតុការណ៍អីផ្សេងទៀតទេក្រោយពីពេលពួកកងកម្លាំងខ្មែរក្រហមនៅទីនោះគេចាកចេញអស់ទៅ ហើយនៅសល់តែលោក និងក្មេងៗប្អូននាក់ទៀត ដែលលោកអះអាងថា ស៊ីបបរស្អុយ ស៊ីបបរផ្សិតអម្បាញ់មិញនេះ ។ បបរផ្អូមនេះ សួរថា តើលោកមានជួបនូវបញ្ហាអ្វីផ្សេងទៀតដែរទេ?

**ឆ៖** ខ្ញុំសង្កេតឃើញរាល់ដងធម្មតា។ ដល់ពេលថ្ងៃនុ៎ង ហាក់បីដូចជានៅក្នុងគុកទួលស្លែងហាក់ដូចជាមានការប្រញាប់ប្រញាល់ ហើយទ្វារគុកមុខខាងក្រោយត្រូវចំហ ហើយខ្ញុំហ្នឹងនៅខាងក្រោយហ្នឹង ចេះមានបារម្ភចេះរង់ចាំមើលម្ដាយ ។ ហើយចំពោះបបរដែលដុះផ្សិតហូបហ្នឹង វាហូបទៅគ្រាន់ចេះតែហូបទៅ វាដូចជាជូរល្វីង ធ្វើឲ្យខ្ញុំចុកពោះម្ដងម្កាលដែរ ។ ប៉ុន្តែចេះតែទ្រាំហូបទៅ ។

**ស៖** ពេលណាទើបលោកជួបមនុស្សទៀត ក្រោយពេលពួកអ្នកនៅក្នុងមន្ទីរស-២១ រត់ចាកចេញអស់ទៅ តើលោកពេលណាទើបលោកមានជួបមនុស្សដទៃទៀត?

**ឆ៖** ទាល់តែពេលក្នុងបរិវេណគុកទាំងហ្នឹងស្ងាត់ជ្រងំអ៊ីចឹង ខ្ញុំឮសូរគ្រាប់ផ្លោងចូលមក គ្រាប់ផ្លោងលាន់ក្ដាំងៗអ៊ីចឹងមក ហើយខ្ញុំបានឃើញទ័ពស្លៀកពាក់ខោអាវវៀតណាមហ្នឹង សម្រាប់កងទ័ពរណសិរ្សហ្នឹង ម្នាក់ចេះនិយាយខ្មែរ ម្នាក់អត់ចេះខ្មែរទេ វៀតណាមសុទ្ធ ។ ហើយមើលទៅមុខមាត់មិនមែនខ្មែរទេ ។ ហើយ *(ឮមិនច្បាស់)* សួរខ្ញុំថា អ្នកណាកូនអ្នកណាគេ? ហើយខ្ញុំវាក់អើដែរ គ្រាន់មកដល់ ខ្ញុំអត់ដឹងផង ដឹងមកពីណាទេស្រាប់តែមកនៅឈរចំពោះមុខខ្ញុំ ។ ហើយវាក់អើ ខ្ញុំរករត់ទៅណាអត់រួចដែរ ហើយសួរខ្ញុំអ៊ីចឹង ខ្ញុំថាខ្ញុំមិនមែនកូន ប៉ុល ពត ទេ ។ ខ្ញុំមានឪពុកម្ដាយផ្សេង ឈ្មោះផ្សេងមែនអ៊ីចឹងទេ ។

[១១:០៧:៣៩]

**ស៖** បន្ទាប់ពីបានជួបមនុស្សហ្នឹងហើយ មានរឿងហេតុម៉េចទៀតកើតឡើងចំពោះលោកទៅ? ហើយជួបហ្នឹងគឺប្រហែលជាម៉ោងប៉ុន្មាន?

**ឆ៖** បាទ, ដោយសារមានគ្រាប់ផ្លោងលាន់ខ្លាំងៗ ខ្ញុំមានការភ័យ សួរអារឿងចាំថ្ងៃម៉ោងប៉ុន្មានអត់ដឹងទេ ប៉ុន្តែ ដឹងតែពេលថ្ងៃ ហើយគេសួរខ្ញុំថា អ្នកឯងហ្នឹងកូន ប៉ុល ពត? ខ្ញុំថាមិនមែនទេ ខ្ញុំមានឪពុកម្ដាយផ្សេង ។ ចុះឪពុកអ្នកឯងឈ្មោះអី? ខ្ញុំប្រាប់ថា ឪពុកខ្ញុំឈ្មោះ តាចិនៗ ចុះម្ដាយ? ខ្ញុំថាម្ដាយខ្ញុំឈ្មោះ យ៉ូវ ។

**ស៖** ហើយយ៉ាងម៉េចទៀត ពេលអ្នកដែលមកជួបលោកហ្នឹង តើគេប្រព្រឹត្តចំពោះលោកយ៉ាងម៉េចទៀត?

**ឆ៖** បាទ, ក្រោយមកគេឃើញពួកខ្ញុំអត់អាហារច្រើនថ្ងៃមកហើយ ដោយបបរនោះហូបលែងកើតហើយ ដុះផ្សិតច្រើនពេកនៅក្នុងខ្ទះហ្នឹង ខ្ទះនៅក្បែរទ្រុងជ្រូក ។ ហើយទាល់ពេលហ្នឹង បានគេដាំបាយឲ្យខ្ញុំហូប ហើយខ្ញុំអត់ដឹងថាគេបានអង្ករបានពីណាទេ ហើយមានទា មានទាមានអីនៅខាងក្រោយ

គុកហ្នឹង គេបានវ៉ៃទាហ្នឹងមួយធ្វើឲ្យពួកខ្ញុំហូបហ្នឹង ។

**ស៖** ហើយក្រោយពេលហូបរួចម៉េចទៀត?

**ឆ៖** បាទ, ទាល់តែពេលពួកខ្ញុំហូបហើយអ៊ីចឹងទៅ ប្អូនៗខ្ញុំអាមួយដើរបានហ្នឹងហូបហើយ ។ ហើយមួយទៀតដើរបានហូបហើយ តែអាពីរនាក់ដែលនៅដេកហ្នឹងលើគ្រែ លើកំណាត់កន្ទបអីអស់ហ្នឹង វាចាប់ផ្ដើមហូបអីលែងកើត យើងបញ្ចុកទឹកឲ្យវាក៏ហូបអត់កើតដែរ ។ បើអាមួយទៀត វាជិតដាច់ខ្យល់ ដោយមានស្រមោចចូលត្រចៀក ចូលច្រមុះវា ខ្ញុំយកទឹកជូតឲ្យហើយនៅតែមានស្រមោចវារកាត់ខ្លួនវាទៅមកៗទៀត ។

**ស៖** ចុះអ្នកដែលមកជួបលោក ហើយនិងបានរៀបចំ លោកថាដាំបាយ ថាមានការធ្វើទាមួយឲ្យធ្វើជាមួយហូបឲ្យហូបផងនោះ តើគាត់នៅទីនោះជាមួយក្នុងនោះ យប់ក្រោយពេលរៀបចំដាំបាយនិងធ្វើម្ហូបឲ្យពួកលោក និងក្មេងៗនៅទីនោះហូបរួច? តើគាត់នៅជាមួយទេ?

**ឆ៖** បាទ, គាត់បន្ទាប់ពីធ្វើហើយ បាទពួកគាត់ក៏ចេញទៅបាត់ទៅ ដោយចេញដោយលឿនបំផុតដោយអត់មានប្រាប់ពួកខ្ញុំទេ ដោយគាត់ចេញទៅវីងបណ្ដោយ ។ ហើយអាមួយដែលក្មេងមួយដែលស្រមោចវារហ្នឹងក៏ចាប់ផ្ដើមខ្លាំងមែនទែន ហើយជិតស្លាប់ហើយ ។ ហើយពេលនុំងបានកងទ័ពវៀត-ណាមគេចូលមក ។ បន្ទាប់មក រំលងមួយយប់ព្រឹកឡើងហ្នឹងបានកងទ័ពវៀតណាម និងកងទ័ពខ្មែរយើងនឹងចូលទៅយកទៅយកពួកខ្ញុំ ចេញពីទួលស្លែងហ្នឹងមក ហើយបាទ ។

**ស៖** អ៊ីចឹង ពេញមួយយប់ដែលលោកក្រោយពេលហូបបាយរួចហ្នឹង គឺលោករស់នៅក្នុងស្ថាន-ភាពតែក្មេងៗប្រាំនាក់ទេ ។ ចំពោះអ្នកដែលទៅជួបលោក ហើយបានរៀបចំដាំបាយ ហើយនិងធ្វើម្ហូបឲ្យលោក ក្រោយពីហូបរួចនុំងគឺចេញបាត់ទៅ ។ ព្រឹកឡើងបានឃើញកងកម្លាំងហ្នឹងគេមកម្ដងទៀតហើយមកជួបពួកលោក និងក្មេងៗទាំងអស់ម្ដងទៀត អ៊ីចឹងមែនទេ?

**ឆ៖** បាទ, មែន ។ ដោយពួកគេយកខ្ញុំចេញពីទួលស្លែងទៅអាមួយដែលថា ខ្ញុំឃើខ្លាំងក៏ពេលវៀតណាមចូលពីព្រឹកឡើងបាន-- អាអូនមួយហ្នឹងបានស្លាប់ហើយ ។ ដោយស្រមោចវារចូលត្រចៀកច្រមុះអស់ហើយ ហើយស្លាប់បាត់ហើយ ។ ហើយអាពីរនាក់ អាម្នាក់ទៀតហ្នឹង អាពីរនាក់ទៀតវាចាប់ផ្ដើមទុនខ្សោយដែរហើយ ។ ហើយគេបានយកខ្ញុំឡើងមកចេញពីក្នុងហ្នឹងមកបាទ ។ ចេញមកដល់មន្ទីរពេទ្យបានខ្ញុំនៅចាំថា មន្ទីរពេទ្យក្រុងយើងហ្នឹង ។

[១១:១១:៤៩]

**ស៖** អ៊ីចឹង ទាំងអស់ប្រាំនាក់ទាំងលោក ដល់ពេលក្មេងមួយនោះត្រូវឈឺហើយស្រមោចរោម អ៊ីចឹងក៏ស្លាប់ទៅនៅយប់នុ៎ង ពេលដែលកងទ័ពវៀតណាមចូលទៅដល់គឺបានកុមារម្នាក់នុ៎ងបានស្លាប់ហើយ ហើយម្នាក់ទៀតហ្នឹងក៏មានកម្លាំងទន់ខ្សោយដែរ អ៊ីចឹងមែនទេ?

**ផ៖** បាទ,មែន ។ ក្រោយពីអាមួយនោះស្លាប់ទៅយកខ្ញុំទៅដល់មន្ទីរពេទ្យក្រុង សម្ពពក្រុងយើងរាល់ថ្ងៃនេះ ខ្ញុំចាំបាន ។ ពេទ្យសម្ពពក្រុងហ្នឹងបានគេត្រូវព្យួរសេរ៉ូម អាតូចមួយទៀត ហើយប្អូនខ្ញុំអាបន្ទាប់ខ្ញុំនុ៎ង ។ ព្យួរសេរ៉ូមមានតែខ្ញុំមួយទេ មានកម្លាំងអាចដើរបានវិញ ។

**ស៖** លោកគិតមើល! ក្មេងទាំងប្រាំហ្នឹងគឺទីមួយ គឺលោកមែនទេ? ទីពីរ ប្អូនរបស់លោកឈ្មោះឡឹត ឈ្មោះ នង ចាន់លី ហៅ ឡិត ហើយនិងទីបីក្មេងហ្នឹងប្រុស ឬស្រី ហើយអាយុប្រហែលប៉ុន្មានទៅ?

**ផ៖** ខ្ញុំនៅចាំបន្ទាប់ក្មេងស្លាប់មួយទៅនៅសល់បួននាក់ ។ ខ្ញុំបងគេ បន្ទាប់មកអាប្អូនខ្ញុំ ហើយបន្ទាប់មួយទៀតក្មេងស្រី ប៉ុន្តែ អាយុប្អូនៗខ្ញុំទៀត ខ្ទង់ប្រហែលអាយុប្រហែលជាបីឆ្នាំអី ។ ប៉ុន្តែវាដើរបានហើយនិយាយស្តាប់អី-- វានិយាយស្តាប់បាន ។

**ស៖** អ៎មិញបានបីនាក់ហើយ នៅម្នាក់ទៀត?

**ផ៖** មើល! ខ្ញុំសូមបញ្ជាក់ម្តងទៀតថា មួយខ្ញុំ ពីរបន្ទាប់មកប្អូនខ្ញុំ បន្ទាប់ទីបីហ្នឹងអាប្អូនស្រី វាអាចដើរបាននឹងប្អូនខ្ញុំមួយឆ្នាំ ប្អូនប្រុសនោះវាប្រហែលជាបីឆ្នាំ ហើយអាបន្ទាប់មួយទៀតប្អូនរបស់កូនស្រីហ្នឹង របស់ប្អូនវាហ្នឹង ពីរនាក់បងប្អូនវាហ្នឹងមួយទៀតតូចប្រុសបីហ្នឹងដែរ អាហ្នឹងចាប់ផ្តើមខ្សោយដែរអត់មានឈ្មោះទេពីរនាក់ហ្នឹង ។ ខ្ញុំអត់បានស្គាល់ឈ្មោះវាទេ អត់មានឈ្មោះទេ ។

**ស៖** ចុះអាក្មេងដែលវាថាស្លាប់នោះ? វាមានអាយុប្រហែលប៉ុន្មានទៅ? ប្រហែលៗប៉ុន្មានឆ្នាំ?

[១១:១៤:០២]

**ផ៖** បាទ, អានុ៎ង ប្រហែលជានៅក្មេង វានៅបី-- ម្តាយវានៅបីអ៊ឹមដោះ ប្រហែលអត់ដឹងប្រហែល ខ្ញុំអត់ដឹងឆ្នាំប៉ុន្មានទេ ប៉ុន្តែគ្រាន់ថាវាក្មេងនៅអ៊ឹមអ៊ីចឹងលោក ។

**ស៖** មនុស្សដែលថាមកទទួលយកហ្នឹង លោកថា អះអាងថាព្រឹកឡើង សំណួរសួរថា តើមានគ្នាប៉ុន្មាននាក់? ហើយមនុស្សដែលមកហ្នឹងមានជាមនុស្សប្រុស ឬមនុស្សស្រី? ឬក៏មានទាំងប្រុសទាំងស្រី? ហើយបើមានទាំងប្រុសទាំងស្រី តើប្រុសប៉ុន្មាន? ស្រីប៉ុន្មាន?

**ផ៖** បាទៗ, កងទ័ពដែលមកចូលយកខ្ញុំហ្នឹងមានគ្នាច្រើនណាស់ខ្ញុំអត់បានចាំទេ ។ ហើយខ្ញុំឃើញមនុស្សច្រើនខ្ញុំអត់មានអរទេ ។ ខ្ញុំភ័យខ្លាចនឹងគេយកខ្ញុំទៅណាទៀត តែខ្ញុំនៅចាំនឹកឃើញថា

បើសិនជាខ្ញុំនៅទីនេះម្តាយអាចរកខ្ញុំឃើញ ។ បើខ្ញុំចេញទៅជាមួយពួកគេ គេប្រហែលជាយកខ្ញុំទៅណាទៀត ខ្ញុំរកម្តាយខ្ញុំអត់ឃើញទេ ។ ខ្ញុំអត់ចង់ចេញទៅពីហ្នឹងទេ ។

**ស៖** ចុះអ្នកដែលមកជួបលោកដំបូង លើកដំបូងហ្នឹងពីរនាក់ដែលថា មកដាំបាយឲ្យហូបនុំង ប៉ុន្មាននាក់? មានប៉ុន្មាននាក់? ហើយស្លៀកពាក់ឯកសណ្ឋានយ៉ាងម៉េច? ហើយមនុស្សប្រុស ឬក៏មនុស្សស្រី?

**ឆ៖** ខ្ញុំនៅចាំបានពីរនាក់នុំង ប្រុសទាំងពីរនាក់ ។ ម្នាក់ចេះនិយាយខ្មែរ ម្នាក់អត់ចេះនិយាយខ្មែរសុទ្ធ ។ ហើយស្លៀកពាក់ជាទាហាន ស្លៀកពាក់ជាពណ៌ត្រីអ៊ីហ្នឹង បានខ្ញុំនៅចាំ ។ ឥឡូវនេះ ខ្ញុំដឹងថាវាពណ៌គគី ពណ៌ប៉ៃតងចាស់ ។

**ស៖** លោកនិយាយចំណុចនេះបន្តិច ដូចជាវាមានបញ្ហាមួយចង់ច្បាស់ថា នៅថ្ងៃដែលច្របូកច្របល់ ។ ច្របូកច្របល់ហ្នឹង ប្រហែលជានៅក្នុងមុនថ្ងៃរំដោះ ៧ មករា ឬក៏មុនពេលដែលលោកជួបមនុស្សពីរនាក់ដែលបានទៅជួប ហើយដើមបាយឲ្យហូបហ្នឹង សួរថា ស្ថានភាពនៃរស់នៅរបស់លោកយ៉ាងម៉េចទៅ? បានជាលោកអត់មានការចាកចេញពីទីនោះ ហើយតើលោករស់ទីណាបានជាអាចគេចផុតពីការកាប់សម្លាប់របស់ឆ្មាំគុកទួលស្លែងនោះ?

**ឆ៖** ខ្ញុំអត់ដឹងថា ខ្ញុំគេចទៅណាទេ ដោយសារខ្ញុំនៅខាងក្រោយហ្នឹង ។ នៅពេលចលាចលស្ត្រីចំណាស់ម្នាក់ហ្នឹងហៅខ្ញុំចេញទៅខាងក្រៅគុក ហើយរត់ទៅជាមួយគាត់ ប៉ុន្តែ ខ្ញុំនៅនឹកឃើញថាម្តាយខ្ញុំសម្លឹងខ្ញុំពីបន្ទប់ទីពីរមក ពីលើអគារជាន់ទីពីរហ្នឹងឃើញខ្ញុំនៅខាងក្រោយហ្នឹង ។ បើសិនណាជាម្តាយខ្ញុំហ្នឹងគាត់ចេញមករក គឺមករកខ្ញុំហ្នឹងនៅកន្លែងខាងក្រោយហ្នឹងឃើញ ។ ហើយខ្ញុំអត់មានបានថា គេចទៅពួនកន្លែងណាខ្លះទេ ប៉ុន្តែ បានពេលស្ត្រីហ្នឹងព្យាយាមហៅខ្ញុំចេញទៅហ្នឹង ខ្ញុំបានដើរទៅខាងគំនរទូបាក់បែក ហើយមានគំនរខោអាវចាស់ៗហ្នឹង ខ្ញុំពួននៅកៀនហ្នឹង ។

[១១:១៧:២៣]

**ស៖** លោកនៅកៀននុំង កន្លែងកៀននុំងប៉ុន្មាននាក់ទៅ? ឬក៏ទៅទាំងអស់គ្នា ទាំងក្មេងៗបួនប្រាំនាក់ដែលនៅទាំងអស់គ្នាហ្នឹង ឬក៏ទៅតែលោក? ឬក៏ក្មេងប៉ុន្មាននាក់ទៅទីនោះ?

**ឆ៖** ខ្ញុំរត់មកពួនខាងក្រោយទូហ្នឹង មានគំនរអាវចាស់ៗហ្នឹងមកពួនក្បែរហ្នឹងដូចខ្ញុំរត់មកតែបីនាក់ទេ តែអ្នកដើរបានទេ អាអ្នកតូចៗអាមួយៗឈឺខ្លាំងមានស្រមោចរោមហ្នឹង ហើយនិងអាមួយទៀតដែលវាកំពុងចាប់ផ្តើមដង្ហក់ហ្នឹង ខ្ញុំអត់បានយកវា គ្រាន់តែទាញកំណាត់គ្របវាហើយខ្ញុំក៏រត់មកក្បែរទូ

ហ្នឹង ហើយដឹកដៃប្អូនខ្ញុំមកពួនខាងក្រោយទូ ហើយមានគំនរអាចាស់ៗហ្នឹង គំនរទូបាក់បែងហ្នឹង ។

**ស៖** ពីថ្ងៃដែល-- លោក នង ចាន់ផល អាចបន្តទៀតបានទេ ឬក៏សម្រាកសិន?

**ផ៖** បាទ, ខ្ញុំសូមសម្រាកសិន ដោយសារសំណួររបស់លោកធ្វើឱ្យខ្ញុំរកនឹកអត់ឃើញ។ ទីមួយ អ្វីដែលខ្ញុំនឹកឃើញ បានជាខ្ញុំនិយាយ ខ្ញុំអត់នឹកឃើញខ្ញុំអត់និយាយ ខ្ញុំឃើញ និយាយអ្វីតែខ្ញុំឃើញនឹងភ្នែក។

**ស៖** ជាការត្រឹមត្រូវណាស់ ព្រោះអ្វីដែលលោកមិនដឹងមិនចាំ គឺលោកមិនអាចនិយាយបានទេ ។ និយាយក្នុងកម្រិតចាំ ហើយកម្រិតដែលជារឿងហេតុពិតដែលកើតមានឡើង ហើយដោយសារបញ្ហានេះវាយូរឆ្នាំ ។ សាមសិបឆ្នាំកន្លងមកហើយ ហើយបញ្ហាទីពីរ កាលនោះគឺលោកនៅក្មេងនៅក្មេងវ័យ៨ឆ្នាំ ឬក៏៧ឆ្នាំ អ៊ីចឹងហើយបញ្ហាគឺអង្គជំនុំជម្រះមិនបណ្តេញក្នុងការតម្រូវថា លោកត្រូវតែឆ្លើយនូវសំណួរហ្នឹងរបស់អង្គជំនុំជម្រះទេ គឺសួរទៅតាមលំហូរនៃរឿងហេតុដែលកើតមានចំពោះលោក តាមការសិក្សាស្រាវជ្រាវលើពាក្យបណ្តឹងរបស់លោក ក៏ដូចជាសំណុំរឿងដែលមានខ្លះៗនៅក្នុងឯកសារនៅក្នុងឯកសារសំណុំរឿងដែលវាមានព័ត៌មាន ។

អ៊ីចឹងយើងផ្អែកលើមូលដ្ឋាននេះ ដើម្បីធ្វើការសួរប៉ុណ្ណោះ ។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះមានប្រយ័ត្នប្រយែងក្នុងការនិយាយហ្នឹង គឺឱ្យមានទម្រង់មួយគឺ អាស្រ័យទៅលើលោកលទ្ធភាពក្នុងការផ្តល់ព័ត៌មានដែលលោកបានជួបប្រទះនៅក្នុងអំឡុងពេលនោះ ។

ឥឡូវលោកត្រូវការសម្រាកមែនទេ?

[១១:២១:១៦]

**ផ៖** បាទ,មែនបាទ សូមសម្រាក ។

**ស៖** ឥឡូវសម្រាកដប់មីនុតសិនចុះ អង្គជំនុំជម្រះប្រកាសសម្រាក ដប់មីនុត ដើម្បីឱ្យសាក្សីរូបនេះធ្វើការសម្របសម្រួលអារម្មណ៍របស់គាត់ឱ្យបានល្អប្រសើរសិន សឹមយើងចូល ហើយបន្តដំណើរសវនាការតទៅទៀត ។

*[សវនាការសម្រាកពីម៉ោង១១:២១នាទី ដល់ម៉ោង ១១:៣៥នាទី]*

**សួរដោយប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

**ស៖** លោក នង ចាន់ផល លោករកនឹកមើលថា ចាប់ពីពេលដែលមានការជ្រួលច្របល់ ហើយអ៊ំស្រីម្នាក់ដែលថាបបួលលោកចេញពីក្រៅ ទៅក្រៅគុកនោះ ហើយលោកអត់ទៅដោយសារលោករង់ចាំម្ដាយរហូតដល់មានមនុស្សពីរ អំមិញដែលលោកនិយាយថា មានម្នាក់និយាយខ្មែរ ហើយម្នាក់ទៀតនិយាយ អត់ចេះនិយាយខ្មែរទេនោះ មកជួបលោក ហើយដាំបាយឲ្យលោកហូបហ្នឹង វាអត់រយៈពេលប៉ុន្មានដែរ ឃ្លាតគ្នារវាងថ្ងៃដែលគេនាំលោកចេញ ហើយហ្នឹងថ្ងៃដែលមនុស្សពីរនាក់មកជួបលោកនោះ?

**ឆ៖** សូមជម្រាបបាទ! ខ្ញុំពេលស្ត្រីនោះហៅខ្ញុំចេញហ្នឹង នៅពេលហ្នឹងទ្វារគុកខាងមុខខាងក្រោយចំហ ។ ដល់ពេលខ្ញុំអត់ព្រមទៅ គាត់មានដូចគាត់មានការដូចគាត់ធ្វើហៅជាបង្ខំអ៊ីចឹង ។ ដល់ខ្ញុំអត់ព្រមទៅ ខ្ញុំសុខចិត្តមកខាងក្រោយកន្លែងទូរបាក់បែក ហើយនិងមានគំនរខោអាវហ្នឹងពួនខាងហ្នឹង ហើយក៏គាត់ ស្ត្រីចំណាស់ហ្នឹងក៏បានចាកចេញទៅបាត់ទៅ ក្រោយមកហ្នឹងខ្ញុំអត់ចាំពេលវេលា ប៉ុន្តែស្រាប់តែ-- អត់ដឹងថា ថ្ងៃស្អែក ឬថ្ងៃខានស្អែកទេ គ្រាន់ថាពេលនុំងមានកងទ័ពពីរនាក់ហ្នឹងមក ហើយខ្ញុំអត់ដឹងថាគេចេញមកពីកន្លែងណាមក ។ ពួកខ្ញុំមកអង្គុយខាងក្រោយហ្នឹងកំពុងភ័យនឹងគ្រាប់ផ្លោងផងអីផង ស្រាប់តែលេចទាហានពីរនាក់ហ្នឹងបុរសពីរនាក់ហ្នឹងមកហ្នឹង គាត់សួរខ្ញុំថា អ៊ីចឹងថា ដូចខ្ញុំជម្រាបលោកខាងលើអំមិញអ៊ីចឹង ។

**ស៖** ចន្លោះពីថ្ងៃដែលស្ត្រីម្នាក់បបួលលោកចេញ ហើយលោកអត់ចេញ លោកថានៅរង់ចាំម្ដាយក្រែងលោម្ដាយមករកមិនឃើញនោះ រហូតដល់មានកងទ័ពពីរនាក់ថា មកជួបលោក ហើយដាំបាយឲ្យហូប ហូបរួចត្រឡប់ទៅវិញហ្នឹង ចម្លោះពេលហ្នឹងលោក និងក្មេងៗផ្សេងទៀតហ្នឹងដែលនៅជាមួយលោកហ្នឹងបានអីហូប?

**ឆ៖** បាទ, សូមជម្រាបទៅលើប្រធាន សុំសំណួរខ្លីៗបន្តិចងាយស្រួលខ្ញុំឆ្លើយ ដល់វែងៗពេកខ្ញុំពិបាកឆ្លើយ អត់ដឹងថាចាប់ពីណាទៅមុន ។ សុំម្ដងទៀត ។

**ស៖** នៅក្នុងចន្លោះពេលដែលមានការហ្វឹកវរ ហើយមនុស្សចាកចេញគុកទួលស្លែងអស់ រហូតដល់មានមនុស្សពីរនាក់ដែលថាជាកងទ័ពមកដាំបាយឲ្យលោកហូប ចន្លោះហ្នឹង តើលោកនិងក្មេងៗទាំងអស់ហ្នឹងបានរបស់អីហូប?

[១១:៣៨:២៣]

**ឆ៖** បាទ, នៅពេលចន្លោះហ្នឹង បបរដែលនៅក្នុងខ្ទះខាងក្រៅនៅកន្លះខ្ទះហ្នឹងមិនច្រើនទេ នៅតិចដែរ ហើយវាមានជាតិធំក្លិនផ្អូម ហើយស្អុយហើយ ហូបបានតែខ្ញុំទេ ប៉ុន្តែហូបមិនបានច្រើនទេ ដោយ

សារវាផ្ទុរផង ហើយពិបាកហូប ហើយមានក្លិនទៀត ។ ហូបបានតែខ្ញុំទេ ប្អូនៗអត់បានហូបទេបាទ ហូបអត់កើត ។

**ស៖** ពេលកងទ័ពចូលមកយកលោក ហើយនិងក្មេងៗដែលនៅរស់ពីរបីនាក់ទៀត មានទាំងប្អូនលោកផងហ្នឹង ចាកចេញទៅតាមផ្លូវណា ចេញពីគុកទួលស្លែងហ្នឹងទៅតាមផ្លូវខាងណា? ហើយតាមច្រកខាងណា?

**ឆ៖** បាទ, ពេលកងទ័ព គេមកយកខ្ញុំហ្នឹង ចេញទៅពីទ្វារខាងក្រោយទៅទ្វារខាងមុខ ប៉ុន្តែបត់ទៅខាងឆ្វេង ឬខាងស្តាំខ្ញុំអត់បានចាំ ។

**ស៖** ចេញទៅទ្វារខាងមុខ បានន័យថាទ្វារខាងកើត ឬក៏ទ្វារខាងលិច?

**ឆ៖** បាទ បើខ្ញុំនៅចាំទ្វារខាងមុខនោះ គឺទ្វារខាងកើតបាទ ។

**ស៖** ពេលកងទ័ពនាំលោក និងក្មេងៗចាកចេញទៅហ្នឹង មានបាននាំដើរលោកដើរមើលនៅតាមអគារផ្សេងៗដែរទេ ឬក៏នាំលោកធ្វើដំណើរតាមដីហ្នឹង ពីកន្លែងដែលលោកនិងក្មេងៗរស់នៅខាងក្រោយហ្នឹង ត្រង់ចេញមកច្រក តាមច្រកទ្វារខាងកើតត្រង់តែម្តង?

[១១:៤០:២៣]

**ឆ៖** បាទ, ពេលនាំចេញមកហ្នឹងអត់មានដើរសួរទៅកន្លែងណាៗទៀតទេ ដោយសារពួកខ្ញុំក្មេងៗហ្នឹងមានសភាពដូចម្នាក់អាតូចមួយទៀតចង់ស្លាប់ហើយ ហើយអាបងអាតូចហ្នឹងវា-- ក្មេងស្រីមួយបងអាតូចវាជិត-- ដកដង្ហក់ជិតដាច់ខ្យល់ដែរទៅហើយ ដោយអត់អាហារប៉ុន្មានថ្ងៃមកហើយ ក៏គាត់--ពួកគេក៏ប្រញាប់យកពួកខ្ញុំទៅមន្ទីរមន្ទីរសម្ភពក្រុងបច្ចុប្បន្នហ្នឹង ។

**ស៖** នៅថ្ងៃនោះលោកមានបានពិនិត្យមើលទិដ្ឋភាពផ្សេងទៀតទេនៅក្នុងមន្ទីរនោះ នៅក្នុងកន្លែងនោះ តើលោកបានឃើញអ្វីទៀតទេ?

**ឆ៖** បាទ, ខ្ញុំពិនិត្យឃើញទៅថា វាមានសភាពស្ងប់ស្ងាត់ ប៉ុន្តែឮសូរគ្រាប់ផ្ទោងចូលមកនោះខ្លាំង ។ ខ្ញុំអត់ហ៊ានចូលជ្រកក្រោមផ្ទះថ្មទេ ដោយខ្លាចផ្ទះថ្មហ្នឹងបាក់សង្កត់ ខ្ញុំនៅតែរត់មកកន្លែងរោងជាងខាងកើតដដែល ។

**ស៖** លោកមានឃើញមនុស្សស្លាប់នៅទីនោះទេ ក្រោយពេលដែលស្ងប់ស្ងាត់មនុស្សចាកចេញអស់ទៅ នៅតែលោកជាមួយនិងក្មេងៗតូចហ្នឹង តើលោកមានបានឃើញមនុស្សស្លាប់នៅទីនោះទេ? ហៅខ្មោច យើងហៅខ្មោច មនុស្សដែលស្លាប់ហើយហ្នឹង ហៅខ្មោច នៅទីនោះដែរឬទេ?

**ឆ៖** បាទ,ពេលស្ត្រីម្នាក់ដែលហៅខ្ញុំទៅហ្នឹង គាត់បានទៅស្ងាត់បាត់យូរហើយ ដល់ពេលស្ងាត់អ៊ីចឹងខ្ញុំឃើញទ្វារចំហមុខក្រោយ ខ្ញុំរត់ទៅរកម្ដាយខ្ញុំនៅលើអគារទីបីហ្នឹង គេចំហទ្វារ ។ ខ្ញុំឡើងកាំជណ្ដើរទៅដល់ជាន់ទីពីរ បន្ទប់ទីពីរហ្នឹង បានឃើញទ្វារហ្នឹងចំហរ ហើយអត់ឃើញម្ដាយខ្ញុំទេ ហើយខ្ញុំរត់មករកមកតាមចេញពីអគារទីបី រត់ពីអាទីពីរ មកទីមួយ ។ ហើយដល់ពេលឃើញបន្ទប់មួយនោះ ហើយឃើញមានមនុស្សដេកនៅខាងលើហ្នឹង ហើយខ្ញុំមិនដឹងថាមនុស្សហ្នឹងស្លាប់ ឬក៏រស់ទេ ឃើញដូចអត់ទាន់មានហើមអីដូចនៅក្នុងរូបថតទេ ។ ឃើញនៅជាប់ខ្នោះហ្នឹងហើយ ឃើញសម្រាកហ្នឹង ដែលឃើញដេកនៅលើគ្រែហ្នឹង ។ ខ្ញុំឃើញអ៊ីចឹងភ័យ ហើយវាមានឈាមមានអី ខ្ញុំឃើញក៏រត់បកមករកកន្លែងរោងជាងវិញ ដោយខ្ញុំ-- ពេលដែលខ្ញុំរត់ទៅខ្ញុំស្រែករកម្ដាយ ។ រត់ស្រែកក្នុងអគារមួយ ខ្ញុំស្រែកពីរទៅបីម៉ាត់ ហើយដល់ពេលឃើញមនុស្សជាប់ជើងនឹងច្រវាក់ដេកនៅលើគ្រែ បានខ្ញុំរត់ភ័យរត់មកខាងក្រោយរោងជាងវិញ ។

[១១:៤៣:០៥]

**ស៖** លោកមានជំនឿ ឬក៏ភស្តុតាងអីទេ ដែលថាឪពុករបស់លោកហ្នឹង បានត្រូវគេចាប់ ហើយនិងសម្លាប់នៅទួលស្លែងនេះ?

**ឆ៖** បាទ,រឿងហ្នឹងខ្ញុំអត់ចាំច្បាស់ដែរ ដោយសារគេបញ្ជូនពុកខ្ញុំមក គេប្រាប់ម្ដាយខ្ញុំថា“លោកពូបានត្រូវគេអញ្ជើញទៅភ្នំពេញហើយ” កាលនៅសហករណ៍អារឈើនុំង ហើយមកភ្នំពេញហើយក្រោយមកបានគេយកម្ដាយខ្ញុំមកទៀត ជាមួយខ្ញុំហ្នឹង ដូចខ្ញុំជម្រាបលោកប្រធានខាងលើហ្នឹង ។

**ស៖** យើងសួរនេះចង់ដឹងពីព័ត៌មានក្រោយៗទៀត ត្រង់ថា ដូចជារូបថត ដូចជាឯកសារផ្សេងៗទៀត ដែលក្រោយៗមកទៀតហ្នឹង វាមានបានបន្សល់ទុកនៅក្នុងសារមន្ទីរឯកសារហ្នឹង ថាតើវាមានបន្សល់ទុកនូវភស្តុតាងអីអ៊ីចឹងទេ ដូចជារូបថត ដែលលោកបានប្រើថា ពេលដែលចូលទៅហ្នឹងគេថតរូបម្ដាយរបស់លោក ដោយមានពាក់ស្លាកអី សរសេរអក្សរផង មានថតពីមុខផង ថតចំហៀងផង អ៊ីអ៊ីចឹង ឬក៏ឪពុករបស់លោក ដែលបានបាត់ខ្លួនទៅហ្នឹង វាមានបន្សល់អ្វីខ្លះដែលជាស្លាកស្នាមនៅក្នុងសារមន្ទីរដែរទេ ដែលលោកធំដឹងក្ដីហើយនេះ? វាមិនមែនយើងសួរក្នុងកាលៈទេសៈកាលពីលោកនៅក្មេងនោះទេ ។ លោកមានព័ត៌មានអីពីបញ្ហាហ្នឹងដែរទេ?

**ឆ៖** បាទ, ក្រោយថ្ងៃរំដោះហ្នឹង ខ្ញុំដើររកមើលរូបថតឪពុកខ្ញុំដែរ រកអត់ឃើញ រូបថតម្ដាយក៏អត់ឃើញ ទើបតែថ្មីៗស្រាវជ្រាវទៅ គេជួយរកឲ្យខ្ញុំទៅ ឃើញមានប្រវត្តិរូបពុកខ្ញុំ ឈ្មោះ នង ចិន

ហ្នឹងនៅតំបន់៣៥ អារឈើ ។ ឃើញប៉ុណ្ណឹងបាទ ប៉ុន្តែគ្មានរូបថតមួយសន្លឹកណាទេ ។

**ស៖** ត្រឡប់ក្រោយបន្តិច នៅពេលដែលលោកនិយាយថា កងទ័ព-- ព្រលឹមឡើង ក្រោយពេលឲ្យហូបបាយរួចហើយ ព្រលឹមឡើងកងទ័ពហ្នឹងបានចូលទៅជួបពួកលោក ហើយនិងបានយកក្មេងៗហ្នឹងចេញ ហើយនៅក្នុងនោះ គឺទាំងប្រាំនាក់ហ្នឹងគឺម្នាក់ដែលថា ស្រមោចរោមនោះ គឺបានស្លាប់ហើយ ។ តើកងទ័ពហ្នឹងគេចាត់ការលើកុមារដែលបានស្លាប់ហ្នឹងយ៉ាងម៉េចទៅ? ឬក៏គេគ្រាន់តែយកលោកបួននាក់-- ពួកលោកបួននាក់ចេញទេ ហើយកុមារដែលស្លាប់ហ្នឹង គឺទុកចោលនៅទីនោះ?

[១១:៤៦:១០]

**ឆ៖** បាទ, បើតាមខ្ញុំនៅចាំកងទ័ពចូលមកហ្នឹងមកយកពួកខ្ញុំ មានអ្នកខ្លះក៏រុំ-- យកកំណាត់កន្ទបកំណាត់ខោអាវចាស់ៗនៅខាងក្រោយហ្នឹង ប៉ុន្តែ ខ្ញុំមិនដឹងខោអាវជាខោអាវអ្នកណាទេ ប៉ុន្តែគ្រាន់តែឃើញខោអាវគរច្រើនក្នុងនុ៎ង ។ ហ្នឹងហើយរុំកូនក្មេងស្លាប់ហ្នឹងកប់នៅខាងក្រោយរោងជាងហ្នឹង ។ ហើយពួកខ្ញុំប៉ុន្មានក៏បានគាត់យកចេញមកខាងក្រៅគុកទៅ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រី ចៅក្រម តើមានសំណួរអ្វីសួរដល់សាក្សី អ្នកដែលរស់រានមានជីវិតពីមន្ទីរ ស-២១ រូបនេះដែរឬទេ? សូមអញ្ជើញលោកស្រីចៅក្រម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំដឹងថា ពេលវេលានោះវាយូរមកហើយ ហើយលោកនៅតូចណាស់នៅពេលនោះ ។ ហើយវាមានការពិបាកក្នុងការនិយាយទៅលើព្រឹត្តិការណ៍នោះឡើងវិញនៅថ្ងៃនេះ ប៉ុន្តែខ្ញុំចង់សូមសួរសំណួរមួយ ឬក៏ពីរប៉ុណ្ណោះទៅដល់លោក ដើម្បីឲ្យបំភ្លឺចំណុចមួយចំនួនជូនខ្ញុំ ។

**ស៖** លោកត្រូវបានគេនាំទៅពេទ្យ គឺទាហានគេនាំលោកទៅពេទ្យ ហើយលោកថាជាពេទ្យសម្ភពក្រុងនោះ គឺពេទ្យសម្រាប់បង្កើតកូននោះ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** តាមពិតមែនហើយ កាលនុ៎ងគេនាំខ្ញុំយកទៅពេទ្យនុ៎ង ប៉ុន្តែខ្ញុំមិនដឹងថាពេទ្យហ្នឹងកន្លែងណាទេ ប៉ុន្តែខ្ញុំនៅចាំបានទាល់តែពេលខ្ញុំមានសុខភាពរាងល្អហើយ ខ្ញុំមកលេងខាងមុខហ្នឹង ។ ដល់ពេលខ្ញុំមកនៅមជ្ឈមណ្ឌលកុមារកំព្រាហើយហ្នឹង បានខ្ញុំដើរទៅលេងស្តាតអូឡាំពិក ដែលគេមានប្រកួតបាល់ប្រកួតអី ខ្ញុំដើរទៅតាមនុ៎ងអី បានខ្ញុំឃើញមន្ទីរពេទ្យហ្នឹងជាមន្ទីរក្រុងមែន សម្ភពក្រុងមែន ។

**ស៖** ដូច្នេះ បន្ទាប់ពីលោកនៅពេទ្យ លោកបន្ទាប់នោះ គឺលោកត្រូវបានគេបញ្ជូនទៅនៅក្នុងកន្លែងកុមារកំព្រានៅជិតអូឡាំពិក តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ក្រោយមកហ្នឹងលោកតា កែវ ចន្ទា ហ្នឹងគាត់បានទៅសុំខ្ញុំពីកងទ័ពវៀតណាម ដោយថាទុកក្មេងនៅតាមកងទ័ពអ៊ីចឹង អត់បានរៀនសូត្រ ហើយគាត់យកមកខ្ញុំនៅជិតផ្ទះរបស់គាត់ដោយមានស្ត្រីម្នាក់ហ្នឹងមេម៉ាយទេ មានកូនពីរនាក់បានមើលពួកខ្ញុំទាំងអស់គ្នាហ្នឹង ។

[១១:៤៩:១៥]

**ស៖** ចុះប្អូនរបស់លោក តើប្អូនហ្នឹងទៅជាមួយលោកដែរឬទេ?

**ឆ៖** បាទ ប្អូនខ្ញុំនៅតូចៗអត់បានទៅជាមួយខ្ញុំទេ ត្រូវបានអ្នកគ្រូនៅក្នុង-- កាលហ្នឹងមានអ្នកមើលហ្នឹង អត់ឲ្យដើរទៅណាទេ ដើររួចតែខ្ញុំមួយ ដោយខ្ញុំធំជាងគេ ។

**ស៖** ខ្ញុំចង់និយាយបកទៅក្រោយវិញ និយាយអំពីម្តាយរបស់លោកនិងលោក ហើយនិងប្អូនពៅរបស់លោក និងស្ត្រីពីរនាក់ និងក្មេងៗផ្សេងទៀត គឺអ្នកទាំងអស់នោះត្រូវបានគេយកមកពីកន្លែងរថភ្លើងថាតើអ្នកទាំងអស់គ្នា និងលោកនោះ ត្រូវបានគេដឹកតាមឡានហ្ស៊ីប នៅពេលដែលដឹកពីស្ថានីយរថភ្លើងមក ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ,មែន ។ ដោយពេលល្ងាចនុ៎ង គេដឹកពួកខ្ញុំទាំងអស់គ្នា ទាំងស្ត្រីបីនាក់ទាំងម្តាយខ្ញុំហើយព្រមទាំងពួកខ្ញុំក្មេងៗប្រាំនាក់ទៀត បាទមកជាមួយឡានហ្ស៊ីបហ្នឹងចូលទៅ ។ ប៉ុន្តែ អ្នកដែលដឹកមកហ្នឹងខ្ញុំអត់បានចាំថា មុខដដែល ឬក៏មុខយ៉ាងណា ដឹងថា គេនាំយកខ្ញុំមកចូលទួលស្លែងហ្នឹងពេលល្ងាច ថ្ងៃរាងរសៀលខ្ទងប្រហែលជា-- ថ្ងៃរសៀលមេឃជិតលិចអីអ៊ីចឹង ខ្ញុំអត់ស្គាល់ម៉ោង ស្គាល់អីកាលនុ៎ង ។

**ស៖** ហើយលោកនិយាយថា លោកមកដល់គុកនោះ គឺប្រហែលជាព្រលប់ៗហើយ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ត្រឹមត្រូវហើយ ។

**ស៖** ថាតើលោកអាចប្រាប់ខ្ញុំដែរឬទេ ថាហេតុអ្វីបានជាលោកដឹងថានៅទីនោះជាទួលស្លែង?

**ឆ៖** បាទ, ខ្ញុំអត់ដឹងថា កន្លែងហ្នឹងជាកន្លែងទួលស្លែងទេ ដោយគេយក-- ពេលដែលកងទ័ពរណសិរ្សវៀតណាមអីហ្នឹងគេយកចេញទៅខ្ញុំ ខ្ញុំនេះខ្ញុំអត់បានដឹងទេ ។ ក្រោយមកលោកតា កែវ ចន្ទា ហ្នឹងគាត់បានយកខ្ញុំទៅផ្ទះសម្តេច ហ៊ុន សែន ដល់ខ្ញុំអត់ចេះជម្រាបសួរអ៊ីចឹង លោកសម្តេច ហ៊ុន សែន

ថា "អ្នកឯងត្រូវតែយកក្មេងៗទៅដាក់កុមារកំព្រា គេមានគ្រូមើលទៅមនុស្សរាប់រយនាក់ចេះឆ្លាតៗណាស់" ក្រោយយកខ្ញុំមកនៅកុមារកំព្រាកូលាបទីពីរ ដល់ពេលដាក់កុមារកំព្រាកូលាបទីពីរហ្នឹង ខ្ញុំវានៅក្បែរសាលាអង្គអេង បច្ចុប្បន្នសាលាអង្គអេង តាមខ្ញុំស្គាល់ ហើយសាលាហ្នឹងជាសាលាអង្គអេង គេដាក់កុមារកំព្រាកូលាបទីពីរ មជ្ឈមណ្ឌលកុមារកំព្រាកូលាបទីពីរ ។ ហើយខ្ញុំបានចេញពីកូលាបទីពីរហ្នឹងដើរលេងម្តងម្កាល ដើរទៅ ខ្ញុំដើរតាមផ្លូវហ្នឹង ស្រាប់តែខ្ញុំឃើញរបងហ្នឹងជារបងគុកទួលស្លែងហ្នឹង ប៉ុន្តែ ខ្ញុំអត់ដឹងថា ទួលស្លែងជាគុកទេ ។ ខ្ញុំដើរមកដល់ហ្នឹងស្រាប់គេថា និយាយតៗគ្នាថា កន្លែងហ្នឹងគុកទួលស្លែងៗ ពីជំនាន់ ប៉ុល ពត ។

[១១:៥២:៣៣]

**ស៖** នៅពេលដែលទ័ពវៀតណាមចូលមកដល់ក្នុងគុកនោះ តើលោកបានចាំថា គេមានថតរូបភាពធម្មតា ឬក៏គេមានថតរូបភាពខ្សែវីដេអូដែរឬទេ?

**ឆ៖** បាទ, មិនបានចាំថាមានការថត ការអីទេ ដោយសារខ្ញុំឃើញមនុស្សច្រើន មានកាំភ្លើង មានអីអ៊ីចឹង ដូចជាទាហានខាង-- ដូចជាខាងពុកខ្ញុំដែរ មានទាហាន គាត់ប្លែកពុកខ្ញុំ ហើយខ្ញុំខ្លាចពួកគេខ្លះអត់ចេះនិយាយភាសាខ្មែរ ហើយខ្ញុំអត់មានគិតថា អ្នកណាជាអ្នកថត អ្នកអីទេ ប៉ុន្តែគ្រាន់តែថាដឹងថា គេយកចេញពីនុ៎ង ចេញពីមន្ទីរទួលស្លែងហ្នឹង ។

**ស៖** ដូច្នេះ ខ្ញុំសូមឲ្យលោកបំភ្លឺនៅចំណុចចុងក្រោយ ។ ទាហានវៀតណាមនោះ គឺបានយកលោក និងក្មេងៗផ្សេងទៀតទៅពេទ្យ ថាតើវាមានចម្ងាយឆ្ងាយប៉ុនណាពីគុកហ្នឹងទៅពេទ្យ? ថាតើលោកចំណាយតែប៉ុន្មាននាទីតែប៉ុណ្ណោះ ឬក៏ចំណាយដល់រហូតដល់ប៉ុន្មានម៉ោងនោះ ដើម្បីទៅដល់ពេទ្យនោះ?

**ឆ៖** បាទ, រឿងម៉ោងនោះ ខ្ញុំបាទអត់ចាំ អត់-- ខ្ញុំមិនអាចដឹងបាន ។

**ស៖** ចុះថាតើលោកត្រូវឈប់គេងយប់នៅទីណាដែរឬទេ? ហើយលោកមានញ៉ាំអាហារដែរឬទេមុនពេលទៅដល់ពេទ្យ?

**ឆ៖** បាទ, អត់ទាន់បានញ៉ាំអីទេ ប៉ុន្តែទៅដល់ពេទ្យហ្នឹងបានគេរៀបចំឲ្យហូបបបាយ ហូបបបាយធម្មតា ។ ហើយប្អូនៗខ្ញុំហ្នឹងហូបបបាយលែងកើតហើយ ដោយមានការបន្តក់ទឹកស ទឹកយើងធម្មតា ហើយមានព្យួរសេរ៉ូម ព្យួរអី អាអូនតូចៗជាងគេពីរនាក់នោះ ហើយដល់ខ្ញុំពីរនាក់បងប្អូននេះ គ្រាន់តែទទួលអាហារទេ ពួកខ្ញុំអាចមានកម្លាំងឡើងវិញបាន ។ ឯចំពោះអាពីរនាក់បងប្អូនស្រីមួយប្រុសមួយ

ដែលថា វាដាច់ខ្យល់នោះ វាត្រូវតែបន្តក់ទឹក ហើយនិងព្យួរសេរ៉ូម ។

[១១:៥៥:១៤]

**ស៖** នៅពេលដែលគេយកលោកទៅមន្ទីរក្មេងកំព្រា ថាតើមន្ទីរនោះនៅឆ្ងាយពីពេទ្យនោះដែរឬទេ?

**ឆ៖** បាទ, ក្រោយមករំដោះហ្នឹង ខ្ញុំបានមានការដឹងខ្លះនៅក្នុងទីក្រុងភ្នំពេញហ្នឹង ខ្ញុំដឹងថាមន្ទីរពេទ្យសម្ភពក្រុងហ្នឹង ហើយនិងទៅមជ្ឈមណ្ឌលកុមារកំព្រាហ្នឹង វាមិនឆ្ងាយប៉ុន្មានទេ បើគិតថា យើងជិះម៉ូតូប្រហែលជាខ្ទង់ប្រហែលកន្លះម៉ោងប៉ុណ្ណឹង ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៌៖**

ខ្ញុំសូមអរគុណច្រើន ហើយសូមអរគុណលោកដែលមកទីនេះ នៅថ្ងៃនេះជម្រាបនូវអ្វីដែលកើតឡើងចំពោះលោក ។ លោកប្រធានខ្ញុំអត់មានសំណួរទៀតទេ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក់ ។

**សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមជម្រាបសួរលោក នង ចាន់ផល ហើយសូមអរគុណដែលលោកបានអញ្ជើញមកថ្ងៃនេះ ។

ខ្ញុំមានសំណួរពីរបី ដើម្បីសូមឲ្យលោកបំភ្លឺចំណុចមួយចំនួនដែលលោកបានបញ្ជាក់ ។ តាមដែលខ្ញុំយល់អ្វីដែលលោកបាននិយាយនោះ លោកបានពន្យល់ថា នៅពេលដែលឪពុករបស់លោកបានចាកចេញពីកន្លែងនោះមកភ្នំពេញ គាត់បានសរសេរសំបុត្រមួយទៅឲ្យម្ដាយរបស់លោក ។

**ស៖** តើអ៊ីចឹងមែនទេ ដែលលោកនិយាយព្រឹកមិញនេះ?

**ឆ៖** បាទ, ឪពុកខ្ញុំ គាត់អត់បានសរសេរសំបុត្រទៅម្ដាយខ្ញុំទេ គ្រាន់តែមានគេយកសំបុត្រមកឲ្យគាត់ៗអានហើយ ក៏គាត់ព្រមទៅភ្នំពេញជាមួយនឹងគេ អ្នកគេយកសំបុត្រមកឲ្យគាត់នោះ ។ ចំពោះសរសេរសំបុត្រមកម្ដាយខ្ញុំអត់មានទេ ។ មានតែព្វខ្ញុំជាកម្មករកំណាល់រទេះភ្លើងហ្នឹង គាត់ឃើញសភាពមិនដូចជាសព្វដង គាត់រត់មកប្រាប់ម្ដាយខ្ញុំនៅពេលចប់ម៉ោងការងារ ហើយខ្ញុំនៅក្បែរម្ដាយខ្ញុំនុ៎ង ។

[១១:៥៧:៤៨]

**ស៖** ដូច្នេះ បើសិនជាខ្ញុំយល់ត្រឹមត្រូវនោះ នៅពេលនោះ លោកអាយុតែប្រាំឆ្នាំទេ ហើយបើខ្ញុំយល់ច្បាស់នោះ គឺថាការចងចាំរបស់លោក គឺម្ដាយរបស់លោកបានទទួលសំបុត្រមួយពីមនុស្សដែល

មិនស្គាល់ឈ្មោះ ហើយបានប្រាប់គាត់ថាៗ ពេលណាមួយក្រោយគេនឹងនាំម្តាយលោកមកភ្នំពេញ តើអ៊ីចឹងទេក្នុងសំបុត្រនោះ?

**ផ៖** បាទ, អត់មានបញ្ជាក់សំបុត្រអីមកម្តាយខ្ញុំទេ ។ ស្រាប់តែមានរយៈពេលក្រោយមកនុ៎ង ខ្ញុំចេះសួររកថាម្តាយខ្ញុំ ថាម្តាយ ខ្ញុំសួរថាម៉ែ ថ្ងៃណាឪពុកត្រឡប់មកវិញ ហើយនៅពេលនោះ ម្តាយខ្ញុំថា "អ្អឺ! មិនដឹងជាពេលណាទេ បើចាំយូរដែរហើយមិនឃើញគាត់មក" តែប៉ុណ្ណឹងទេ ។

**ស៖** នៅពេលដែលគេនាំយកមកជាមួយឡានហ្ស៊ីប ជាមួយម្តាយរបស់លោក ហើយនិងមនុស្សផ្សេងទៀតនោះ ហើយលោកបញ្ជាក់ថា គឺថា ក្រោយមកទៅដល់ស្ថានីយរថភ្លើងមួយ រ៉ាវទេះភ្លើង តើលោកនៅចងចាំទេ រ៉ាវទេះភ្លើងនោះនៅកន្លែងណា? តើវានៅជិតទីកន្លែងដែលគេចាប់លោក តើឬក៏នៅកន្លែងណា?

**ផ៖** បាទ, ខ្ញុំនៅចាំបាននោះ គឺថាក្នុងរ៉ាវទេះភ្លើងនោះ ពេលខ្ញុំមកពីកំពង់ស្ពឺ គេបញ្ជូនខ្ញុំមកដល់ហ្នឹង គេបញ្ចូលខ្ញុំនៅក្នុងនោះទាំងម្តាយ ហើយនិងស្ត្រីមកជាមួយគ្នាពីរនាក់ទៀត ហើយនិងខ្ញុំ ក្មេងៗប្រាំនាក់នៅក្នុងនុ៎ង ហើយខ្ញុំបានថា រ៉ាវទេះភ្លើងហ្នឹង មានរទេះភ្លើងបែរមុខមកកើតហ្នឹង បើតាមខ្ញុំចាំបាន ហើយក្រោយមកខ្ញុំក៏ដើរបានជិះម៉ូតូ ឬក៏ដើរ ជិះកង់កាត់ហ្នឹង កាលពីខ្ញុំនៅរៀន ខ្ញុំចាំច្បាស់ថា ចាំទាំងកន្លែងម្តាយខ្ញុំសម្រាកនៅក្នុងហ្នឹងទៀត ដោយម្តាយខ្ញុំសុំអាអ្នកយាមនៅទីនោះ ថានៅគាត់សុំដាំថ្នាំខ្មែរ ដោយគាត់ឈឺហើម គាត់សុំដាំថ្នាំខ្មែរ គាត់មានកំសៀវទឹកយកមកជាមួយ ។ ហើយអ្នកយាមហ្នឹងគេបានប្រាប់ថា មិនឲ្យបង្កាត់ភ្លើងអីនៅកន្លែងនេះទេ ព្រោះកន្លែងនេះ ជារ៉ាវទេះភ្លើង ហើយរ៉ាវទេះភ្លើងខ្ញុំចាំបាន គឺរ៉ានៅភ្នំពេញយើងហ្នឹង ។

**ស៖** ដូច្នេះ ទាំងអស់គ្នានុ៎ង គេបានដឹកលោកទាំងអស់គ្នាមកស្ថានីយរថភ្លើង រ៉ាវទេះភ្លើង ថាតើមានអ្នកបើកបរដដែលហ្នឹង ដែលយកពីរ៉ាវទេះភ្លើងមកទួលស្លែងហ្នឹង អ្នកបើកបរឡានហ្នឹងដដែលទេ?

**ផ៖** បាទ, ខ្ញុំអត់បានចាំទេ អ្នកដែលបើកឡាន ហើយនិងទាហានហ្នឹង ខ្ញុំអត់បានចាំទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា ខ្ញុំពួកខ្ញុំក្មេងៗ ដល់ពេលដែលបានជិះឡានហ្នឹង មានភាពសប្បាយ ប៉ុន្តែមិនដឹងថា គេយកទៅកន្លែងណា កន្លែងភ័យខ្លាចណា ខ្ញុំអត់ដឹង ។ តែពេលដែលបានជិះឡានហ្នឹង ពួកខ្ញុំហ្នឹងអរណាស់ ។

[១២:០១:៤២]

**ស៖** តើលោកនៅចាំដែរឬទេថា លោកបានទទួលព័ត៌មានអីខ្លះ ដែលថាគេថា ប្រាប់លោកថា លោកនឹងជួបឪពុកលោកម្តងទៀត ឬក៏គេមានប្រាប់ព័ត៌មានអ្វីបែបនេះដែរឬទេ?

**ឆ៖** នៅពេលដែលគេទៅយកម្ដាយខ្ញុំ ព្រមទាំងខ្ញុំមក គេថា យកអ្នកមីងទៅជួបលោកពូនៅភ្នំពេញគេបានប្រាប់យើងអ៊ីចឹង ហើយខ្ញុំក៏មានភាពអរសប្បាយថា ខ្ញុំនឹងទៅដល់ភ្នំពេញបានជួបឪពុកខ្ញុំហើយ តែតាមពិតមកដល់ភ្នំពេញរហូតក្រោយថ្ងៃរំដោះ រហូតមកដល់បច្ចុប្បន្ន គឺអត់ឃើញឪពុកខ្ញុំទាល់តែសោះ រហូតដល់បច្ចុប្បន្ននេះ ។

**ស៖** នៅពេលដែលលោកបានមកដល់ទួលស្លែង ដូច្នេះលោកក៏បានពន្យល់យើងថា គឺថាគេមានថតរូបម្ដាយរបស់លោក តើលោកអាចពន្យល់ថែមទៀតបានទេ នៅពេលដែលម្ដាយរបស់លោកគេដាក់ខ្នោះដៃរបស់គាត់ទេ ឬក៏មិនដាក់ខ្នោះដៃទេ ក្រោយមកនោះ?

**ឆ៖** បាទ, នៅពេល ខ្ញុំចាំបាន នៅពេលដែលគេបញ្ជូនរុញម្ដាយខ្ញុំចុះពីលើឡានហ្នឹង អត់មានដាក់ខ្នោះដាក់អីទេៗ រុញចូលទៅក្នុងបន្ទប់ដែលគេថតរូបនៅប៉ុយរ៉ូខាងខាងមុខហ្នឹង គឺចូលទៅថតរូបហ្នឹង គឺចូលទៅថតរូបហ្នឹង អត់មានដាក់ខ្នោះដាក់អី រហូតដល់បញ្ជូនឡើងទៅលើអគារហ្នឹងទៀត ក៏អត់មានដាក់ខ្នោះដែរ នៅក្នុងបន្ទប់ហ្នឹងអត់មានដាក់ខ្នោះទេ ចាក់តែឲ្យពួកខ្ញុំចូលសម្រានខាងក្នុងជាមួយម្ដាយខ្ញុំ គ្រាន់តែកិបសោរតែពីក្រៅទេ ។

**ស៖** តើលោកនៅចាំឬទេថា ម្ដាយរបស់លោកត្រូវបានគេចងមុខ ឬក៏គេចាប់ចង់មុខលោកដែរឬទេ ដើម្បីកុំឲ្យលោកមើលឃើញនោះ?

**ឆ៖** បាទ,អត់មានចងមុខម្ដាយខ្ញុំទេ ហើយខ្ញុំក៏អត់បានមានការចងអីដែរ គ្រាន់តែហៅទៅតាមសម្រួលទៅឡើងលើអគារទីបី បន្ទប់ទីពីរ ជាន់ទីពីរហ្នឹង ។

**ស៖** តើលោកនិយាយថា អគារទីបី តើលោកអាចកំណត់ឲ្យបានច្បាស់ជាងហ្នឹងទេ? តើអគារទីបីនុ៎ង មានន័យថាម៉េច? លោកស្គាល់ថាជាអគារអ្វីពេលនោះ?

**ឆ៖** កាលនោះ ខ្ញុំអត់ដឹងថាអគារទីប៉ុន្មានទេ មកពេលល្ងាចហ្នឹង ប៉ុន្តែខ្ញុំនៅចាំអគារហ្នឹង មានចេញពីក្រោយប៊ុយរ៉ូទៅ ចេញពីក្រោយប៉ុយរ៉ូកន្លែងគេថតហ្នឹងឡើងទៅចំមុខអគារហ្នឹងតែម្ដង ។ ហើយខ្ញុំនៅចាំបានផ្លូវឡើងនិងបន្ទប់ ហើយក្រោយមកខ្ញុំបានចូលទៅលេងពេលក្រោយថ្ងៃរំដោះ ខ្ញុំនៅកុមារកំព្រា ចូលទៅខ្ញុំគ្រាន់តែឡើងទៅមើលកន្លែងដែលម្ដាយខ្ញុំសម្រាកជាមួយខ្ញុំហ្នឹង ហើយខ្ញុំចាំបានស្គាល់ពេលក្រោយ បានខ្ញុំស្គាល់បន្ទប់រិតតែច្បាស់ និងខ្ញុំដឹងថាអគារនោះជាអគារទីបី ជាន់ទីពីរ បន្ទប់ទីពីរ ។

**ស៖** ដូច្នេះ ប្រសិនបើលោកត្រឡប់ទៅទួលស្លែងវិញ នៅពេលដែលលោកចូលទៅដល់ច្រកទ្វារធំនៃសារមន្ទីរ តើលោកនិយាយអគារនៅចំពីមុខលោក ឬក៏នៅខាងឆ្វេងដៃ ឬខាងស្ដាំ តើលោកនិយាយ

ថាអគារមួយណា?

**ផ៖** បាទ, បើខ្ញុំនៅចាំបានរហូតដល់បច្ចុប្បន្ន ពេលដែលខ្ញុំចូលទៅអគារទល់មុខខ្ញុំខាងស្តាំដៃ ។ ខាងឆ្វេងជាអគារទីពីរទេ ។

**ស៖** ដូច្នេះ លោកបានពន្យល់ប្រាប់យើងថា លោកចូលទៅដល់ខ្លោងទ្វារខាងមុខនៃសារមន្ទីរ គឺអគារនៅខាងស្តាំដៃ តើអ៊ីចឹងមែនឬទេ?

**ផ៖** បាទ, មែន ។

**ស៖** ដូច្នេះ នៅពេលដែលលោកថា លោកនៅជាន់ទីពីរ តើជាន់ទីពីរហ្នឹង តើអាជាន់ផ្ទាល់ដីជាជាន់ទីមួយ ឬក៏ជាជាន់ចុងបំផុតនៃអគារនោះ?

**ផ៖** ខ្ញុំនៅចាំបានថា ពេលដែលខ្ញុំឡើងទៅកាំជណ្តើរហ្នឹង អាហ្នឹងជាន់នៅជាប់ដីហ្នឹង អាឡើងទៅបន្ទាប់មក បានជាន់ទីពីរ ឡើងទៅមួយជាន់ អាជាន់ទីមួយ ជាន់ឡើងមួយជាន់ទៀតបានជាន់ទីពីរ ដោយសារជាន់នោះ ជាន់ទីពីរហ្នឹងជាជាន់ផុតលើគេបង្អស់ ។

**ស៖** នៅក្នុងកន្លែងឃុំមួយដែលលោកបាននៅជាមួយម្តាយរបស់លោក តើមានអ្នកទោសផ្សេងទៀតដែរឬទេ? ហើយម្តាយរបស់លោកនិងលោក ត្រូវបានគេដាក់ខ្នោះដែរឬទេ?

**ផ៖** បាទ, ខ្ញុំនៅចាំបាន នៅពេលដែលគេបញ្ជូនខ្ញុំ និងម្តាយខ្ញុំចូលក្នុងបន្ទប់ ថ្នាក់រៀនមួយធំហ្នឹង ចូលដល់ទៅក្នុងហ្នឹង អត់មានដាក់ខ្នោះដាក់អីទេ ហើយអត់មានពេលចូលទៅសម្រានហ្នឹងក៏អត់មាន មុងមានអីដែរ ដោយសារម្តាយខ្ញុំយកក្រមារបស់គាត់នោះ បានបក់ឲ្យខ្ញុំ ពេលដែលខ្ញុំគេងនុំង ។

**ស៖** ហើយនៅជាន់នោះ តើៗមាននៅលើកម្រាលហ្នឹងមានរបាដែក ឬក៏មានអ្វីទេ ដែលលោកនៅចងចាំនោះ?

**ផ៖** បាទ, ខ្ញុំនៅចាំថា បន្ទប់នុំងមានចំរឹងដែកនៅតាមបង្អួច ហើយនៅលើដែលពួក ដែលម្តាយខ្ញុំ ព្រមទាំងខ្ញុំសម្រាកហ្នឹង អត់មានកន្ទេល មានអីទេ គឺនៅផ្ទាល់នឹងឥដ្ឋតែម្តង ។

[១២:០៩:៥០]

**ស៖** ដូច្នេះ គេបានបំបែកលោកពីម្តាយរបស់លោកនៅថ្ងៃបន្ទាប់មក តើលោកអាចរៀបរាប់ឲ្យយើងដឹងច្បាស់ជាងហ្នឹងបានទេ ជាកន្លែងដែលលោក គេនាំលោកទៅក្រោយពីបំបែកពីម្តាយនោះ?

**ផ៖** បាទ, ខ្ញុំនៅចាំថានៅសម្រាកបានមួយយប់ ព្រឹកឡើងហ្នឹង បានអ្នកយាមគុកទាំងអស់ហ្នឹង បាទ ខ្ញុំដឹងថាប៉ុន្មាននាក់ទេ បានជញ្ជូនខ្ញុំមក ពេលខ្ញុំចុះដើរមក ខ្ញុំអ្នកដើរចុះមុនគេ ហើយអ្នកបន្ទាប់ដែល

គេបីក្មេងៗចុះមកក្រោយ ក៏ខ្ញុំអត់ដឹងថា ប៉ុន្មាននាក់ដែលបីមកដែរ ។ យកខ្ញុំមកដាក់ចូលទ្វារខាងក្រោយ មកអង្គុយរោងជាងខាងក្រោយហ្នឹង នៅក្បែរទ្រុងជ្រូកហ្នឹង ។

**ស៖** តើនៅកន្លែងនោះគេដាក់ខ្នោះលោកដែរឬទេ? តើលោកមានអ្វីសម្រាប់គេងពេលយប់ទេ មានពូក ឬក៏ខ្នើយអ្វីទេ?

**ឆ៖** បាទ, នៅខាងក្រោយនុ៎ង អត់មានពូក មានខ្នើយ មានអីទេ មានតែកម្រាលក្តារ ផ្តាំងបើតាមខ្ញុំដឹង ផ្តាំងក្តារមួយធំហ្នឹង ហើយមានក្រណាត់ចាស់ៗនៅហ្នឹង ហើយមានស្ត្រីចំណាស់ហ្នឹងគេឲ្យមើលពួកខ្ញុំហ្នឹង អត់ឲ្យខ្ញុំចេញទៅណា ហើយដោយគ្មានដាក់ខ្នោះ ដាក់ច្រវាក់អីទេ ។

**ស៖** តើមានអង្រឹងអ្វីទេនៅទីនោះ?

**ឆ៖** បាទ, ខ្ញុំអត់បានចាំថា មានអង្រឹង ឬក៏យ៉ាងណា ដូចអត់មានទេ ។ បើខ្ញុំអត់ និយាយចាំថាអត់ចាំ ។ អត់បានប្រទះភ្នែកឃើញទេ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវលើសម៉ោងហើយ ឥឡូវដល់ម៉ោងត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ហើយអង្គសវនាការនឹងលើកទៅបន្តនៅរសៀលនេះ ចាប់ពីវេលាម៉ោងមួយកន្លះ ហើយមន្ត្រីតុលាការនាំ សម្របសម្រួលដល់លោក នង ចាន់ផល ដើម្បីបានទទួល កន្លែងសម្រាកសមរម្យ អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទ ទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់ត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោងមួយកន្លះនៅរសៀលនេះ ។

*[សវនាការសម្រាកពីម៉ោង ១២:១២នាទី ដល់ម៉ោង ០១:៣៣នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការកិច្ចនីតិវិធីសវនាការ សួរពិភាក្សាដេញដោលចំពោះអ្នករស់រានមានជីវិត ឈ្មោះ នង ចាន់ ផល ជាបន្ត ។ ហើយតទៅនេះសួរថា អស់លោក លោកស្រីចៅក្រមតើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះទៀតដែរឬទេ? បើមានសូមអញ្ជើញ ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោក នង ចាន់ផល តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ ថាតើតាមការចងចាំរបស់លោក លោកត្រូវបានគេដោះលែងឲ្យដើរចេញពីកន្លែងដែលគេរក្សាទុកកូនក្មេងទាំងនោះ ។ លោកបានពន្យល់មុននឹងថា លោកបានឃើញមនុស្សម្នាក់ដែលជាស្ត្រី ហើយថា ជាម្ដាយរបស់លោកនៅជាន់ទីពីរនៅក្នុងអគារ ។ ថាតើលោកអាចធ្វើការដើរទៅដើរមកនៅក្នុងទីកន្លែងនោះដែរឬទេ? ឬក៏លោកត្រូវបានគេហាមឃាត់ ហើយឲ្យនៅតែក្នុងកន្លែងមួយតែប៉ុណ្ណោះ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! ពេលដែលខ្ញុំនៅខាងក្រោយរោងជាងនោះ ខ្ញុំសម្លឹងមើលទៅខាងក្រោយហ្នឹង ស្រាប់តែឃើញម្ដាយខ្ញុំឈរតោងនៅចង្រឹងបង្អួចហ្នឹង គាត់មើលមកខ្ញុំ ដោយខ្ញុំមិនបានដើរទៅណាទេ នៅខាងក្រោយហ្នឹង ហើយខ្ញុំមើលទៅគាត់ ។ គាត់មើលទៅ ហាក់បីដូចគាត់ចង់និយាយអីជាមួយខ្ញុំ ប៉ុន្តែវាឆ្ងាយពេកពីកម្ពស់អគារហ្នឹងមក មកដល់ខាងក្រោមនេះ ហើយខាងក្រោយគុកហ្នឹងទៀត វាឆ្ងាយហើយគាត់អត់មាននិយាយអីគេ គ្រាន់តែមើលដោយក្រសែភ្នែក មកមើលពួកខ្ញុំ ហើយខ្ញុំក៏បានមើលទៅគាត់មួយសន្ទុះ អ៊ីចឹងបានខ្ញុំដាក់ភ្នែកមកធម្មតាវិញ ។ ហើយចាប់តាំងពីពេលនោះមកខ្ញុំលែងបានជួបគាត់រហូត ។

**ស៖** លោកហាក់ដូចជាមិនយល់សំណួររបស់ខ្ញុំ ។ ថាតើលោកអាចដើរទៅដើរមកទៅកន្លែងផ្សេងៗដែរឬទេ? ឬក៏លោកនៅខាងក្រោយអគារ ឬនៅកន្លែងរបស់លោករហូតតែម្ដង? ថាតើលោកនៅកន្លែងលោក ដែលគេឲ្យលោកនៅនោះរហូត ឬក៏លោកអាចដើរទៅ ដើរមកទៅកន្លែងផ្សេងៗបាន?

**ឆ៖** កាលពីនៅមានអ្នកនៅធ្វើការហ្នឹងនៅមិនទាន់ទ្វារចំហគុកហ្នឹង គឺពួកខ្ញុំអត់មានបានដើរទៅណាមកណាបានទេ គេនៅមើលគេមើលថាឲ្យហ្នឹង គេនៅមើលពួកខ្ញុំហ្នឹង ។ ទាល់តែពេលទ្វារគុកចំហហើយស្ត្រីដែលបក់ដៃហៅខ្ញុំឲ្យចេញទៅជាមួយគាត់ ខ្ញុំអត់ទៅហ្នឹង បានពេលដែលស្ងប់ស្ងាត់ហ្នឹង បានខ្ញុំអាចដើរបាន ។

[១៣:៣៧:០០]

**ស៖** ដូច្នេះហើយ នៅពេលដែលគេបើទ្វារអីផ្សេងៗនោះ តាមការចងចាំរបស់លោក ។ លោកបានចាំថា លោកបានឃើញស្ត្រីនោះនៅជាន់ទីពីរ ឬក៏លោកឃើញស្ត្រីនោះមុនពេលដែលគេបើកទ្វារអីផ្សេងៗ?

**ឆ៖** សំណួរនេះខ្ញុំអត់យល់ ដោយថាទីមួយ ស្ត្រីនោះ ខ្ញុំឃើញជាម្ដាយខ្ញុំនៅលើអគារ នៅលើបង្អួច ។ ហើយស្ត្រីម្នាក់ដែលមើលពួកខ្ញុំនៅខាងក្រោមហ្នឹង គឺគាត់ហៅខ្ញុំចេញទៅនៅពេលទ្វារគុកចំហខាងមុខខាងក្រោយ គាត់ហៅខ្ញុំរត់ចេញទៅជាមួយគាត់ ប៉ុន្តែខ្ញុំអត់ព្រមចេញទៅ ។ ហើយខ្ញុំអត់យល់សំណួរ ។

**ស៖** ខ្ញុំនឹងព្យាយាមសួរឲ្យបានច្បាស់ ។ យើងនិយាយអំពីម្ដាយរបស់លោក ហើយចំណុចមួយទៀតយើងនិយាយអំពីស្ត្រីដែលចង់ឲ្យលោកទៅជាមួយគាត់ ហើយលោកបដិសេធមិនចេញទៅជាមួយគាត់ទេ ។ តាមការចងចាំរបស់លោក ថាតើលោកចាំដែរឬទេ ថាលោកបានឃើញម្ដាយរបស់លោកមុនពេលដែលស្ត្រីនោះគាត់ហៅលោកចេញ ឬក៏លោកឃើញម្ដាយរបស់លោក បន្ទាប់ពីស្ត្រីនោះហៅលោកចេញ?

**ឆ៖** ចំណុចត្រង់នេះវា-- ពេលដែលខ្ញុំឃើញម្ដាយខ្ញុំ វាចុងក្រោយហ្នឹង កាលហ្នឹងវា ទ្វារគុកយើង ហ្នឹងមិនទាន់ចំហទេ អ្នកនៅយាមទ្វារគុកហ្នឹងក៏នៅដែរ ។ ទាល់តែពេលម្ដាយខ្ញុំបាត់ គាត់បាត់រហូតមក បានជាថ្ងៃក្រោយមកទៀតទេ បានស្ត្រីចំណាស់ហ្នឹង ពេលទ្វារគុកខាងមុខ ខាងក្រោយចំហហ្នឹងបានគាត់ហៅខ្ញុំចេញ ។ គឺម្ដាយខ្ញុំហ្នឹង គាត់បាត់តាំងពីអ្នកទៅធ្វើការក្នុងគុកហ្នឹង មិនទាន់មានចំហទ្វារគុកម្ល៉េះ ។

**ស៖** នៅពេលដែលលោកនៅខាងក្រោយអគារនោះ តើលោកធ្លាប់ដែរឃើញមនុស្សផ្សេងៗ និងអ្នកយាមដែរឬទេ? ហើយតើលោកបានធ្លាប់ឮសំឡេងអ្វីផ្សេងៗដែរឬទេ ដូចជាការស្រែក និងការយំផ្សេងៗរបស់អ្នកមនុស្សផ្សេងៗនោះ? ថាតើលោកធ្លាប់ឮទៅលើចំណុចហ្នឹង ទាំងអស់នេះដែរឬទេ?

[១៣:៣៩:៤៤]

**ឆ៖** បាទ, ខ្ញុំចាំមិនសូវច្បាស់ ដោយសារវាយូរពេកហើយ ណាមួយឮសំឡេងដែរ ដល់ឮសូរម្ដងម្កាល ហើយខ្ញុំរៀបពេលដែលឮសំឡេងទៅ ខ្ញុំចោលទៅ-- ភ្នែកទៅរកមើលម្ចាស់សំឡេង ហើយនិងសម្លឹងទៅរកមើលប្រឡោះបង្អួច ដែលម្ដាយខ្ញុំឈរហ្នឹង គឺសំឡេងផ្អើយពីកន្លែងដែលម្ដាយខ្ញុំ ឈរពីតាមបង្អួចនោះមក ដោយសារឮសំឡេងម្ដងៗម្កាល ខ្ញុំតែងតែចោលភ្នែកមើលទៅរកមើលកន្លែងដែលម្ដាយខ្ញុំឈរហ្នឹង ។

**ស៖** ខ្ញុំនៅសល់សំណួរចុងក្រោយសម្រាប់លោក ។ ព្រឹកមិញ ប្រសិនបើខ្ញុំស្ដាប់ត្រឹមត្រូវនោះលោកបានលើកឡើងថា ក្រុមក្មេងៗ ឬក៏បងប្អូនរបស់លោក គឺមានចំនួនប្រាំពីរនាក់ បងប្អូនរបស់

លោក ។ អ៊ីចឹងថាប្រាំពីរនាក់នោះ ជាបងប្អូនរបស់លោក ហើយតើបងប្អូនរបស់លោកទាំងពីរនាក់មានអ្នកណាគាត់នៅរស់ដែរឬទេ? ឬក៏លោកបានទទួលដំណឹងពីពួកគាត់ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំមានបងប្អូនប្រាំពីរនាក់ ប៉ុន្តែ ដែលនៅមកជាប់ម្ដាយចូលក្នុងទួលស្លែងហ្នឹង ចូលក្នុងទួលស្លែងតែពីរនាក់បងប្អូនខ្ញុំទេ ។ ហើយដែលបងប្រាំនាក់ទៀត គាត់នៅខាងក្រៅហ្នឹង សហករណ៍ផ្សេងៗទៀត ដោយខ្ញុំអត់បានដឹង អត់បានចាំ ប៉ុន្តែបច្ចុប្បន្នពួកគាត់នៅរស់ នៅរស់រានមានជីវិត ដូចប្រជាពលរដ្ឋទូទៅដែរ ។ តែបាត់តែបងស្រីម្នាក់ ធំជាងគេបាត់នៅក្នុងជំនាន់ ប៉ុល ពត ហ្នឹង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណច្រើន លោក នង ចាន់ផល ។

ខ្ញុំអស់សំណួរសួរទៅកាន់សាក្សីទៀតហើយ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អស់លោកចៅក្រមផ្សេងទៀតមានសំណួរអីទេ?

សូមអញ្ជើញលោកចៅក្រម ធូ មណី ។

**សួរដោយ ចៅក្រម ធូ មណី៖**

សូមអរគុណ លោកប្រធាន ។

**ស៖** លោក នង ចាន់ផល តើលោកអាចបញ្ជាក់យើងឡើងវិញបានទេថា នៅពេលដែលលោកឃើញស្ត្រីម្នាក់ដែលលោកអះអាងថា ជាម្ដាយរបស់លោកឈរហ្នឹង លោកបានឃើញប៉ុន្មានដងដែលគាត់ឈរនៅចម្រឹងដែកមាត់បង្អួចហ្នឹង?

**ស៖** បាទ, ខ្ញុំសូមបញ្ជាក់ថា ពេលដែលខ្ញុំចុះពីលើអគារ នៅពេលព្រឹកគេបំបែកខ្ញុំមកខាងក្រោយរោងជាងខាងក្រោយហ្នឹង គឺខ្ញុំបានមើលគាត់ឃើញតែម្ដងគត់ ពីអាក្រោមអគារ ពីខាងក្រោយអគារទៅលើអាបន្ទប់គាត់នៅលើបង្អួច ឃើញនៅលើបង្អួចហ្នឹង តាមបង្អួចហ្នឹង ។

[១៣:៤២:៤៩]

**ស៖** តើរយៈពេលប្រហែលជាប៉ុន្មានដែរ តាំងពីលោកបានឃើញម្ដាយលោកជាចុងក្រោយរហូតដល់ថ្ងៃដែល ចុងក្រោយដែលគេ-- លោកថាស្ត្រីម្នាក់ដែលហៅលោកឲ្យទៅជាមួយនោះ?

**ឆ៖** បាទ, ពេលដែលខ្ញុំឃើញម្ដាយខ្ញុំហ្នឹង ឃើញមុនស្ត្រីហ្នឹង ពេលចាប់ពីខ្ញុំចុះមកខាងក្រោមឃើញតែគាត់តែម្ដងហ្នឹងមក ក៏លែងឃើញរហូត ។ ហើយស្ត្រីដែលបក់ដៃហៅខ្ញុំ មើលពួកខ្ញុំ ហើយ

ហៅខ្ញុំចេញទៅខាងក្រៅគុកហ្នឹង គឺខាងក្នុងគុកហ្នឹងមានសភាពស្ងប់ស្ងាត់ហើយ ហើយគាត់ឃើញ ហើយខ្ញុំឃើញទ្វារគុកខាងមុខ ខាងក្រោយចំហ ហើយគាត់ហៅ ខ្ញុំអត់ព្រមចេញទៅទេ ។

**ស៖** ប៉ុន្តែ លោកអាចបញ្ជាក់បានទេ រយៈពេលប្រហែលជាប៉ុន្មានទៅ ចាប់ពីពេលដែលលោកឃើញម្តាយលោក ហើយនិងរយៈពេលដែលគេហៅលោកឲ្យចេញទៅហ្នឹង ប៉ុន្មានថ្ងៃ ប៉ុន្មានខែ?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំអត់ចាំបាន ព្រោះខ្ញុំនៅក្មេងពេក អត់ដឹងពីរយៈពេលប៉ុន្មានទេ អត់បានគិតថា វាយូរ ឬក៏ឆាប់ ។

**ស៖** សំណួរមួយទៀត នៅពេលដែលលោកអះអាងថា មានកងទ័ពវៀតណាម ហើយនិងមានខ្មែរខ្លះ ដែលទៅយកលោកពីក្នុងមន្ទីរគុកទួលស្លែងហ្នឹងមក ហើយយកលោកទៅពេទ្យ ។ តើការយកពីទួលស្លែងទៅពេទ្យហ្នឹង គឺយកទៅក្នុងថ្ងៃតែមួយហ្នឹង ឬក៏រំលងបានប៉ុន្មានថ្ងៃបានយកទៅពេទ្យ?

**ឆ៖** បាទ, មានកងទ័ពពីរនាក់ហ្នឹង មកដាំបាយឲ្យពួកខ្ញុំហូបហើយ សួរខ្ញុំហើយហ្នឹង ដូចជម្រាបពីខាងមុន ហើយដល់ពេលព្រឹកឡើង ព្រឹកឡើង ឬក៏ព្រឹកឡើងថ្ងៃបន្ទាប់ ខ្ញុំអត់បានចាំដែរ បានមានទ័ពមកច្រើន គេដើរពេញខាងក្នុងគុកហ្នឹង ហើយមានអ្នកខ្លះក៏គេមកយកពួកខ្ញុំ ហើយអ្នកខ្លះក៏គេដើរមើលពេញខាងក្នុងគុកហ្នឹង ។

**ស៖** លោកអាចបញ្ជាក់បានទេថា នៅពេលដែលគេយកលោកទៅពេទ្យហ្នឹង គេយកចេញពីទួលស្លែងហ្នឹងទៅពេទ្យតែម្តង ឬក៏ប៉ុន្មានថ្ងៃកន្លងមក?

**ឆ៖** បាទ, នៅពេលដែលគេយកពួកខ្ញុំចេញពីគុកហ្នឹង គឺយកទៅពេទ្យហ្នឹងតែម្តង ហើយពួកខ្ញុំមានសភាព វាធ្ងន់ហើយ មានដូចចង់ដាច់ខ្យល់ហើយ ដង្ហក់ អត់អាហារ ។

[១៣:៤៥:៤៨]

**ស៖** ហើយលោកសម្រាកនៅមន្ទីរសម្ភពក្រុងនុំង រយៈពេលប៉ុន្មានទៅ?

**ឆ៖** ខ្ញុំបាទនៅចាំបានថា អត់មានចាំថ្ងៃខែបាន ដោយសារចូលទៅហ្នឹង គ្រាន់តែឃើញថា ពួកខ្ញុំត្រូវសម្រាកនៅហ្នឹង ហើយមានកងទ័ពគេរបួសខ្លះមានខ្មែរយើងខ្លះ មានប្រជាជនយើងហ្នឹង ហើយនិងទ័ពវៀតណាមខ្លះ មានរបួសប៉ុណ្ណឹង ។ ហើយក៏បានដកទីតាំង កងទ័ពឲ្យដកពីកន្លែងពេទ្យហ្នឹងមកបានមកនៅក្នុងចំការដូងយើងនេះ គេហៅចំការដូងហើយហ្នឹង ខណ្ឌដង្កោនេះ ។ រួចខ្ញុំមកនៅជាមួយទ័ពវៀតណាមហ្នឹងទេ ។

**ស៖** លោកនៅជាមួយកងទ័ពវៀតណាម ប្រហែលជាប៉ុន្មានទៅ រយៈពេលប៉ុន្មានខែ ប៉ុន្មានឆ្នាំ?

**ឆ៖** បាទ, ខ្ញុំអត់បានចាំពេលវេលាទេ ប៉ុន្តែគ្រាន់តែថា នៅជាមួយកងទ័ពវៀតណាម ក៏មិនបានយូរប៉ុន្មានដែរ ដោយកងទ័ពវៀតណាម គេដកបន្តិច ខាងណេះខាងណោះ ហើយលោកតា កែវ ចិន្តា ក៏បានទៅស្នើសុំពីពួកខ្ញុំហ្នឹង យកមករស់នៅក្បែរផ្ទះគាត់ហ្នឹង ដោយមានស្ត្រីម្នាក់ជួយមើលហ្នឹង គាត់មានកូនពីរនាក់ផងដែរ ជួយមើលពួកខ្ញុំ ថែទាំពួកខ្ញុំហ្នឹង ហើយឲ្យពួកខ្ញុំហ្នឹងរៀននៅសាលារៀនវត្តកោះហ្នឹង ។

**ចៅក្រម ធូ មណី៖**

សូមអរគុណលោកប្រធាន! ខ្ញុំអស់សំណួរហើយ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម យ៉ា សុខន ។

**សួរដោយ ចៅក្រម យ៉ា សុខន៖**

**ស៖** សូមអរគុណលោកប្រធាន ។ នៅពេលលោកនៅរោងបាយ លោកមានស្គាល់អ្នកដាំបាយឈ្មោះ យាយ សុះ ទេ?

**ឆ៖** បាទ, សូមជម្រាបថា ខ្ញុំសូម្បីតែ អីអត់សូវចាំផង ហើយខ្ញុំអត់មានចាំគាត់ថា គាត់អ្នកដាំបាយអីទេ ប៉ុន្តែ គ្រាន់តែខ្ញុំមិនប៊ានសួរគាត់ផង ខ្លាចគាត់ទៀតណ៎ ។ ខ្ញុំអត់បានស្គាល់ឈ្មោះគាត់ទេ ។

**ស៖** នៅពេលលោកនៅរោងបាយហ្នឹង លោកមានបានជួបក្មេងពីរនាក់ទេ ដែលគាត់ថាជាកូនរបស់ឈ្មោះ ចេង អន? កូនប្រុសពីរនាក់ ប្រហែលជាប៉ុនៗលោកដែរកាលនោះ ជំនាន់នោះ?

**ឆ៖** បាទ, ពេលដែលមកខ្ញុំហ្នឹង ដូចខ្ញុំអត់មានបានឃើញក្មេងណាក្រៅពីពួកខ្ញុំទេ ។ ឃើញតែពួកខ្ញុំប្រាំនាក់ហ្នឹងមក ហើយបងស្រីម្នាក់ហ្នឹង ស្ត្រីចំណាស់ម្នាក់ហ្នឹងមើលពួកខ្ញុំហ្នឹង ។ តែប៉ុណ្ណឹងទេ អត់មានឃើញក្មេងណាដទៃទៀតទេ ។

**ចៅក្រម យ៉ា សុខន៖**

សូមអស់សំណួរហើយ លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ សូមប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ។ ប្រសិនបើមានសំណួរអ្វីត្រូវសួរដល់សាក្សី អ្នករស់រានមានជីវិតរូបនេះ សូមអញ្ជើញ ។

**សួរដោយ លោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ ហើយក៏សូមអរគុណផងដែរលោក នង ចាន់ផល ដែលបានអញ្ជើញមករៀបរាប់នៅខ្សែជីវិតដ៏ឈឺចាប់របស់លោក ជូនអង្គជំនុំជម្រះនៅថ្ងៃនេះ ។

**ស៖** សំណួរទីមួយ សូមសួរលោកថា តើនៅពេលណាដែលលោកបានដឹង ពីការបង្កើតសាលាក្ដីខ្មែរក្រហមនេះ?

[១៣:៤៩:៥៦]

**ឆ៖** ខ្ញុំអត់បានចាំដែរ ព្រោះដោយសារការងារខ្ញុំនៅឆ្ងាយពីទីប្រជុំជន ។ ហើយខ្ញុំបានដឹងចុងក្រោយថា នៅថ្ងៃដែលគេបិទ ការទទួលពាក្យហ្នឹងបានខ្ញុំវាយឺតពេល ។

**ស៖** អរគុណលោក ។ សំណួរទីពីរ ថាតើលោកដែលធ្លាប់ត្រូវសម្ភាសដោយមជ្ឈមណ្ឌលឯកសារកម្ពុជាទេ?

**ឆ៖** បាទ, ធ្លាប់បានសម្ភាសតាមមជ្ឈមណ្ឌលឯកសារកម្ពុជាពិតមែន ហើយនិងអ្នកកាសែតដទៃទៀតក៏បានសាកសួរខ្ញុំ អំពីរឿងទួលស្លែងនេះជាច្រើនតាំងពីឆ្នាំ៧៩ រហូតមកដល់បច្ចុប្បន្ន ។ តែក្រោយមកខ្ញុំមានការលំបាកក្នុងការជួបអ្នកកាសែត គេសួរច្រើនពេកទើបតែជិតបិទសវនាការ ជិតតែគេលែងទទួលពាក្យនេះហើយ បានជាខ្ញុំយឺតពេល ។ ខ្ញុំដាក់ពាក្យហ្នឹង ខ្ញុំមកយឺតពេល ។

**ស៖** អរគុណលោក ។ សំណួរទីបី សួរថាតើលោកធ្លាប់ដែលបានឃើញរូបភាព ហើយនិងភាពយន្តដែលកងទ័ពវៀតណាមហ្នឹង បានថតនៅក្នុងការចូលមកដល់ទីក្រុងភ្នំពេញ ហើយជាពិសេសបានទៅសារមន្ទីរទួលស្លែងហ្នឹងទេលោក?

**ឆ៖** បាទ, ពីមុនមកខ្ញុំអត់ដឹងថា មានខ្សែភាពយន្តហ្នឹងទេ ។ ហើយតែពួកខ្ញុំហ្នឹងទៅរស់នៅជាមួយលោកតា កែវ ចិន្ដា ហ្នឹង ហើយខ្ញុំដាក់កុមារកំព្រាហ្នឹងក៏អត់បានដឹងដែរ ។ ទើបតែពេលបច្ចុប្បន្ននេះខ្ញុំបានឃើញនូវមជ្ឈមណ្ឌលឯកសារកម្ពុជាគេមាន ហើយនិងនៅប៉ុស្ដិ៍ផ្សាយនៅប៉ុស្ដិ៍*ស៊ីធីអិន* ហ្នឹងខ្ញុំបានឃើញមែន ។ ហើយប៉ុស្ដិ៍ *ស៊ីធីអិន* ក៏គាត់បានទៅសម្ភាសខ្ញុំដល់កន្លែងការងារនៅខេត្តកំពង់ស្ពឺដែរ ។

**ស៖** អរគុណលោក ។ នៅក្នុងភាពយន្តនោះ តើលោកមានបានសម្គាល់ឃើញថា នៅក្នុងនោះមានរូបភាពរបស់លោក ប្អូនៗរបស់លោក ហើយនិងក្មេងដទៃទៀតដែលលោកបានរៀបរាប់ជូនអង្គជំនុំជម្រះនៅថ្ងៃនេះទេ?

**ឆ៖** បាទ, ខ្ញុំបានឃើញក្មេងៗទាំងអស់ហ្នឹង ហើយមកជាមួយខ្ញុំប្រាំនាក់ហ្នឹង បានឃើញ ។ ហើយបច្ចុប្បន្នហ្នឹង ម្នាក់ដែលស្លាប់នោះស្លាប់ហើយ ប៉ុន្តែក្រោយមក-- ខ្ញុំសុំឆ្លើយម្តងទៀតដោយច្រឡំ ។ ខ្ញុំបានឃើញរូបភាពហ្នឹងហើយ ហើយនិងឃើញពួកខ្ញុំហ្នឹង ហើយប្អូនខ្ញុំ ហើយនិងក្រុមក្មេងបីនាក់ទៀតហ្នឹង ។ តែបច្ចុប្បន្ននៅសល់-- ចេញមកអង្គាល់ថ្ងៃបែកហ្នឹងនៅសល់បួននាក់ ហើយពីរនាក់ទៀតក៏បានត្រូវជនជាតិអាល្លឺម៉ង់ថា ឮសួរសុំទៅជាកូនចញ្ចឹម ។ ហើយម្នាក់ទៀតក៏បានបាត់ដោយអត់មានដំណឹង នៅក្នុងមជ្ឈមណ្ឌលកុមារសង្គ្រោះទារកនៅជិតពេទ្យកាល់ម៉ែត្រ ។

[១៣:៥៣:០៩]

**ស៖** អរគុណលោក ។ ចុះប្រសិនបើ ខ្ញុំបង្ហាញរូបថតមួយសន្លឹក ដែលខ្ញុំបានយកចេញពីក្នុងខ្សែភាពយន្តនោះយកមកជូនលោកមើល តើលោកអាចចង្អុលបង្ហាញថា តើរូបណាមួយជារូបរបស់លោក ប្អូនរបស់លោក និងក្មេងៗដែលបានរស់រានមានជីវិតនៅពេលនោះបាទេ? មិនមែនយកជាខ្សែវីដេអូទេ គឺអានេះគេយករូបថតមួយសន្លឹក ដែលបានផ្តិតចេញពីក្នុងខ្សែភាពយន្តហ្នឹង ដើម្បីមកជូនជនរងគ្រោះដែលបាន-- នៅសេសសល់ពីការស្លាប់ហ្នឹង ដើម្បីមកបញ្ជាក់បន្ថែមថាតើ ជនរងគ្រោះនោះពិតជាបានស្គាល់ថា រូបភាពហ្នឹងដែលបានថតដោយកងទ័ពវៀតណាមនុំង ជារូបរបស់ខ្លួនដែរឬទេ? មិនបានយកភាពយន្តទាំងមូលទេ គឺយកតែរូបភាពមួយសន្លឹកដែលបង្ហាញពីក្មេងៗទាំងបួនប្រាំនាក់ហ្នឹង ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តីចង់មានមតិយោបល់អ្វីទៅ? សូមអញ្ជើញ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

លោកប្រធាន គឺខ្ញុំទ្រាំអត់បានទេ ដែលថាយើងលើកឡើងយករូបភាពមួយដែលដកស្រង់ចេញពីខ្សែវីដេអូ ដើម្បីឲ្យបង្ហាញនៅពេលនេះ ។ គឺយើងមិនទាន់បានចេញសេចក្តីសម្រេច ទៅលើបញ្ហាខ្សែភាពយន្តនេះនៅឡើយ ថាតើយើងគួរតែបញ្ចាំងខ្សែភាពយន្ត ឬក៏អត់? សហព្រះរាជអាជ្ញានៅពេលនេះ គឺបានចង្អុលចង់បង្ហាញរូបភាពមួយដែលដកស្រង់ចេញពីរូបខ្សែវីដេអូ ។ ដូច្នេះហើយ ប្រសិនបើធ្វើដូច្នោះមែន គឺខ្ញុំគិតថាយើងមិនអាចធ្វើទៅបាននោះទេ ។

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់មេធាវីការពារក្តីមានប្រសិទ្ធភាព ។ ការលើកឡើងនេះត្រឹមត្រូវ ព្រោះទោះបីជាផ្នែកមួយក៏ដោយក៏ជាវីដេអូដែលអង្គជំនុំជម្រះមិនទាន់សម្រេច ថាត្រូវលើកយកមកដេញដោលនោះដែរ ។

បានន័យថា ទាំងស្រុងហ្នឹងឯង គឺមិនទាន់បានដេញដោលទេ ដូច្នេះ ខាងសហព្រះរាជអាជ្ញា គឺប្តូរនូវការសួរនេះ ។ ចៀសវាង គឺការសួរពាក់ព័ន្ធជាមួយនឹងខ្សែវីដេអូ ដែលអង្គជំនុំជម្រះមិនទាន់បានសម្រេចសេចក្តីនៅឡើយក្នុងការថា ដាក់ដេញដោល នៅចំពោះមុខអង្គជំនុំជម្រះ ឬក៏អត់នោះ?

[១៣:៥៥:៤៦]

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** អរគុណ ។ សំណួរបន្តទៀត ជូនលោក នង ចាន់ផល នៅក្នុងរយៈពេលដែលលោកស្នាក់នៅក្នុងទួលស្លែងហ្នឹង មន្ទីរសន្តិសុខហ្នឹង ថាតើលោកមានបានដែលជួបតាៗ ហើយនិងអ្នកថត អ្នកគូររូប ជាងជួសម៉ាស៊ីននៅទីនោះដែរទេ? ក្នុងរយៈពេលដែលលោកបានស្នាក់នៅទីនោះ ហើយនិងរត់លេង និងញុំាបាយនៅទីនោះ?

**ឆ៖** បាទ, សូមជម្រាប! ខ្ញុំនៅក្នុងហ្នឹង នៅឈរ-- នៅកន្លែងម្ខាងនៅក្បែរទ្រុងជ្រូកនេះ ហើយចាស់ៗហ្នឹង គាត់នៅខាងស្តាំដៃនៅក្រោយអគារទីពីរ ។ ខ្ញុំក្រឡេកមើលឃើញតែពីចម្ងាយ ខ្ញុំអត់បានស្គាល់នរណាម្នាក់ទេ ។ ក្រោយមកថ្ងៃរំដោះហ្នឹង ខ្ញុំនៅកុមារកំព្រាកុលាបទីពីរហ្នឹង ខ្ញុំក៏បានដើរទៅលែងម្តុំហ្នឹង ហើយខ្ញុំក៏ស្គាល់ថា នេះជារបងគុកដែលខ្ញុំធ្លាប់មក ហើយគេប្រាប់ថា នេះជាកន្លែងគុក ។ ហើយខ្ញុំក៏បានចូលទៅ ចូលទៅគេ-- ខ្ញុំប្រាប់គេថា ខ្ញុំជាក្មេងសល់ពីហ្នឹង នៅធ្លាប់មកហ្នឹង ហើយបានស្គាល់ តាគង់ ហ្នឹង ។ តាគង់ ហ្នឹង គាត់មិនដឹងជាជាងខ្មោះមិនដឹងជាងអី គាត់នៅក្នុងរោងជាងដែរ គាត់បានប្រាប់ខ្ញុំថា ឃើញធ្លាប់ឃើញខ្ញុំ មើលមកខ្ញុំ ខ្ញុំមើលទៅគាត់ពីចម្ងាយមើលអត់ច្បាស់ទេ ប៉ុន្តែគាត់-- បាទ ខ្ញុំស្គាល់គាត់ដល់ថ្ងៃបែកហើយ ។

**ស៖** អរគុណ លោក នង ចាន់ផល ។ ប្រសិនបើអង្គជំនុំជម្រះ យកផែនទីទីតាំងរបស់សារមន្ទីរទួលស្លែងដែលជាអតីតគុកមន្ទីរស-២១នេះ ជូនលោកមើល ។ តើលោកអាចចង្អុលបង្ហាញ ជូនអង្គជំនុំជម្រះ ថាតើទីណា កន្លែងណាដែលគេយកលោក ម្តាយរបស់លោក និងប្អូនៗហ្នឹងមកដល់មុនគេ? ហើយក្រោយពីគេថតរូបរួចហ្នឹង តើគេយកលោកម្តាយលោក និងប្អូនៗនោះចូលទៅកាន់ទីតាំងអគារណាមួយ តាមដែលលោកអាចចងចាំបានហ្នឹង ជូនអង្គជំនុំជម្រះពេលហ្នឹងបានទេ?

**ឆ៖** បាទ, ខ្ញុំជម្រាបថាបាន ។ ខ្ញុំស្គាល់ ខ្ញុំនៅចាំបាន ។

**លោក តាន់ សេណារ៉ុង៖**

អ៊ីចឹង សុំលោក-- អនុញ្ញាតពីលោកប្រធានដើម្បីឲ្យខាងសោតទស្សន៍ បង្ហាញនូវរូបភាពទីតាំង

រួមរបស់សារមន្ទីរទួលស្លែងហ្នឹង ដើម្បីឲ្យសាក្សីហ្នឹងបានចង្អុលបង្ហាញពីទីតាំង ទីកន្លែងនៅការមកដល់ និងការចាប់ខ្លួន ។ បានទេបាទ?

[១៣:៥៨:២៨]

**ប្រធានអង្គជំនុំ៖**

លោកចាំទេថា រូបភាពហ្នឹង មានលេខសម្គាល់អត្តសញ្ញាណយ៉ាងម៉េចដែរ?

**លោក តាន់ សេណារ៉ុង៖**

ក្នុងនោះដែលមានលេខ D45 ។ រូបភាពហ្នឹង អង្គជំនុំជម្រះហ្នឹង ខាងការិយាល័យសហព្រះរាជអាជ្ញាហ្នឹង ធ្លាប់បានជូនលោក ដុំ ម៉ី ហ្នឹងចង្អុលបង្ហាញម្តងរួចមកហើយ ដែលទីតាំងរួមដែលថតពីលើអាកាសហ្នឹង ដែលមានលេខ D45--*(ត្រេពីរ)* ធ្លាប់បានបង្ហាញគាត់ពីថ្ងៃមុន ហើយដែលមានលេខ ERN 00195373 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីផ្នែកសោតទស្សន៍បញ្ចាំងនូវរូបណាមួយដែលមានលេខ ERN 00195373 ដែលជារូបភាពបង្ហាញពីទីតាំងនៃមន្ទីរស-២១ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** លោកពិនិត្យមើល៍ លោកឃើញនេះជាទីតាំងអគារនៃសារមន្ទីរទួលស្លែងទាំងមូល ដែលថតពីលើអាកាស ។ ហើយដែលដាក់អក្សរឆ្វេងដៃគេបង្អស់គឺ អគារ “ក” អគារកាត់ទទឹងនោះ គឺអគារ“ខ” ។ អគារមួយទៀតនេះ គឺអគារ “គ” ហើយនិងអក្សរ “D” ហ្នឹង គឺអក្សរ “ឃ” ហើយអគារកណ្តាលហ្នឹងអក្សរ “ង” ។ ថាតើទីតាំងណាមួយដែលគេយកលោក ម្តាយលោក ហើយនិងប្អូនៗនោះចូលមកដល់មុនគេ? នៅផ្នែកខាងក្រោមហ្នឹង គឺជាខាងកើត គឺទ្វារធំបច្ចុប្បន្នហ្នឹង ។ នេះកន្លែងកូនព្រួញមួយតូចៗហ្នឹង គឺជាភ្លោងទ្វារមុខបច្ចុប្បន្នហ្នឹង នៃសារមន្ទីរទួលស្លែងហ្នឹង ។ ថាតើថ្ងៃដំបូងដែលយកមកដល់ចូលមកកន្លែងណា?

**ឆ៖** ខ្ញុំចាំបានថា ពេលដែលចុះពីរថយន្តហ្នឹង គេត្រូវបញ្ជូនខ្ញុំចូលនៅក្នុងប៉ុយរ៉ូខាងមុខហ្នឹងមានជញ្ជាំងពណ៌ស ហើយកម្រាលឥដ្ឋការ៉ូហ្នឹង មានអ្នកថតនៅហ្នឹង មានអ្នកថតអត់ដឹងថាប៉ុន្មាននាក់អត់ចាំបានដែរ ប៉ុន្តែមានអ្នកថត ។ ក្រោយមកចេញពីក្នុងហ្នឹងមក គាត់ចេញមកខាងស្តាំប៉ុយរ៉ូហ្នឹង ដើរខាងស្តាំតម្រង់ទៅអគារ បច្ចុប្បន្នអគារនេះបើតាមខ្ញុំមើលក្នុងនេះឃើញជាអក្សរ “C” ចូលជណ្តើរ

ហើយបានបត់មកឆ្វេងឡើងជណ្ដើរទៅជាន់ទីមួយ ជាន់ទីពីរបណ្ដោយ ។ ហើយនៅបន្ទប់ទីពីរហ្នឹង ម្ដាយខ្ញុំនៅក្នុងអគារ “C” ហ្នឹងបន្ទប់ទីពីរ-- ជាន់ទីពីរ បន្ទប់ទីពីរ ។

[១៤:០២:២៧]

**ស៖** បន្តមួយទៀតជូនលោក ថាតើកន្លែងដែលលោកបានទៅញ៉ាំបាយនិងរត់ ហើយនិងស្នាក់នៅខាងក្រោយ ដែលលោកបានរៀបរាប់ជូនអង្គជំនុំជម្រះហ្នឹង នៅផ្នែកខាងណានៃអគារទាំងប្រាំហ្នឹង?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា នៅក្នុងពេលដែលខ្ញុំចុះទៅខាងក្រោយរោងជាងហ្នឹង គឺនៅខាងក្រោយជ្រុងខាងលិចនៃអគារ “C” ផ្ទៀងបន្តិច គឺខ្ញុំអាចមើលឃើញចន្លោះទ្វារហ្នឹងមក ។ វាសឹងថាខ្ញុំនៅចំពាក់កណ្ដាល ប៉ុន្តែវានៅកៀកទ្រុងជ្រូក នៅក្បែរទ្រុងជ្រូកជាងគេ ដោយសារខ្ញុំមើលទៅអាបន្ទប់ទីពីរ អគារ “C” ហ្នឹង ខ្ញុំមើលឃើញ ។ ហើយខ្ញុំមើលទៅខាងស្ដាំ ឃើញមើលទៅតាៗចាស់ ហើយមានរោងជាងនៅកន្លែងធ្វើជាងហ្នឹង ឃើញមានដំអីភីងផ្ទូង មិនដឹងថាគាត់ធ្វើអីខ្លះ ។ នៅខាងស្ដាំដៃខ្ញុំហ្នឹង វារោងជាងហ្នឹងវានៅក្រោយអគារ “B” ហ្នឹង ។

**លោក តាន់ សេណារ៉ុង៖**

អគុណលោក នង ចាន់ផល ដែលលោកបានរៀបរាប់នូវការចងចាំ របស់លោកត្រួសៗជូនអង្គជំនុំជម្រះថ្ងៃនេះ ។ ខ្ញុំអស់សំណួរ ហើយអរគុណលោកប្រធានអង្គជំនុំជម្រះ ខ្ញុំនឹងជូននាទីបន្ទាប់ទៅសហការីរបស់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយ លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។ សូមជម្រាបសួរលោក នង ចាន់ផល ។

**ស៖** ខ្ញុំបន្តសំណួរពីសហសេវិកខ្ញុំ លោកបញ្ជាក់ថា រោងជាងដែលបាននៅនោះ គឺថានៅខាងក្រោយអគារ “C” នៅខាងលិច ថាតើស-២១ នោះ គឺនៅជិតរោងជាងហ្នឹង គ្រាន់តែរោងជាងហ្នឹងនៅខាងក្រៅមែនឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា បើអគារហ្នឹងមួយមក មានរបង ។ របងហ្នឹងហើយ របងលួសសំណាញ់ហ្នឹងជាច្រើនជាន់ណាស់ ប្រហែលជាស្មុគស្មាញ ។ សំណាញ់នេះវាមានភាពរញ៉េរញ៉ៃ ហើយបន្ទប់ពីររបងហ្នឹងមក គឺរោងជាងខាងក្រោយហ្នឹង ។ ពិតមែនបាទ ។

[១៤:០៤:៥០]

**ស៖** ហើយបន្ទាប់ពីរោងជាងនោះ នៅខាងលិចនោះ ថាតើមានច្រកទ្វារចេញពីខាងលិចទៅកន្លែងនោះដែរឬទេ ពីស-២១ខាងក្នុងទៅនោះ?

**ឆ៖** សុំសំណួរនេះម្តងទៀត ដោយសារនៅខាងរោងជាងដែលគាត់សួរខាងនៅក្នុងបរិវេណគុកហ្នឹង?

**ស៖** លោកនិយាយថា រោងជាងនោះនៅខាងក្រោយអគារ“C” អគារ“គ” ដែលថានៅខាងលិចនៃរោងជាង ថាតើមានច្រកទ្វារ មានច្រកចេញពីបរិវេណស-២១ ហ្នឹងទៅកន្លែងនោះដែរឬទេ?

**ឆ៖** បាទ, នៅខាងក្រោយនោះបើតាមខ្ញុំមើលទៅជាវាលហើយ ហើយមានដើមអំពិលទឹកដើមស្វាយ ហើយខ្ញុំអត់បានចាំដែរថា វាមានច្រកចេញខាងក្រោយទៀតក៏អត់ដឹងដែរ ខ្ញុំអត់ចាំបានចាំបានទេ ។

**ស៖** នៅក្នុងការឆ្លើយទៅនឹងសំណួររបស់ចៅក្រមឡាវែន៍ លោកប្រាប់ថា លោកបានចេញពីច្រកទ្វារមួយខាងកើតនៃស-២១ ថាតើនៅពេលដែលលោកចាកចេញជាមួយវៀតណាមនោះ ថាតើចេញច្រកខាងកើត ឬក៏ខាងលិច?

**ឆ៖** បាទ, ចំពោះទ្វារខាងលិចគឺអត់ ខ្ញុំអត់ដឹងថាមានទ្វារខាងលិចទេ ប៉ុន្តែដឹងថា ខាងមុខគុកខាងកើតមានមួយ ខាងក្រោយគុកមានមួយ ។ ប៉ុន្តែ ដល់ខាងក្រោយមិនដឹងខាងលិច ឬខាងណា ខ្ញុំអត់ចាំបាន ដែរ ប៉ុនដឹងថា មានទ្វារពីរ ខាងក្រោយមានទ្វារមួយ ខាងមុខមានទ្វារមួយ ។ ហើយពេលចេញមកខ្ញុំជិះឡានហ្នឹង វាមានទ័ពវៀតណាមហើយនិងទ័ពរណសិរ្សខ្មែរយើងគេថា ទ័ពរណសិរ្សខ្ញុំចេះតែថាតាមគេទៅបច្ចុប្បន្ន ។ ហើយខ្ញុំបានឡើងជិះឡាននោះ មនុស្សច្រើនរោមខ្ញុំអ្ហូ អ៊ឹចឹង ខ្ញុំមិនដឹងថាឡានហ្នឹងវាបត់ទៅឆ្វេង ឬក៏ស្តាំទេ ហើយយកខ្ញុំមកចូលក្នុងមន្ទីរពេទ្យ បច្ចុប្បន្នខ្ញុំនៅចាំបាន ឥឡូវពេទ្យសម្តេចក្រុងយើងសព្វថ្ងៃ ។

**ស៖** សូមអរគុណ តើលោកប្រាកដទេ នៅពេលដែលលោកចាកចេញពីស-២១ ពីក្លោងទ្វារខាងមុខ ឬខាងក្រោយ? តើច្បាស់ប្រាកដណាមួយ?

**ឆ៖** បាទ, ខ្ញុំប្រាកដណាស់ ចេញតាមទ្វារខាងមុខដោយគេបីពួកខ្ញុំចេញពីខាងរោងជាងខាងក្រោយទៅដើរទៅខាងមុខហើយឡើងឡានតែម្តង ។ គ្រាន់តែមិនដឹងថាបត់ទៅខាងស្តាំ ឬក៏ខាងឆ្វេងគុកទេ ខ្ញុំអត់បានចាំ ។

**ស៖** សូមអរគុណលោក នង ចាន់ផល ។ អង្គជំនុំជម្រះបានសួរលោកថាតើលោកមានភស្តុតាងអ្វីបង្ហាញទេថា ឪពុករបស់លោកត្រូវបានគេចាប់ហើយបញ្ជូនទៅស-២១ ។ ខ្ញុំនឹងបង្ហាញឯកសារមួយ E5/12/1 លេខERN នៅក្នុងភាសាខ្មែរ 00289900 នៅក្នុងភាសាបារាំង 00291146 ហើយនៅក្នុងភាសាអង់គ្លេស 00289887 ។ លោកប្រធាន សូមលោកប្រធានអនុញ្ញាតដើម្បីបង្ហាញអត្ថបទជាភាសាខ្មែរលើអេក្រង់កុំព្យូទ័រ ។

[១៤:០៨:៤០]

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ អាចបញ្ចាំងនូវឯកសារដែលមានលេខ ERN 00289900 លើអេក្រង់ទូរទស្សន៍ ។

**សួរដោយលោក វីលៀម ស្មីត៖**

**ស៖** លោក នង ចាន់ផល នេះគឺជាប្រវត្តិរូបអ្នកទោស អ្នកជាប់ឃុំឃាំងនៅស-២១ ។ លោកពិនិត្យ មើលឈ្មោះនៅលើនេះ ហើយនិងសេចក្ដីលម្អិតផ្សេងៗទៀតទាក់ទងទៅនឹងប្រវត្តិរូបនេះហើយ តើអាចប្រាប់តុលាការបានទេ ថាតើលោកស្គាល់បុគ្គលម្នាក់នេះដូចម្ដេចដែរ?

**ឆ៖** ខ្ញុំកាលពីនៅក្មេងខ្ញុំអត់បានចេះអក្សរ អត់ទាន់បានរៀនសូត្រទេ ប៉ុន្តែបច្ចុប្បន្នខ្ញុំចេះ ខ្ញុំអាចអានអក្សរខ្មែរបានល្អ ខ្ញុំដឹងថានេះ ពិតជាប្រវត្តិរូបរបស់ឪពុកខ្ញុំមែន ។ ដោយថាមាន គាត់មានឈ្មោះមានម្ដាយ មានយាយ ហើយជាពិសេសនៅភូមិឃុំស្រុកខ្ញុំហ្នឹងតែម្ដង។ ដោយភូមិ និងស្រុកកំណើតដែលខ្ញុំកើតជានៅស្រុកភូមិដំណាក់ស្នួល ឃុំស្រែខ្ទុង ស្រុកឈូក ហ្នឹងពិតមែន ។ ហើយឈ្មោះឪពុកម្ដាយខ្ញុំនឹងសុទ្ធតែត្រូវទៀត ។ ហើយទីកន្លែងដែលគាត់រស់នៅហ្នឹង គឺកន្លែងដែលគេអារកំណល់រទេះភ្លើងមែន គឺជាសហករណ៍មួយមានរោងម៉ាស៊ីនអារឈើច្រើន អារឈើគរវាប់ម៉ឺនម៉ែត្រគូបនៅតំបន់ហ្នឹង នៅស្រុកភូមិត្រែងត្រយឹងនេះ ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកចៅក្រម នេះជាប្រវត្តិរូបអ្នកទោសអ្នកជាប់ឃុំឃាំងមកពីស-២១ ។

សូមអរគុណលោក ចាន់ផល ដែលលោកបានអញ្ជើញមកតុលាការថ្ងៃនេះ ។ ខ្ញុំមិនមានសំណួរអ្វីផ្សេងទៀតទេលោកប្រធាន ។

[១៤:១០:៤៤]

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍បង្វែររូបភាព មកជារូបភាពធម្មតាឡើងវិញ ។ ហើយជាកិច្ចបន្តនេះគឺដល់វេទិការបស់មេធាវីការពារក្តី ។ ហើយឥឡូវនេះលោកមេធាវី ខាងមេធាវីការពារក្តីតើមានសំណួរអ្វីត្រូវសួរ? មេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី តើមានសំណួរអ្វីចង់សួរដល់សាក្សីរូបនេះដែរឬទេ? បើមានសូមអញ្ជើញ។ ក្រុមណាមុន? ក្រុមមួយ?

**លោក អាឡាំង វែនណឺ៖**

សូមគោរពលោក លោកស្រីចៅក្រម! ខ្ញុំសូមការអនុញ្ញាតពីអង្គសវនាការ។ សាក្សីនេះគឺគាត់ជាសាក្សីមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ដូច្នេះ គឺយើងមានការរៀបចំនៅក្នុងក្រុមរបស់យើង ហើយក្រុមរបស់ខ្ញុំនេះនឹងសួរសំណួរសាមសិបនាទី ។ ដូច្នេះ ខ្ញុំសូមចាប់ផ្តើមក្នុងការរៀបចំក្នុងចំណោមគ្នាខ្ញុំនេះ ។

**ប្រធានអង្គជំនុំ៖**

រៀបចំបានឬនៅ ឥឡូវ? អញ្ជើញអ្នកណាសួរមុន ឥឡូវហ្នឹង? មានពេលវេលាសែសិបនាទីសរុប ។

**សួរដោយលោក អាឡាំង វែនណឺ៖**

សូមអរគុណ។ ហើយសូមជម្រាបសួរលោក នង ចាន់ផល ។ ខ្ញុំជម្រាបជាបឋមក្នុងនាមក្រុមរបស់ខ្ញុំ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកដែលមកចូលរួមនៅក្នុងថ្ងៃនេះ ។ ខ្ញុំដឹងថាវាមិនមានភាពងាយស្រួលនោះទេចំពោះលោក ។ ហើយខ្ញុំនឹងសួរសំណួរឲ្យបានខ្លីតាមដែលអាចធ្វើទៅបានចំពោះសំណួររបស់ខ្ញុំ ។ ហើយខ្ញុំសូមបំភ្លឺទៅលើបញ្ហាមួយចំនួនតែប៉ុណ្ណោះ ។

**ស៖** ជាបឋមលោក នង ចាន់ផល លោកបានជម្រាបជូនយើងខ្ញុំថា បន្ទាប់ពីឪពុករបស់លោកត្រូវបានគេចាប់ខ្លួន លោកនៅជាមួយនឹងម្តាយនិងប្អូនពៅរបស់លោក ។ ហើយលោកនិយាយថា ម្តាយនោះរង់ចាំឪពុករបស់លោក តើលោកអាចប្រាប់យើងខ្ញុំដែរឬទេ ថាតើម្តាយរបស់លោកមានបានធ្វើការស្វែងសួររកឪពុករបស់លោកដែរឬទេ ដែលគាត់ទៅឆ្ងាយនោះ?

**ឆ៖** ខ្ញុំសូមទៅថា កាលជំនាន់នោះ ម្តាយខ្ញុំ មានតែខ្ញុំទេសួររកឪពុកខ្ញុំ "ម៉ែ! មើលទៅថ្ងៃណាបានឪពុកខ្ញុំគាត់ត្រឡប់មកវិញ?" ម្តាយខ្ញុំគាត់មានការព្រួយបារម្ភ គាត់ថាមិនដឹងជាថ្ងៃណាទេ ចាំចេះតែពេលយូរមកហើយ ។ ហើយម្តាយខ្ញុំក៏អត់ដែលប៊ានសួរអ្នកណាក្រៅពីអ្នកដែលគាត់ស្គាល់ទេ ។ ទីមួយ

កាលណាគាត់ស្គាល់ច្បាស់បានគាត់ហ៊ានសួរ ។ អ្នកណាដែលអត់ស្គាល់ច្បាស់ គាត់អត់ហ៊ានសួរគេទេ។ ហើយខ្ញុំចេះតែសួរសុខទុក្ខគាត់តៗមក រៀងមករហូត ។

[១៤:១៤:២១]

**ស៖** លោកដឹងទេ តើហេតុអ្វីបានជាគាត់មិនទៅសួរគេឯងនៅពេលនោះ?

**ឆ៖** ខ្ញុំអត់បានដឹងដែរ ដោយសារម្ដាយខ្ញុំមានការភ័យខ្លាចអីដឹង គាត់មានព្រួយបារម្ភរឿងអីខ្ញុំអត់ដឹងដែរ ដោយសារ ពេលដែលខ្ញុំសួរទៅគាត់ហាក់បីដូចជាគ្មានហ៊ានសួរអ្នកណាផ្សេងទៀតដែរ ក្រៅពីអ្នកស្គាល់គាត់ ។

**ស៖** លោកបានជម្រាបយើងខ្ញុំហើយខ្ញុំសូមឲ្យបំភ្លឺ ។ នៅពេលដែលលោកទៅដល់ជាមួយម្ដាយរបស់លោកនៅទួលស្លែង លោកនិយាយថាម្ដាយរបស់លោកឈឺ ហើយលោកបានលើកឡើងថា គេច្រានម្ដាយរបស់លោកទៅវិញទៅមក ហើយម្ដាយរបស់លោកមានការតក់ស្លុតនិងភិតភ័យណាស់ ថាតើម្ដាយរបស់លោកត្រូវបានគេវាយតប់ដែរឬទេ នៅពេលដែលលោក ម្ដាយនិងលោក ហ្នឹងបានទៅដល់ទួលស្លែងហើយថតរូបនោះ?

**ឆ៖** បាទ, ដល់ចំណុចនេះវា ខ្ញុំនៅចាំបាន ។ នៅដល់ពេល ខ្ញុំចុះពីលើរថយន្តទៅធម្មតាកាលពីខ្ញុំនៅស្រុកត្រែងត្រយឹងហ្នឹងមានតែគេនិយាយពាក្យល្អៗមកកាន់គាត់ ។ គេហៅម្ដាយខ្ញុំអ្នកមីងៗអីចឹង។ ដល់ពេលគាត់ចូលទៅដល់ទួលស្លែងហ្នឹងគេសម្លុតគាត់ រុញច្រានគាត់អីចឹងទៅ ឲ្យគាត់ឈរនៅមុខម៉ាស៊ីនថត ខ្ញុំនៅចាំបានហាក់ដូចមានដាក់អីនៅពីមុខដូចជាម៉ាស៊ីនថតបច្ចុប្បន្នអីចឹង។ ហើយមានការរុញគាត់ ឲ្យឈរឲ្យត្រង់ ឈរអីៗអីចឹងទៅ គាត់ធ្វើមិនត្រូវ ដោយគាត់មានជំងឺហើមផង គាត់រុញគាត់ច្រានទៅលិចទៅកើត ហើយជួនណាខ្ញុំឃើញគេរុញគាត់ចង់ដួល ហើយទាញសក់គាត់មកក្រោយ ។ *(សាក្សីរន្ធត់ចិត្ត)* មកដល់ ចំណុចនេះធ្វើឲ្យខ្ញុំនឹកឃើញដដែលៗ ថ្មីៗ គេបានទះគាត់ ហើយជន្ល យកជើងរកធាក់គាត់ គាត់ផ្កាប់មុខ ទៅលើកម្រាលឥដ្ឋទម្រាំគាត់ធ្វើត្រូវ បីបួនដង ទម្រាំឈរឲ្យគេថតហើយហ្នឹង ។

[១៤:១៧:០០]

**ស៖** ចាតើលោកអាចបន្តឆ្លើយសំណួររបស់ខ្ញុំដែរឬទេ? ខ្ញុំនឹងមិនសួរច្រើនទេទៅដល់លោកហើយ ខ្ញុំនឹងចំណាយពេលតែបន្តិចតែប៉ុណ្ណោះ ។

**ឆ៖** បាទ, បាន ។

**ស៖** លោកបានពន្យល់ប្រាប់អង្គសវនាការនេះថា បន្ទាប់ពីគេបំបែកលោកចេញពីម្តាយ លោកនៅរោងជាងមួយនោះជាមួយនឹងស្ត្រីម្នាក់ដែលគាត់ទទួលខុសត្រូវមើលក្មេងៗ ។ ហើយបន្ទាប់មកលោកពន្យល់ចំនួនក្មេងនៅទីនោះ នៅពេលដែលស្ត្រីហ្នឹងគាត់ចាកចេញ ប៉ុន្តែ នៅចំណុចនេះខ្ញុំហាក់ដូចជាមិនយល់ច្បាស់ នៅពេលដែលលោកនៅទួលស្លែងជាមួយស្ត្រីនៅខាងក្រោយរោងនោះ ថាតើក្មេងទាំងអស់នោះមានចំនួនប៉ុន្មានដែលនៅជាមួយស្ត្រីនោះ បើសិនជាតាមការចងចាំរបស់លោក?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ខ្ញុំនៅចងចាំបានថា អត់ដូចជាគ្មានបានឃើញក្មេងណាដទៃទៀតទេ ឃើញតែពួកខ្ញុំហ្នឹងប្រាំនាក់ហ្នឹងមក ហើយស្ត្រីចំណាស់ម្នាក់ហ្នឹងមើលពួកខ្ញុំហ្នឹង។ ឃើញតែប៉ុណ្ណឹង តែប៉ុណ្ណឹងខ្ញុំចាំបានតែប៉ុណ្ណឹង ។

**ស៖** ខ្ញុំសូមធ្វើការបំភ្លឺ លោកនិយាយអំពីស្ត្រីម្នាក់ដែលគាត់មើលក្មេងនៅទីនុ៎ង ។ ហើយបន្ទាប់មកលោកនិយាយអំពីស្ត្រីដែលគាត់ចេញនៅចុងក្រោយ ហើយគាត់ហៅលោកឲ្យទៅជាមួយគាត់ហើយលោកមិនទៅ។ ថាតើលោកនិយាយថា ស្ត្រីហ្នឹងគឺស្ត្រីតែមួយ ឬយ៉ាងម៉េច?

**ឆ៖** បាទ, ស្ត្រីដែលមើលពួកខ្ញុំហ្នឹងហើយដែលគាត់ហៅពួកខ្ញុំចេញឲ្យចេញ រត់ចេញទៅជាមួយគាត់ ។ ដោយខ្ញុំគិតថាក្រែងម្តាយខ្ញុំរកខ្ញុំមិនឃើញ បានខ្ញុំអត់ព្រមទៅ ខ្ញុំសុខចិត្តនៅចាំនៅខាងក្រោយនោះដដែលហ្នឹង ។

**ស៖** នៅពេលដែលស្ត្រីនោះចេញទៅ ហើយខ្ញុំដឹងថា លោកមិនទៅជាមួយគាត់ទេ ថាតើស្ត្រីនោះ គាត់ទៅជាមួយគេផ្សេងដែរឬទេ? ឬក៏គាត់ទៅជាមួយក្មេងៗផ្សេងៗទៀតដែរឬទេ?

**ឆ៖** បាទ, ខ្ញុំអត់បានចាំដែរ ដូចថាឃើញតែគាត់ចេញតែពីខ្ញុំផុត ខ្ញុំរត់ចេញទៅដល់ច្រកទ្វារខាងក្រោយចេញទៅចូលទៅក្នុងគុកហ្នឹង ខ្ញុំអត់បានមើលទៅមុខតទៅទៀតទេ ដូចជាគ្មានឃើញនរណាទេ ខ្ញុំបានរត់មកខាងក្រោយវិញដដែល អត់មានរត់ទៅតាមគាត់ទេ ។

**ស៖** ខ្ញុំសូមបំភ្លឺទៅលើចំណុចមួយចំនួនដែលលោកបានជម្រាបអង្គសវនាការ ។ ចៅក្រមឡាវ៉ែន៍បានសួរលោកថា លោកបានធ្លាប់ឮសំឡេងអ្វីដែរឬទេ? ហើយលោកបាននិយាយថា លោកបានឮសំឡេង។ ថាតើសំឡេងយ៉ាងម៉េចដែរលោកបានឮ? តើសំឡេងហ្នឹងវាយ៉ាងម៉េច សំឡេងនុ៎ង?

**ឆ៖** បាទ, សំឡេងនោះ បើតាមការចងចាំរបស់ខ្ញុំ វាដូចជាសំឡេងសម្រែកម្តងម្កាល ប៉ុន្តែមិនដឹងថា ស្រែកនោះស្រែកក្រោយការឈឺចាប់ ឬក៏ស្រែក-- ឮសូរតែល្វើយៗ ពេលដែលខ្ញុំឮសំឡេងហ្នឹងហើយ ខ្ញុំចោលភ្នែកមករកមើលបន្ទប់ ដែលម៉ែខ្ញុំឈរ ។ បន្ទប់ទីពី ជាន់ទីពីរនោះ គាត់ឈរតោង

ចម្រឹងដែកដៃទាំងពីរមើលមកខ្ញុំនោះ ពេលដែលខ្ញុំឮសំឡេងហ្នឹង ខ្ញុំចោលភ្នែកទៅមើលរកម្ដាយខ្ញុំនៅលើបន្ទប់នោះ ។ ពេលដែលខ្ញុំមើលទៅអត់ឃើញម្ដាយខ្ញុំទេ ឮតែសម្រែក មិនដឹងសម្រែកនុ៎ងចេញល្វើយៗពីក្នុងអគារទីហ្នឹងមក អគារ១ទីបីហ្នឹង ខ្ញុំនៅចាំថានៅអគារទីបីហ្នឹង ។

**ស៖** ខ្ញុំសូមធ្វើការបំភ្លឺ ដោយសារតែខ្ញុំចង់ឲ្យច្បាស់ ។ អ៊ីចឹង គឺបានន័យថា លោកបានឮសំឡេងហ្នឹងច្រើនជាងម្ដង បានន័យថាបានឮលើសពីម្ដង ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ត្រឹមត្រូវ ។ ព្រោះពេលដែលខ្ញុំនឹងនៅអង្គុយនៅខាងក្រោយ ទ្រុងជ្រូកខាង រោងជាងខាងក្រោយ ជួនកាលខ្ញុំឮសំឡេងម្ដង ឬក៏ពីរដង ។ ខ្ញុំតែងតែក្រឡេកទៅរកមើលតែបង្អួចដែលម៉ែខ្ញុំតោងចម្រឹងបង្អួចមើលមកពួកខ្ញុំហ្នឹង ។

**ស៖** នៅពេលដែលលោកនៅខាងក្រោយរោងនោះ ដែលស្ត្រីនោះមើលលោក តើលោកធ្លាប់ឃើញអ្នកទោសផ្សេងៗទៀតដែរឬទេ?

**ឆ៖** បាទ, អ្នកទោសផ្សេងទៀត ខ្ញុំអត់បានឃើញទេ ។

**ស៖** ឆ្លើយសំណួរមួយនោះលោកបានលើកឡើងថា គឺមានជាងដែកមួយ ជាងដែកនោះគាត់ថាគាត់ឃើញលោកនៅពេលនៅ ស-២១ ថាតើលោកនៅចាំជាងដែកនោះដែរ ឬទេ?

[១៤:២២:៥៤]

**ឆ៖** បាទ, បើខ្ញុំនៅចាំជាងនោះ គាត់ជាង-- គាត់ប្រាប់ថាគាត់ជាដំខ្នោះក្រោយពេលថ្ងៃរំដោះខ្ញុំបានជួបគាត់ គាត់ប្រាប់ថា គាត់ជាងខ្នោះដំដែកនៅខាងក្រោយរោងជាងហ្នឹង ។ គាត់បានឃើញពួកខ្ញុំដែរ ហើយខ្ញុំក៏មើលទៅគាត់ដែរ ប៉ុន្តែខ្ញុំអត់បានដើរទៅជិតទៅគាត់ទេ ដោយមានគេហាមប្រាមអត់ឲ្យដើរទៅណា ខ្ញុំមើលឃើញតែចាស់ៗ ។ មើលទៅពីចម្ងាយឃើញប្រហែលជាបួននាក់ ។ ដោយខ្ញុំចាំមិនច្បាស់ បើគ្រាន់តែឃើញចាស់ៗ ប៉ុន្តែ តាគង់ ហ្នឹង ខ្ញុំបែកហើយបានជួបគាត់ ។ គាត់នៅធ្វើ-- សុំគេធ្វើការនៅទួលស្លែងជាអ្នកថែសួន ហើយគាត់មានសភាពចាស់ជរាចាស់មែនទែនហើយ ។

**ស៖** ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ថា តើ តាគង់ ហ្នឹងគាត់ជាអ្នកធ្វើខ្នោះ ឬយ៉ាងម៉េច? ខ្នោះជើង?

**ឆ៖** បាទ,សូមបញ្ជាក់ថា គាត់ប្រាប់ខ្ញុំនឹងកាលពីវានៅក្នុងរោងជាងខាងក្រោយហ្នឹង មុនថ្ងៃរំដោះ ហ្នឹងខ្ញុំក្រឡេកឃើញទៅគាត់មានឃើញគាត់ធ្វើការធម្មតាដូចជាជាងមើលពីចម្ងាយមានការដំផ្លុងភាំងអីអ៊ីចឹង ឮ។ ដល់ពេលក្រោយ ខ្ញុំជួបគាត់នៅថ្ងៃបែកហើយហ្នឹង ខ្ញុំទៅលេងទួលស្លែងបានជួបគាត់ហើយគាត់ក៏ស្គាល់ ខ្ញុំអត់បានស្គាល់គាត់ដែរ មើលពីចម្ងាយ ប៉ុន្តែគាត់ស្គាល់ខ្ញុំ ហើយគាត់ហៅខ្ញុំសួរសុខ

ទុកធម្មតាអ៊ីចឹង ។ គាត់មានការអាណិតអាសូរដល់ខ្ញុំមានជូនលុយកាក់ដល់ខ្ញុំ ហើយដេញឲ្យខ្ញុំមកកន្លែងកុមារកំព្រារៀនសូត្រវិញ ។ ប៉ុណ្ណឹង ។

**ស៖** លោកនិយាយអំពីគំនរខោអាវ ហើយលោកបាននិយាយថាលោកលាក់ខ្លួននៅក្នុងគំនរខោអាវហ្នឹង និងនៅក្រោយទូ និងតុអីផ្សេងៗ ។ ថាតើលោកបានដឹងព័ត៌មាន ឬក៏ដឹងយ៉ាងម៉េចអំពីខោអាវសម្លៀកបំពាក់ដែលនៅជាគំនរនោះ?

**ឆ៖** បើតាមខ្ញុំដឹងថា បើតាមខ្ញុំនៅចងចាំ វាជាកំណាត់ខោអាវចាស់ៗដែលគេបោះចោល ហើយខ្ញុំមិនដឹងថា ខោអាវហ្នឹងជាខោអាវអ្នកណាទេ អត់ដឹងទេ ។ ខ្ញុំដឹង ឃើញតែប៉ុណ្ណឹង ។

**ស៖** ក្រោយមក តើគេមានប្រាប់លោកអំពីខោអាវហ្នឹងដែរ ឬទេ?

**ឆ៖** បាទ, ទាល់តែពេលខ្ញុំនៅកុមារកំព្រាបានមួយឆ្នាំពីរឆ្នាំ ខ្ញុំឧស្សាហ៍មកលេង តាគង់ ហ្នឹងក៏ចូលទៅ តាគង់ ហ្នឹងទៅបានឮសួរគេនិយាយថា ខោអាវហ្នឹងសុទ្ធតែខោអាវអ្នកទោសទេ ។ ហើយខ្ញុំក៏មិនដឹងថា អ្នកទោសហ្នឹងដែរ ទាល់ពេលហ្នឹងគ្រាន់តែអ្នកទោសហ្នឹងជាអ្នកណា? គេថាអ្នកទោសហ្នឹងហើយ អ្នកមកកទួលស្តែងដូចជាឪពុកម្តាយឯង គេយកមកសម្លាប់នៅទីនេះអ៊ីចឹង ។ បានខ្ញុំថា អ៊ូ! ខោអាវនេះជាខោអាវអ្នកទោស អ្នកទោសហ្នឹងហើយជាអ្នករងទុក្ខនៅក្នុងហ្នឹង គេចាប់យកមកដូចជាឪពុកខ្ញុំអ៊ីចឹង ។

[១៤:២៥:៥២]

**ស៖** ខ្ញុំមានសំណួរពីរ ឬក៏បីទៀតប៉ុណ្ណោះ ហើយបន្ទាប់មកខ្ញុំនឹងបញ្ចប់ ។ ខ្ញុំមានសំណួរមួយលោកបានពន្យល់ថា លោកបានរត់ចុះ រត់ឡើងនៅពេលដែលទីកន្លែងនោះស្ងប់ស្ងាត់នៅចុងក្រោយដើម្បីចង់ជួបម្តាយ ។ ហើយលោកបានលើកឡើងថា លោកបានចូលទៅក្នុងបន្ទប់មួយលោកបានលើកឡើងថាឃើញរូបភាពមួយនៅលើគ្រែ ថាតើលោកចាំ និងលោកចាំដែរឬទេថា លោកបានឃើញនូវបន្ទប់ដែលឃើញមានរូបភាពអីនៅក្នុងបន្ទប់នោះ?

**ឆ៖** បាទ,ខ្ញុំនៅចាំបានថា ពេលស្ត្រីនោះហៅខ្ញុំចេញទៅខ្ញុំអត់ព្រមចេញទាល់តែពេលក្រោយមកស្ងាត់ស្ងប់អស់អ៊ីចឹងខ្ញុំក៏រត់តាមអគារហ្នឹង រត់តែពីមុខអគារទេ អត់បានចូលទៅក្នុងអគារទេ ។ ទាល់តែដល់អគារទីមួយ ខ្ញុំអើតមើលឃើញពីចម្ងាយទៅ វាឃើញមនុស្សដូចជាមនុស្សប្រុសសម្រាននៅលើគ្រែហ្នឹង ហើយមិនដឹងថាគាត់ស្លាប់ ឬក៏នៅទេ ប៉ុន្តែមើលឃើញហាក់បីជាមានរុយរោមអ៊ីចឹង ហើយសាច់ឈាមក៏ដូច-- បើតាមខ្ញុំធ្លាប់បានមើលគេបញ្ចាំងនៅក្នុងប៉ុស្តិ៍ *ស៊ីអិនអិន* គេថាខ្មោចអ្នកទោសវាពិតមែន

ប៉ុន្តែមិនទាន់ហើយដូចពេលគេបញ្ចាំងហ្នឹងទេ ។ ឃើញមានរុយរោមអ៊ីចឹង ដល់ឃើញខ្ញុំឃើញបានខ្ញុំបករត់ពីហ្នឹង រត់មកចូលខាងក្រោយរោងជាងហ្នឹងវិញ ។

**ស៖** តើលោកមានអារម្មណ៍យ៉ាងម៉េចនៅពេលដែលលោកមើលបន្ទប់ហ្នឹង ហើយមើលឃើញតែលើទិន្នភាពយ៉ាងនោះ?

**ឆ៖** បាទ, ខ្ញុំមានការភ័យណាស់ ខ្លាចថាក្រែងមើល ហើយក្រែងឃើញខ្ញុំរត់ទៅហ្នឹង អ្នកនៅដេកលើគ្រែហ្នឹងរត់ទៅហ្នឹង អ្នកដែលដេកលើគ្រែហ្នឹងរត់ហៅខ្ញុំ ឬហៅអីថា ខ្ញុំដើរពាសវាលពាសកាលអ៊ីចឹងគេហាមឃាត់ពីមុនមកមិនឲ្យដើរអ៊ីចឹង ដល់ខ្ញុំឃើញអ៊ីចឹងខ្ញុំមានការភ័យខ្លាច បានខ្ញុំរត់មករកកន្លែងដើមវិញ ។ ខ្ញុំមានការតក់ស្លុតរហូតដល់ខ្ញុំអត់ហ៊ានដើរទៅណាតទៅទៀត ។ នៅខាងក្រោយរោងជាងរហូតដល់ថ្ងៃវៀតណាមគេយកខ្ញុំចេញពីទីនុ៎ង ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ សូមឲ្យលោកធ្វើការបំភ្លឺ ។ លោកបានពន្យល់ថា ក្មេងមួយក្នុងចំណោមក្មេងនុ៎ងគឺស្លាប់ គឺក្មេងនៅជាមួយលោកម្នាក់ស្លាប់ ។ ហើយលោកបានលើកឡើងថា ហើយគឺយើងឃើញស្រមោចចូលត្រចៀកនិងចូលច្រមុះរបស់គាត់ ហើយគិតនូវអ្វីដែលលោកបាននិយាយព្រឹកមិញកាលយល់របស់ខ្ញុំនោះ គឺថាក្មេងនោះស្លាប់ដោយសារការអត់ឃ្លាន ។ តើត្រឹមត្រូវដែរឬទេ?

[១៤:២៨:៥១]

**ឆ៖** បាទ, ខ្ញុំជម្រាបថា នេះពិតជាត្រឹមត្រូវហើយដោយសារជាមកជាមួយពួកម្តាយពួកគេនុ៎ងគេនៅជាក្មេងបីនឹងដៃ នៅអឹមដោះម្តាយ ទាល់ពេលទុកចោលខាងក្រោយគុកហ្នឹងយូរទៅគ្នាអត់មានបានអីហូប ហើយបញ្ចុកបបរដែលស្ត្រីនោះបញ្ចុកបបរ ក៏ដូចជាហាក់បីដូចជាមិនទាន់ចេះហូបបបរនៅឡើយ ។ ហើយក្រោយមកហ្នឹង ក៏បានស្លាប់ទៅដោយមានទុកចោលយូរទៅ វាយំទាល់តែស្អក យំទាល់តែស្អកមែនទែនទៅ លែងយំ ទាល់លែងយំទៅបានឃើញមានស្រមោចវារចូលក្នុងស្លឹកត្រចៀកនិងចូលច្រមុះ ។ ហើយខ្ញុំមិនដឹងថា វាទាន់វាស្លាប់ទេ ទាល់ពេលកងទ័ពវៀតណាមចូលហើយថា ក្មេងនេះស្លាប់ហើយ បាទៗខ្ញុំដឹងតាមក្រោយទៀតដែរថា ក្មេងនេះស្លាប់ហើយ ។ សូមជម្រាបប៉ុណ្ណឹង ។

**លោក អាឡាំង វែនណឺ៖**

សូមអរគុណច្រើនចំពោះពេលវេលារបស់លោកដែលបានឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំ សូមអរគុណលោក លោកស្រីចៅក្រម ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី ។

**សួរដោយ លោកស្រី ម៉ាទីន ហ្សាកកាំង៖**

**ស៖** សូមអរគុណលោកប្រធាន លោកចៅក្រម សូមអរគុណលោក នង ចាន់ផល ដែលបានលោកអញ្ជើញមកទីនេះ ។ ខ្ញុំនឹងសួរលោក សំណួរទីពីរបី ដើម្បីឲ្យលោកបំភ្លឺបញ្ហាមួយចំនួនដែលលោកបាននិយាយដល់នោះ ។ ជាដំបូងដែលលោកទៅដល់ស-២១ គេបានថតរូបម្ដាយរបស់លោក ។ តើលោកហើយនិងប្អូនរបស់លោកគេបានថតរូបដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ពេលដែលគេថតម្ដាយហើយពួកខ្ញុំអត់បានថតអីទាំង ហើយប្អូនខ្ញុំវាអត់មានទាន់ដឹងថា ភ័យខ្លាចម៉េច ។ នៅពេលដែលគេរុញម្ដាយខ្ញុំ ច្រានទៅ គេទះតប់គាត់ដួលទៅផ្កាប់មុខទៅលើកម្រាលឥដ្ឋហ្នឹង ។ ហើយប្អូនខ្ញុំក៏អត់ដឹងអីដែរ វានៅតែរត់លេងធម្មតា វាអត់ដឹងមានការភ័យខ្លាច អត់មានដឹងថាគេវាយម្ដាយអីទេ មានតែខ្ញុំទេដែលអាចដឹង ។ ហើយខ្ញុំមានភាពតក់ស្លុតនៅកន្លែងហ្នឹង ។

**ស៖** យប់តែមួយដែលលោកបាននៅទីនោះ លោកនៅជាមួយម្ដាយនិងប្អូននៅក្នុងបន្ទប់មួយនៅជាន់ទីពីរនៃអគារ “គ” តើលោកនិងម្ដាយរបស់លោកហើយនិងប្អូនទាំងបីនាក់ ឬតើមានអ្នកផ្សេងទៀតនៅក្នុងបន្ទប់នោះមានស្ត្រី ឬបុរសណាផ្សេងទៀតទេ?

**ឆ៖** បាទ, ខ្ញុំជម្រាបថានៅបន្ទប់នោះទទេស្អាត មានតែពួកខ្ញុំឡើងទៅទេ ម្ដាយខ្ញុំហ្នឹង ហើយព្រមទាំងស្ត្រីពីរនាក់ទៀតហ្នឹង ។ ម្ដាយខ្ញុំនិងស្ត្រីពីរនាក់ បីនាក់ ហើយនិងខ្ញុំក្មេងៗប្រាំនាក់ មានតែប៉ុណ្ណឹងទេ បន្ទប់ហ្នឹងហាក់បីដូចជាគ្មានសម្ភារៈស្អីសោះទទេស្អាតទុកនៅខាងលើហ្នឹង ។

**ស៖** នៅពេលដែលលោកបានឃើញម្ដាយរបស់លោកតាមបង្អួចនោះ មានចម្រឹងពីកន្លែងដែលលោកនៅខាងក្រោយនោះ តើលោកបានឃើញម្ដាយលោកតែម្នាក់ឯង ឬក៏មានស្ត្រីផ្សេងទៀតនៅក្បែរនោះដែរឬទេ?

**ឆ៖** បាទ, សូមជម្រាបថា ស្ត្រីពីរនោះអត់មានឃើញទេ ឃើញតែម្ដាយខ្ញុំម្នាក់ឯង គាត់សម្លឹងមកមើលពួកខ្ញុំហ្នឹង ។ ឃើញតែគាត់ម្នាក់ឯង ។

**ស៖** សំណួរខ្ញុំគិតថា លោកបានព្យាយាមអស់ពីសមត្ថភាពដើម្បីចង់ឃើញម្ដាយរបស់លោកជាថ្មី ហើយៗលោកមើលតម្រង់ទៅតែទិសហ្នឹងរហូតទៅលើអគារហ្នឹង តើលោកបានឃើញមនុស្សណា

ផ្សេងទៀតក្រោយមកនោះ?

**ឆ៖** ខ្ញុំសម្លឹងទៅលើបន្ទប់ដែលម្តាយខ្ញុំឈរហ្នឹងនៅចម្រឹងបង្អួចមួយបើកចំហនៅខាងក្រោយអគារហ្នឹង សម្លឹងមកមើលពួកខ្ញុំហ្នឹង ខ្ញុំឃើញតែម្តាយខ្ញុំចុងក្រោយតែម្តងហ្នឹង ហើយក្រៅពីហ្នឹងគ្មានឃើញអ្នកណាទេ ។

**ស៖** តើលោកមានបានឃើញមនុស្សណាផ្សេងណាទៀតទេនៅបង្អួចនោះ ឬក៏មិនដែលឃើញអ្នកផ្សេងទៀតទាល់តែសោះនៅតាមបង្អួចនោះ?

**ឆ៖** បាទ, បង្អួចដទៃជាន់ក្រោមៗទៀត គឺអត់មានដែលបើកទ្វារទេ បើកទ្វារតែអាបន្ទប់ដែលម្តាយខ្ញុំគាត់ឈរមើលមកខ្ញុំហ្នឹង អាពេលដែលបាត់ម្តាយហ្នឹងបង្អួចហ្នឹងក៏ទាន់បានបិទដែរ នៅចំហអ៊ីចឹង ហើយខ្ញុំព្យាយាមមើលទៅបន្ទប់បង្អួចដែលគាត់ឈរហ្នឹង ប៉ុន្តែអត់ឃើញគាត់ ប៉ុន្តែទ្វារបង្អួចនៅតែបើកដដែល ។

**ស៖** សំណួរ អ៊ីចឹងនៅពេលនោះលោកអាយុ៩ឆ្នាំ ។ តើក្នុងចំណោមក្មេងប្រាំនាក់នោះលោកជាមនុស្សដែលបងគេបំផុត បានន័យថា អាយុច្រើនជាងគេបំផុតមែនទេ?

[១៤:៣៤:៤៤]

**ឆ៖** បាទ, ពិតមែនហើយ ។

**ស៖** នៅក្នុងពេលថ្ងៃតើលោកអាចលេងអ្វីបានទេ? តើមានអ្នកណាម្នាក់ជាអ្នកមើលឃុំគ្រងលោក ឬក៏លោកធ្វើការអ្វីដែរនៅពេលនោះ?

**ឆ៖** នៅពេលនោះ ខ្ញុំនៅខាងក្រោយហ្នឹងគឺអត់មានលេងអីទេ សូម្បីដើរទៅណាដូចជារពឹសរត់ចុះរត់ឡើងក៏អត់បានដែរ ដោយមានស្ត្រីម្នាក់ហ្នឹងចាំមើលពួកខ្ញុំហ្នឹង គាត់បានប្រាប់ឲ្យ ស្រែកឲ្យថាឲ្យកុំទៅនេះកុំទៅនោះ ខ្លាចនេះខ្លាចនោះ ។ ហើយខ្ញុំមើលទៅស្ត្រីហ្នឹងហាក់បីដូចជាគាត់ខ្លាចគេដែរ ខ្លាចអ្នកយាមអ្នកអីហ្នឹងដែរ ។ ខ្ញុំមើលទៅអ៊ីចឹងខ្ញុំ-- តាំងពីគេឃើញម្តាយរុញម្តាយខ្ញុំនៅបន្ទប់ថតហ្នឹង ខ្ញុំឃើញគេវ៉ៃគាត់អ៊ីចឹង ខ្ញុំមានអារម្មណ៍ថា កន្លែងច្បាស់ជាមិនដឹងកន្លែងស្អី បើគេ ម្តាយខ្ញុំគេធ្វើបាបគាត់ ។ ខ្ញុំកំពុងតែគិតភ័យរហូតមិនដឹងថា ខ្ញុំនឹងទៅណាមកណាអី ខ្ញុំក៏មិនប៉ានដើរទៅណាដែរ ដោយឃើញគេធ្វើបាបម្តាយអ៊ីចឹង ។

**ស៖** រហូតទាល់ដែលលោកចូលទៅដល់ពេលវេលាមួយដែលពិបាកបំផុតនៅក្នុងពេលនោះ ។ នៅពេលដែលលោកត្រឡប់ទៅអគារនោះទៅរកម្តាយ ដែលលោកបានរត់ទៅរកទៅឃើញថា មានសាក

សពនៅអគារដែលលោកទៅរកម្តាយនោះ តើឃើញមានមនុស្សមានដេកស្លាប់ ឬក៏មិនមានមនុស្សទាល់តែសោះនោះឬទេ?

**ឆ៖** ដល់ពេលស្ត្រីមួយដែលបក់ដៃហៅខ្ញុំរត់តាមគាត់ហ្នឹង គាត់ទៅបាត់យូរទៅ ខ្ញុំឃើញភាពស្ងប់ស្ងាត់ហ្នឹងទ្វារគុកក៏របើក ខ្ញុំក៏គិតថារត់រកម្តាយ ដល់តែពេលខ្ញុំរត់ទៅហ្នឹង គឺខ្ញុំរត់ចាកចេញពីខ្លោងខាងក្រោយហ្នឹងរត់ទៅអគារ “B” រត់ទៅអាគារ “A” ហ្នឹងដល់ពេលដែលខ្ញុំរត់ទៅអាគារ “A” ឃើញមានមនុស្សដេកនៅលើគ្រែហ្នឹង ហើយខ្ញុំមិនដឹងថាមនុស្សហ្នឹងស្លាប់ ឬក៏នៅទេ ប៉ុន្តែហាក់ដូចជាមានរុយរោមហើយគ្មានកម្រើក គ្រាន់តែពេលខ្ញុំឃើញប៉ុណ្ណឹងខ្ញុំក៏រត់មកវិញ កន្លែងវិញហើយគ្មានឃើញអ្នកណាទៀតទេ ។

**សៈ** នៅចុងបំផុតនោះលោកនិយាយថា នៅក្នុងចំណោមកុមារទាំងប្រាំនោះ គឺនៅសល់ប្អូននាក់ជាមួយលោកចេញពីទួលស្លែងទៅ ដែលថាពីរនាក់ត្រូវបានគេទទួលយកធ្វើជាកូនចិញ្ចឹម តើអ្នកផ្សេងទៀតគេទៅណាដែរខុសពីហ្នឹង?

**ឆ៖** កាលនុ៎ង ដោយសារគេយកពួកខ្ញុំទៅដាក់កុមារកំព្រា ហើយពួកនោះវាតូចៗពេកអាពីរនុ៎ងត្រូវបានគេយកទៅដាក់កុមារកំព្រាសង្គ្រោះទារកយើងនៅជិតពេទ្យកាល់ម៉ែត្រ ហើយដោយឆ្ងាយពីពួកខ្ញុំផង ហើយខ្ញុំក៏ចាត់ទុកថាវាដូចជាប្អូនខ្ញុំអ៊ីចឹង ហើយថាលោកគ្រូអ្នកគ្រូគេចុះក្នុងបញ្ជីគេថា វាជាប្អូនខ្ញុំ ដល់ពេលថ្ងៃក្រោយមកគេមានពិធីបុណ្យអីមួយគេឲ្យពួកខ្ញុំហ្នឹងជួបគ្នា ។ ហើយខ្ញុំសួរទៅអ្នកគ្រូនុ៎ងថា ចុះប្អូនខ្ញុំនោះនៅឯណាអត់ឃើញ? គេថា អូ! មានគេសុំធ្វើជាកូនចិញ្ចឹមនៅប្រទេសអាឡឺម៉ង់មួយ ហើយមួយទៀតត្រូវបានជាខ្មែរសុំមិនដឹងជាទៅនៅខាងណា គេថានៅម្តុំសង្កាត់ស្ទឹងមានជ័យ ។ ខ្ញុំចេះតែព្យាយាមសួរគេដែរ ប៉ុន្តែវាតូចពេកវាមិនចាំខ្ញុំ ហើយខ្ញុំក៏មិនចាំវា ហើយខ្ញុំក៏នៅបែកវារហូតបាត់គ្នា រហូតពីរហ្នឹងបាត់ទៅ ។ នៅខ្ញុំតែពីរនាក់បងប្អូនបង្កើត ហើយប្អូនបង្កើតរបស់ខ្ញុំបច្ចុប្បន្នវាអ្នកបើកឡានរកស៊ីឡានបើកដឹកដីនៅស្រុកកៀនស្វាយ ហើយឥឡូវហ្នឹង គេកំពុងតែជាប់ការងារគេនៅខេត្តមណ្ឌលគីរី គេជួលឡានគេទៅ ។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមអរគុណលោក នង ចាន់ផល ។

**សួរដោយ លោក គីម ម៉េងឃី៖**

**សៈ** សូមគោរពលោកប្រធាន! ខ្ញុំមានសំណួរតែបន្តិចទេ សួរទៅកាន់លោក នង ចាន់ផល

ពាក់ព័ន្ធនឹងលោកដែលក្រោយលោកថា លោកត្រូវបានចាប់ទៅទួលស្លែង រហូតមកដល់-- តើលោកត្រូវបានបង្កឲ្យមានរបួស ឬក៏ស្លាកស្នាមបន្សល់ទុកដល់សព្វថ្ងៃដែរឬទេ?

[១៤:៣៩:២៤]

**ឆះ** ចំពោះរបួសស្នាមនោះវាអត់មានការវ៉ៃដំអីទេ ពួកខ្ញុំហ្នឹងមានតែកមរមាស់ ហើយនិងដំបៅតូចៗនៅនឹងខ្លួនដោយសារមូសខាំ ដោយសារអត់អាហារ បាទមានតែប៉ុណ្ណឹងទេ ។ ដោយសារពួកខ្ញុំស្លេកស្លាំង ប៉ុណ្ណឹងបាទ មូសខាំច្រើនថ្ងៃច្រើនយប់ពេក ។

**សះ** ខ្ញុំសូមបញ្ជាក់មួយសំណួរទៀត។ ទាក់ទងនឹងលោកដែលថាបរិភោគនូវបបរផ្អូមហ្នឹង តើលោកបរិភោគចំនួនប៉ុន្មានដង? ហើយបរិមាណហ្នឹងប្រហែលប៉ុនណា? ហើយក្រោយពីបរិភោគហ្នឹងធ្វើឲ្យអាការៈសុខភាពលោកយ៉ាងម៉េចដែរ?

**ឆះ** ខ្ញុំអត់នៅចាំថា វាអាការអាម៉េចទេ ដោយសារខ្ញុំនៅតូចពេកអត់ចាំ ដោយសារខ្ញុំឃ្លានន៎ុងខ្ញុំចេះតែហូតទៅ តែដល់វាជូរៗទៅវាល្វីងដូចថា វាហូបលែងបានវាទាល់តែស្អុយទៅជូរមែនទែនទៅបានខ្ញុំលែងហូប ។ ហើយពីពេលដែលពួកខ្ញុំលែងហូបហ្នឹងហើយ វាអត់អាហារតាំងពីថ្ងៃន៎ុងមករហូតទាំងប្អូនខ្ញុំ ទាំងខ្ញុំ ។ ទើបតែដល់ពេលគេមានគេចូលទៅនឹងបានគេដាក់ដាំបាយឲ្យខ្ញុំហូតមួយឆ្នាំង ហើយខ្ញុំមិនដឹងថា គេបានអង្ករមកពីណាទេ ហើយគេធ្វើទា អាទាន៎ុងនៅខាងក្រោយរោងជាងន៎ុងមានទា ។ គេវ៉ៃទាមួយធ្វើឲ្យពួកខ្ញុំហូប ដឹងតែប៉ុណ្ណឹង ។

[១៤:៤០:៥១]

**សះ** មួយសំណួរទៀតសួរថា ពាក់ព័ន្ធនឹងការហូបហ្នឹង តើមានទឹកសម្រាប់បរិភោគដែរឬទេ? សូមអរគុណ ។

**ឆះ** ទឹកនោះ ខ្ញុំមានឃើញទឹកពាងខ្លះបែកនៅទីនោះមានពាងខ្លះល្អ ពាងខ្លះបែកហើយមានទឹកភ្លៀងដកនៅជាប់ហ្នឹង ហើយក៏បានហូបទឹកដែលនៅសល់លើពាងបែកៗហ្នឹង ហើយ*រ៉ូមីណេ* ដែរ ប៉ុន្តែរ៉ូមីណេទឹកហ្នឹងអត់មានទឹកចេញទេ ចេញតែលើអាមានទឹកនៅលើអំបែកពាងបែកៗនៅខាងហ្នឹង ពាងខ្លះបែកមួយចំហៀង នៅសល់មួយចំហៀងហើយមានទឹកពួកខ្ញុំក៏ហូតទឹកដួសទឹកហ្នឹងឲ្យប្អូនៗហូបហ្នឹងតែប៉ុណ្ណឹង ។

**ប្រធានអង្គជំនុំះ**

សូមអញ្ជើញ ។ មានមេធាវីណា? សូមអញ្ជើញមេធាវី ។

**សួរដោយលោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ខ្ញុំបាទមានសំណួរតែពីរសំណួរទេ ហើយអាចហ្នឹងថែមបន្តិចប្រសិនបើពាក់ព័ន្ធ ។ ខ្ញុំបាទសូមគោរពលោកប្រធាន និងសូមគោរពលោកស្រី លោកចៅក្រម អង្គជំនុំជម្រះជាទីគោរព ។

**ស៖** ខ្ញុំសូមជម្រាបសួរលោក នង ចាន់ផល សំណួរខ្ញុំសួរទីមួយមួយសួរថា នៅថ្ងៃដំបូងដែលពួកខ្មែរក្រហមចាប់ម្ដាយលោកព្រមទាំងលោកដឹកឡានទៅដល់យើងហៅថាមន្ទីរស-២១ ឬហៅឲ្យស្រួលស្ដាប់ហៅថា ទួលស្លែងនេះ ។ ថ្ងៃដំបូង ចូលទៅដល់នោះ មួយថ្ងៃមួយយប់នោះគេឲ្យបាយឲ្យទឹកលោក និងម្ដាយលោកហូបដែរ ឬទេ?

**ឆ៖** ខ្ញុំដូចអត់នៅចាំទេ ដោយសារតក់ស្លុតនឹងគេវៃម្ដាយខ្ញុំហ្នឹង នៅក្នុងបន្ទប់ថតរូបហ្នឹងរុញច្រានបោចសក់គាត់ទាញទៅក្រោយទាញឆ្វេងស្ដាំនឹងរុញផ្កាប់មុខតប់គាត់ពីរបីដៃហ្នឹង ខ្ញុំភ័យពេកខ្ញុំគ្មានបានចាំទេរឿងបាយទឹកអីទេ ។

**ស៖** សូមអរគុណ។ អម្បាញ់មិញលោកមេធាវីបានសួរលោកអំពីរឿងថ្ងៃដែលកងទ័ពវៀតណាម ឬក៏កងទ័ពដែលចូលទៅដល់ជួបលោកដែលហូបបបរផ្អមស្អុយនោះ ។ អ៊ីចឹងខ្ញុំសួរទាក់ទងរបៀបគ្នានេះដែរ តែមិនមែនថ្ងៃនោះទេ ។ ចង់និយាយថា មុនថ្ងៃដែលកងទ័ពចូលទៅរំដោះយកលោកមកនោះ តើនៅកន្លែងនោះរោងជាងនោះគេឲ្យលោកហូបឆ្អែតឬទេ?

[១៤:៤៣:១០]

**ឆ៖** ខ្ញុំនៅចាំការឃ្លានវាចេះតែឃ្លាន ប៉ុន្តែបាយទឹកគេឲ្យទៀងពេល ឬក៏ច្រើនពេលឆ្អែតឬក៏អត់ក៏អត់បានចាំដែរ ។ ដឹងតែពេលដែលឃ្លានដឹងថាឃ្លាន ហើយប្អូនៗវាយំទារខ្ញុំហ្នឹង ហើយអាមួយប្អូនហ្នឹងវាយំទារបាយបបរដល់តែពេលហ្នឹងបានគេដាក់ឲ្យហូប បើវាអត់យំទារអត់ទេ ។

**ស៖** សូមអរគុណ។ សំណួរមួយទៀតសួរថា លោកគិតថយក្រោយបន្តិចទៅមើលចាំ ឬមិនចាំ ។ ខ្ញុំគ្រាន់តែសួរថា តើលោកដែលទៅសុំក្ដាំងបបរនៅក្នុងខ្ទះឆ្នោតពីចុងភៅដែរឬទេ?

**ឆ៖** ខ្ញុំអត់នៅចាំដែរទេ ព្រោះថា ខ្ញុំតាំងពីឃើញម្ដាយខ្ញុំគេធ្វើអ៊ីចឹងទៅខ្ញុំតក់ស្លុតរហូតដល់តែខ្ញុំឃើញមនុស្សចាស់ៗដែលខ្ញុំអស់ស្គាល់ខ្ញុំអត់ហ៊ានទៅក្បែរគេទេ ។ ខ្ញុំនៅចាំបានតែប៉ុណ្ណឹង ។

**ស៖** សំណួរចុងក្រោយលោកជម្រាបអង្គសវនាការច្បាស់ហើយថា នៅពេលដែលកងទ័ពវៀត-ណាម ឬកងទ័ពខ្មែរចូលទៅយកលោកបីលោកយកមកមន្ទីរពេទ្យនោះ? ហើយរហូតដល់លោកទៅនៅ

ជាមួយកងទ័ពវៀតណាមទៀត ។ សំណួរខ្ញុំសួរអ៊ីចេះ តើក្នុងពេលនោះ ពេលដែលនៅជាមួយកងទ័ពវៀតណាមគេដែលយកលោកទៅថតឯណាដែរឬទេ?

**ផ៖** បើតាមខ្ញុំដឹងនៅជាមួយទ័ពវៀតណាមដូចអត់មានបានទៅណាទេ ដោយថាទ័ពវៀតណាមហ្នឹងវ៉ៃខាងនេះបន្តិចដកទៅខាងនោះដកទៅខាងនេះបានលោកតា កែវ ចិន្តា គាត់បានឮដំណឹងថាមានក្មេងនៅជាមួយទ័ពវៀតណាមហ្នឹងបានគាត់ទៅសុំពីវៀតណាមហ្នឹងមក ។

បើការ--មានការថតមានការអីជួនកាលគណៈប្រតិភូចូលទៅទស្សនកិច្ចនៅមជ្ឈមណ្ឌលកូលាបមជ្ឈមណ្ឌលកុមារកំព្រាកុលាបទីពីរហ្នឹង គេមានការថតមែន ដោយថតពួកខ្ញុំនៅនុំងកុមារកំព្រាទេ ។ ពេលនោះខ្ញុំមានសុខភាពល្អមានខោអាវស្លៀកពាក់ត្រឹមត្រូវហើយ ។ ហើយពួកខ្ញុំបានចូលរៀនហើយអានុំងបានថតមែន ។

**ស៖** អ៊ីចឹងសូមសួរថែមបន្តិច សួរថា ដោយសារពេលនេះលោកមិនមែនជាជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីទេ ប៉ុន្តែ សំណួររបស់ខ្ញុំគ្រាន់ថា ដែលលោកមានបំណងដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណីនោះ លោកចង់ប្តឹង លោកប្តឹងចង់បានអ្វី?

[១៤:៤៥:៣៨]

**ផ៖** ខ្ញុំប្តឹងពាក្យបណ្តឹងហ្នឹងវា ខ្ញុំឃើញពេលវេលាអាចព្យារពេលវេលាបានច្រើន ដោយការងាររវល់ពេកខ្ញុំបើក *អាប៊ូលដូហ្សរ* ហ្នឹងនៅតាមខេត្ត ។ ដល់ពេលថ្ងៃមួយខ្ញុំបានបើកប្រាក់ខែហើយខ្ញុំមកលេងគ្រួសារនៅភ្នំពេញយកលុយយកកាក់ឲ្យគ្រួសារ ហើយខ្ញុំបានមើលប៉ុស្តិ៍ព័ត៌មានហើយថា សវនាការទទួលពាក្យបណ្តឹងហ្នឹង រឿងទួលស្លែងហ្នឹង គេជិតបិទហើយ ហើយខ្ញុំក៏បានដឹងពាក្យហ្នឹង ខ្ញុំក៏រត់ទៅរកពាក្យបណ្តឹងដាក់ទាល់ពេលដែលខ្ញុំដាក់ទៅ ខ្ញុំយឺតពេលដាក់ពាក្យបណ្តឹង ដើមបណ្តឹងហើយ ខ្ញុំក៏បានសូមខ្លួនចូលជាសាក្សីទៅ ។

**ស៖** តើលោកចង់បានអ្វី?

**ផ៖** ពេលដែលខ្ញុំដាក់ហ្នឹងខ្ញុំគ្មានចង់បានអ្វីក្រៅរកយុត្តិធម៌ឲ្យម្តាយខ្ញុំទេ និងឪពុកខ្ញុំទេ ។

**លោក ហុង គីមសួន៖**

សូមអរគុណលោក នង ចាន់ផល ហើយសូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។

**កញ្ញា ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន ជាបឋមខ្ញុំសូមគោរពលោកប្រធាន ។ នាងខ្ញុំគិតថា ដើមបណ្ដឹងរដ្ឋ-ប្បវេណី ខាងក្រុមដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលប្រាំនាទីដែលនៅសេសសល់ ហើយចំពោះនាងខ្ញុំផ្ទាល់នាងខ្ញុំពុំមានសំណួរអ្វីដើម្បីសាកសួរទៅសាក្សី នង ចាន់ផល នេះទេ ប៉ុន្តែនាងខ្ញុំមានសំណើមួយដែលសូមស្នើទៅលោកប្រធាន បើសិនជាលោកប្រធានអនុញ្ញាតនាងខ្ញុំនឹងធ្វើការស្នើសុំដល់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមានសំណើអីទៅ? ទាល់តែមានសំណើបានសម្រេចកើត?

**កញ្ញា ទី ស្រ៊ីនណា៖**

នាងខ្ញុំសូមស្នើៗលោកប្រធានថា សូមឲ្យខាងជនជាប់ចោទជួយបំភ្លឺទៅលើចំណុចមួយដែលពាក់ព័ន្ធទៅនឹងចម្លើយរបស់សាក្សី នង ចាន់ផល ដែលគាត់បានលើកឡើងថា មាន-- នៅពេលដែលគាត់បានទៅដល់បន្ទប់នៃមន្ទីរស-២១ ហ្នឹង គាត់បានឃើញសាកសពនៅលើគ្រែ ហើយពេលដែលសាកសពនៅលើគ្រែហ្នឹង គាត់ថាសាកសពហ្នឹងមិនទាន់មានការហើមទេ ហើយអ៊ីចឹងនាងខ្ញុំក៏មានចម្ងល់ទាក់ទងទៅនឹងចំណុចនេះ ។ នាងខ្ញុំមិនដឹងថា តើសាកសពមួយហ្នឹងគឺជាសាកសពដែលៗមួយនៅក្នុងចំណោមមនុស្សទាំងប្រាំបួននាក់ដែលលោកជនជាប់ចោទហ្នឹង គាត់បានស្នើសុំទៅថ្នាក់លើរបស់គាត់ដើម្បីទុកសាកសួរចម្លើយ ។

កាលពីលើកមុនហ្នឹង គាត់បានឆ្លើយទៅលើចំណុចហ្នឹង ហើយអ៊ីចឹងនាងខ្ញុំគ្រាន់តែចង់ដឹងថា តើសាកសពដែលលោក នង ចាន់ផល លើកឡើងហ្នឹងគឺជាមនុស្សម្នាក់នៅក្នុងចំណោមអ្នកទាំងប្រាំបួននាក់ហ្នឹងដែរឬទេ? ដូច្នេះ នាងខ្ញុំសូមឲ្យលោកប្រធាន ស្នើសុំដល់លោកប្រធានដើម្បីឲ្យជនជាប់ចោទជួយបំភ្លឺទៅលើករណីនេះ ។ សូមអរគុណ ។

[១៤:៤៨:១៤]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** នង ចាន់ផល ដែលលោកអះអាងថា បានឃើញសាកសពមួយពេលដែលលោករត់ ដើររកម្ដាយហើយថា លោកបានឆ្លើយបញ្ជាក់ច្បាស់ថា អំមិញនៅអាគារ “A” ។ ហើយសំណួរសួរថា តើ

សាកសពនៅលើគ្រែដែលនៅជាប់ខ្នោះដែលលោកមើលឃើញនុ៎ង នៅជាន់ក្រោម ឬក៏នៅជាន់ទីមួយ ឬក៏ជាន់ទីពីរ?

**ឆ៖** ខ្ញុំសូមជម្រាមថា ពេលដែលខ្ញុំរត់មករកម្ដាយខ្ញុំហ្នឹង រត់ចេះតែរត់ៗទៅ ខ្ញុំស្រែករកម៉ែៗ អ៊ីចឹងហើយ ចេះអត់មានឮសំឡេងតបមកវិញអ៊ីចឹង ហើយខ្ញុំរត់ទៅដល់នុ៎ងឃើញ-- ក្រឡេកទៅឃើញមនុស្សប្រុស ដឹងមនុស្សប្រុសមនុស្សស្រី? ដេកនៅលើគ្រែហ្នឹង ហើយមានរុយរោមអ៊ីចឹង ។ ហើយអត់មានហើមអ៊ីចឹងដូចក្នុងរូបថត-- ។

**ស៖** អត់ចង់ដឹងអ៊ីចឹងទេ ។ លោកនិយាយរួចហើយ យើងចង់ដឹងថា សពដែលនៅលើគ្រែដែលលោកមើលឃើញនុ៎ង នៅជាន់ផ្ទាល់ដី បានន័យថាខាងក្រោមផ្ទាល់ដី ឬក៏នៅជាន់ទីមួយ ឬក៏ជាន់ទីពីរ? ពីព្រោះលោកបាននិយាយហើយ វាៗមានលក្ខណៈមិនច្បាស់លាស់ដែលលោកថា រត់ហ្នឹង គឺរត់ទៅរកហ្នឹងមិនបានឡើងទៅលើអាគារទេ គឺរត់នៅនឹងដី ។ អ៊ីចឹងយើងចង់ដឹងថា សពនុ៎ងដែលថា លោកអើតទៅមើលឃើញហ្នឹងគឺនៅជាន់ផ្ទាល់ដី ឬក៏នៅជាន់ទីមួយ ឬក៏ទីពីរនៃអាគារ “A”?

[១៤:៥០:០៤]

**ឆ៖** បាទ, ខ្ញុំនៅចាំបាន ។ ខ្ញុំពេលដែលខ្ញុំរត់នៅនុ៎ងនៅនឹងដី ជាន់ហ្នឹងគឺជាន់ទី បើតាមយើងបច្ចុប្បន្នគឺថា E1 ម៉េចគេនោះ? ជាប់នឹងដីហ្នឹង ដូចជាគេអត់ទៀតរាប់ជាជាន់ទីមួយទេ ។ ទាល់តែឡើងមួយជាន់ទៀតទើបគេរាប់ជាន់ទីមួយ ។ ហើយខ្ញុំឃើញបន្ទប់ហ្នឹងវាចំហទ្វារ ហើយខ្ញុំមើលទៅឃើញមនុស្សប្រុសហ្នឹងដេក ប្រហាក់ប្រហែលហ្នឹងជា-- បើតាមមើលទៅចំណាស់ប្រហែលជាឪពុកខ្ញុំដែរមិនដឹង? ប្រហាក់ប្រហែលប៉ុណ្ណឹង ហើយខ្ញុំមើលទៅនុ៎ងហាក់បីដូចជាមនុស្សប្រុសហ្នឹងដេកហ្នឹងអត់ទាន់ស្លាប់ទេ មើលឃើញទៅដូចនៅ-- ប៉ុន្តែអត់មានកម្រើកទេ ប៉ុន្តែមានរុយរោម ។ នៅជាន់ជាប់នឹងដីហ្នឹងបន្ទាប់ទីមួយហ្នឹង ។

**ប្រធានអង្គជំនុំ៖**

ចំពោះចម្ងល់ ឬក៏សំណួររបស់មេធាវីអម្បាញ់មិញគឺ ទុកលោកលទ្ធភាពជូនជនជាប់ចោទដែលនឹងអាចធ្វើការកត់សម្គាល់ចំពោះចម្លើយសាក្សីរូបនេះដែលបានឆ្លើយ ប៉ុន្តែឥឡូវដល់ពេលម៉ោងសម្រាកហើយអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងបីដប់នាទីចូលវិញ ។ ហើយដំណើរការសវនាការបន្ត ហើយពេលនោះឈានចូលដំណាក់កាលនៃការកត់សម្គាល់ លើចម្លើយសក្ខីកម្មរបស់សាក្សីរូបនេះរបស់ជនជាប់ចោទ ។ អ៊ីចឹង គឺអាចពាក់ព័ន្ធនឹងចម្ងល់របស់មេធាវីជាតិក្រុមមួយដែល

បានលើកឡើងផងដែរ ។ មន្ត្រីតុលាការសម្របសម្រួលរកកន្លែងឲ្យលោក នង ចាន់ផល បានសម្រាក សមរម្យ ។

*[សវនាការសម្រាកពីម៉ោង ១៤:៥២ នាទី ដល់ម៉ោង ១៥:១៥នាទី]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការតទៅទៀត ។

តទៅនេះ គឺអង្គជំនុំជម្រះប្រគល់វេទិកានេះទៅជនជាប់ចោទដើម្បីធ្វើការកត់សម្គាល់នូវការផ្តល់សក្ខីកម្មរបស់លោក នង ចាន់ផល ដែលបានធ្វើរួចហើយ ហើយប្រសិនបើអាចធ្វើទៅបាន ក៏ភ្ជាប់ជាមួយនេះ គឺអាចតបទៅនឹងសំណួរដែលសួរដោយមេធាវី ។ អង្គជំនុំជម្រះសូមជម្រាបដល់ជនជាប់ចោទផងដែរថា ការឆ្លើយតបនេះគឺកត់សម្គាល់លើសម្តីដែលគាត់ធ្វើសក្ខីកម្មនេះ តើវាមានលក្ខណៈយ៉ាងម៉េច? ប្រាកដប្រជា ឬមិនប្រាកដប្រជាយ៉ាងម៉េច គឺដែលលោកធ្វើការកត់សម្គាល់ប៉ុណ្ណឹង គឺមិនចាំបាច់ក្នុងការលាតត្រដាងទៅលើការទទួលខុសត្រូវ ពីពិរុទ្ធភាព ឬគ្មានពិរុទ្ធភាព ឬកំហុសរបស់លោកដែលទទួលខុសត្រូវនោះទេ គឺលោកគិតតែអ្វីដែលគេនិយាយអីអ៊ីចឹង តើលោកកត់សម្គាល់យ៉ាងម៉េចខ្លះ? ចំពោះបុគ្គលលោក ចំពោះចម្លើយសក្ខីកម្មរបស់សាក្សីរូបនេះតែប៉ុណ្ណោះ ។

បើមានសូមអញ្ជើញជនជាប់ចោទ ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំសូមបញ្ជាក់តាមដែលការខ្ញុំបានស្តាប់សក្ខីកម្មរបស់លោក នង ចាន់ផល នេះ ។ ដំបូងខ្ញុំសូមទទួលស្គាល់ថា សក្ខីកម្មនេះ វាបញ្ចាំងឲ្យឃើញទុក្ខវេទនា ការនិរាសប្រាសព្រាត់របស់លោក នង ចាន់ផល ពិតប្រាកដមែន ។ ដំបូងនៅពេលដែល មុនឹងឃើញឯកសារជីវប្រវត្តិរបស់លោក នង ចិន ជាឪពុកលោក នង ចាន់ផល ខ្ញុំគិតថា ឧក្រិដ្ឋកម្មនេះវានៅក្រៅ ស-២១ ទេ ។ ប្រហែលជាលោក នង ចិន រងទុក្ខវេទនានៅមន្ទីរនគរបាលមួយផ្សេងទៀត ។ ដល់ឃើញប្រវត្តិរូបរបស់លោក នង ចិន ដែលចុះនៅលេខ TSL បានន័យថាទួលស្លែង លេខ 0529 ខ្ញុំទទួលស្គាល់ហើយ ថាលោក នង ចិន ពិតជាមកស្លាប់នៅកន្លែងនេះ ។ ដោយឡែកម្តាយរបស់លោកនង ចាន់ផល អត់ទាន់ឃើញឯកសារអីទេ ។ ដូច្នេះ ខ្ញុំសូមញែកបញ្ហានេះជាពីរ ។

ទីមួយ បើសិនជាមានប្រវត្តិរូបអ៊ីចឹងមកទៀត និយាយអំពីម្ដាយលោក នង ចាន់ផល លទ្ធភាពវាតែម្យ៉ាង គឺវាត្រូវស្លាប់ទាំងអ្នកមីងមុំ យ៉ូវ ហើយវាស្លាប់ទាំងលោក នង ចាន់ផល និងប្អូនផង ។ ស-២១ អត់ដែលទុកកុមារទេ ។ នេះខ្ញុំសូមជម្រាបលោកដោយត្រង់ ។ នេះលទ្ធភាពវាទៅអ៊ីចឹង ។

ប្រសិនបើរកមិនឃើញវិញ ខ្ញុំនៅតែសន្និដ្ឋានថា អ្នកមីង មុំ យ៉ូវ ទទួលរងគ្រោះថ្នាក់ដល់ស្លាប់ខ្លួននៅកន្លែងផ្សេង ទើបបានលោករស់ អាចកងទ័ពវៀតណាម ហើយនិងកងទ័ពលោកតា ហេង សំរិន ប្រមូលលោកយកមកចិញ្ចឹមបាន ។ នេះខ្ញុំវិភាគអ៊ីចឹង ។ ជាបណ្ដោះអាសន្ននេះខ្ញុំនៅចែកផ្លូវពីរហ្នឹងសូមមេត្តាជួយរកឲ្យឃើញក្រដាសស្នាមនៅខាងស-២១ ដើម្បីខ្ញុំបញ្ជាក់ស្រួល ។

ដូច្នេះ សក្ខីកម្មរបស់លោក នង ចាន់ផល ខ្ញុំទទួលទាំងអស់ ខ្ញុំទទួលទាំងទុក្ខវេទនារបស់គាត់ដោយគោរព អត់ប្រកែកទេ ។ នេះសំណូមពរខ្ញុំតែប៉ុណ្ណឹង ។

[១៥:២០:៣៥]

ដោយឡែកសូមបន្តទៅទៀតចំពោះសំណួរកញ្ញាមេធាវី សូមបញ្ជាក់ជូនកញ្ញាថា ប្អូននាក់ ពួក យ-៨ ហ្នឹងប្អូននាក់ កញ្ញាច្រឡំហើយប្រាំប្អូននាក់ មិនមែនប្រាំប្អូនទេ ប្អូននាក់ ។ រូបថតដែលនៅលើគ្រែហ្នឹងខ្ញុំឃើញម្ដងអង្កាល់ពីខែ ឆ្នាំ២០០៧-- ២០០៦ មុនខ្ញុំមកនេះ ជួបទូរទស្សន៍ជប៉ុនអ៊ីចឹងមិនដឹងទូរទស្សន៍អ៊ីតាលីមិនដឹង ខ្ញុំចាំដូចទូរទស្សន៍ជប៉ុន ។ គេបង្ហាញរូបថតមនុស្សម្នាក់ដេកលើគ្រែ មានខោឡេវជើងវែង ហើយនិងមានអាវ ។ គេបង្ហាញរូបថតមនុស្សម្នាក់នៅក្នុងសាលធំ ដូច្នេះ បើនិយាយថាលោក នង ចាន់ ផលមានប្រសាសន៍ថា ឃើញមនុស្សម្នាក់នៅដេកលើនុំង លោកមិនច្បាស់ជាស្លាប់ ឬរស់តែមិនដឹងស្អុយហើយគគ្រិចគគ្រុកទេ ខ្ញុំថា ប្រហែលជារូបហ្នឹងដែលគេថត ពួកទូរទស្សន៍ជប៉ុនហើយដែលគេថតមនុស្សតម្កល់នៅទួលស្លែងពិតប្រាកដរបស់គេ ។ ខ្ញុំគ្រាន់តែសន្និដ្ឋានប៉ុណ្ណឹងជូនទេ ។ នេះខ្ញុំសូមបញ្ជាក់ជូនតុលាការប៉ុណ្ណោះ សូមចប់ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ ចម្លើយដែលបញ្ជាក់ដោយជនជាប់ចោទ បានធ្វើឲ្យខ្ញុំមិនប្រាកដអំពីថាតើគាត់ឯកភាព ថាសាក្សី នង ចាន់ផល នេះ គឺធ្លាប់បានជាកុមារជាប់ឃុំនៅស-២១ ឬក៏មិនមែន ។ តើមេធាវីការពារអាចណែនាំ ឬក៏ពិគ្រោះយោបល់ជាមួយជនជាប់ចោទដើម្បីបញ្ជាក់ថា តើគាត់

ទទួលស្គាល់បែបនេះដែរឬទេ? សូមអរគុណ ។

[១៥:២៤:០៨]

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ខ្ញុំបាទសូមអនុញ្ញាតជម្រាបលោកជំទាវចៅក្រមថា ខ្ញុំបានពិភាក្សាជាមួយនឹងកូនក្តីខ្ញុំរួចហើយ ។ កូនក្តីខ្ញុំពុំទទួលស្គាល់ថា លោក នង ចាន់ផល បានមករស់មករានមានជីវិតប៉ុន្មានថ្ងៃនៅក្នុងទួលស្លែងនេះទេ ។ មូលហេតុដែលគាត់មិនទទួលស្គាល់ ដោយសារថា វិធានការជាបទបញ្ជាពីអង្គការខាងលើតឹងតែងណាស់ គ្មានអ្នកណាមួយអាចប្រឆាំងបានទេ ប្រឆាំងគឺត្រូវស្លាប់ គេបញ្ជាមកពីលើ ជាពិសេស គឺថ្ងៃពីរ និងថ្ងៃ បី មករា ១៩៧៩ គឺ នួន ជា បញ្ជាអ៊ីចឹងតែម្តង ទាំងក្មេងទាំងចាស់ ទាំងប្រុស ទាំងស្រី កម្ទេចឲ្យអស់គ្មានឲ្យសល់ ។

[១៥:២៥:០៨]

ដូច្នេះ គេប្រមូលខ្មោចខ្មី គ្មានឲ្យមានម្នាក់នៅស-២១ ទេ លើកលែងតែបួននាក់ដែលបាញ់ជនបរទេសដែលជាអ្នកកាសែតនោះ ដែលគេមិនទាន់សួរចម្លើយ គេទុកសិនមានតែប៉ុណ្ណឹងទេ ។ រួចជនជាប់ចោទគាត់បានប្រាប់ខ្ញុំ គាត់ថា គាត់អត់ជឿថា មានអ្នកណាហ៊ានប្រឆាំងជាមួយនឹងបញ្ជារបស់ថ្នាក់លើទេ ។ នេះខ្ញុំបាទបានពិភាក្សាអ៊ីចឹង គាត់អត់ទាន់ជឿទេ ។ សូមជម្រាបប៉ុណ្ណឹង សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រមហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

យើងអាចព្យាយាមចង់បានឲ្យច្បាស់ពីចំណុចនេះ មេធាវីបញ្ជាក់ថា លោក នង ចាន់ផល មិនមែនជាមនុស្សដែលអាចនឹងរួចរស់ពីស-២១ ទេ តើមេធាវីអាចប្រាប់យើងដឹងថា តើគាត់ជាមនុស្សម្នាក់ដែលមិនដែលធ្លាប់បានជាប់ឃុំនៅស-២១ ទាល់តែសោះ ឬយ៉ាងម៉េច? ពីព្រោះថា គឺថាលោកបដិសេធទាំងពីរហ្នឹង ប៉ុន្តែ ជនជាប់ចោទនិយាយពីខាងដើមនោះ គាត់ថា គាត់មិនជំទាស់ទៅនឹងខ្លឹមសារនៃសក្ខីកម្មរបស់លោក នង ចាន់ផល ទេ ។ ដូច្នេះ ខ្ញុំដូចជាមិនទាន់ច្បាស់ពីលោកមេធាវី ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកចៅក្រម! ចំពោះលោក នង ចាន់ផល ខ្ញុំជាមេធាវីការពារ នៅតែពុំទាន់យល់ថាតើគាត់បានរស់នៅទួលស្លែងពិតប្រាកដឬអត់? ពីព្រោះសូមលោកចៅក្រមពិចារណា គាត់ថាម្តាយរបស់

គាត់ចូលទៅស-២១ គេទះម្តាយគាត់ គេរុញចាប់សក់ រុញក្បាលម្តាយគាត់ពីមុខពីក្រោយបួនប្រាំសា ថតពីមុខ ថតពីក្រោយគាត់មានការតក់ស្លុត ។ តែក្រោយឆ្នាំ១៩៧៩ គាត់បានវិលត្រឡប់ទៅទួលស្លែង រកមើលរូបថតម្តាយគាត់អត់ឃើញទេ ។ អ៊ីចឹង អ្នកដែលគេចូលទួលស្លែងប៉ុន្មានគេថត ហើយមានរូបថតនៅនុ៎ងទាំងអស់ ចុះហេតុអ្វីក៏ម្តាយគាត់អត់ឃើញមានរូបថត? នេះជាបញ្ហាទីមួយ ។

បញ្ហាទីពីរ ចំនួនឈ្មោះអ្នកស្លាប់នេះ ១២.៣៨០នាក់ សូមលោកចៅក្រមរកចុះ តើមានឈ្មោះម្តាយលោក នង ចាន់ផល ទេ? អត់ឃើញមានទេ ។ អ៊ីចឹងបើវាអត់ឃើញស្លាប់នៅស-២១ តើឲ្យមេធាវីជឿយ៉ាងម៉េច? សូមអរគុណ ខ្ញុំសូមជម្រាបប៉ុណ្ណឹងសិន ។

[១៥:២៨:១១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

តើជនជាប់ចោទអាចប្រាប់អង្គជំនុំជម្រះបានទេ ពេលណា? នៅពេលដែលលោកនិយាយថាលោកមិនជំទាស់ទៅនឹងខ្លឹមសារនៃសក្ខីកម្មរបស់លោក នង ចាន់ផល នោះ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំមិនជំទាស់នឹងខ្លឹមសារនៃសក្ខីកម្មរបស់លោក នង ចាន់ផល ត្រង់ដែលគាត់ពិតជាមនុស្សរងទុក្ខនិរាសប្រាសព្រាត់ទាំងឪពុកទាំងម្តាយ នេះខ្ញុំទទួល អត់ប្រកែកទេ ។ មុនដែលឃើញក្រដាសមួយសន្លឹកនេះ ខ្ញុំនៅតែគិតថាឪពុកលោក នង ចាន់ផល រងទុក្ខវេទនា ហើយស្លាប់នៅមន្ទីរនគរបាលណាមួយផ្សេងទៀត ដល់ឃើញក្រដាសមួយសន្លឹកនេះ ខ្ញុំទទួលស្គាល់ថា ឪពុកលោកនង ចាន់ផល ពិតជារងទុក្ខវេទនាយ៉ាងអាណោចអាធម្ម ហើយស្លាប់នៅទួលស្លែង ដោយសារស្នាដៃស-២១ ពិត ។ ក៏ប៉ុន្តែ ចំពោះម្តាយ ហើយនិងរូបលោក នង ចាន់ផល ផ្ទាល់ តើរងទុក្ខវេទនានៅទីណា? ខ្ញុំអត់ទាន់ច្បាស់ ដូច្នេះបើមានក្រដាសមួយសន្លឹកនេះមកទៀត វាច្បាស់ហើយ ។ ម្តាយមក កូនមកហើយ លោកនង ចាន់ផល ពិតជាមករងទុក្ខវេទនានៅស-២១ ហ្នឹង ឬមានក្រដាសមួយបែបទៀតធុនក្រដាសដែលប្រវត្តិរូបទៅខាងស-២៤ ជាមួយមិត្តម៉េត (ឃឹម ម៉េត) ទទួលទៀតអាហ្នឹងធ្លាក់ទៅស្រែ ដូច្នេះសូមឲ្យមានភស្តុតាងមក វាចេញពីស-២១ ឲ្យតែឃើញភស្តុតាងចេញពីស-២១ ខ្ញុំទទួលភ្លាម ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ។

[១៥:៣០:៣៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដូច្នេះ បើសិនខ្ញុំយល់ត្រឹមត្រូវអ្វីដែលលោកបញ្ជាក់នោះ លោកនិយាយថា វាអាចថាសាក្សី អ្វីដែលសាក្សីនិយាយនោះ គឺមិនទាក់ទងទៅនឹងស-២១ តើរឿងនោះកើតឡើងនៅមន្ទីរសន្តិសុខផ្សេង តើអ៊ីចឹងឬទេ?

**ជនជាប់ចោទ៖**

ត្រូវហើយ។ ឬមួយម្តាយគាត់រងទុក្ខវេទនានៅមន្ទីរនគរបាលណាមួយផ្សេងទៀត ឬមួយក៏ម្តាយគាត់ត្រូវបញ្ជូនទៅស-២៤ ។ ដូច្នេះ សូមឲ្យខាងការិយាល័យសហព្រះរាជអាជ្ញាលោកជួយតាមដានឯកសារហ្នឹង ។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាអន្តរជាតិអញ្ជើញ ។

**លោក វីលៀម ស្មីត៖**

លោកចៅក្រម ខ្ញុំមានមតិសង្ខេបមួយគឺថា គោលជំហររបស់ជនជាប់ចោទ គឺកែប្រែពីភស្តុតាងដែលបង្ហាញ អ៊ីចឹងមុនពេលដែលមានប្រវត្តិរូបបង្ហាញដោយអង្គជំនុំជម្រះ ជនជាប់ចោទបញ្ជាក់ថាឪពុករបស់គាត់ប្រហែលជាមិននៅស-២១ ទេ ។ ប៉ុន្តែនៅពេលដែលបង្ហាញប្រវត្តិរូបទៅ គាត់ទទួលស្គាល់ ។ អ៊ីចឹងហើយមេធាវីបាននិយាយថា ឪពុករបស់សាក្សីហ្នឹងមិនត្រូវបានសម្លាប់ ឬទារុណកម្មនៅស-២១ ទេ ព្រោះមិនមាននៅក្នុងបញ្ជី ។ ប៉ុន្តែ ពេលនោះជនជាប់ចោទបញ្ជាក់ថា ពិតជានៅស-២១ ពីព្រោះថាមានប្រវត្តិរូប ។ អ៊ីចឹងគឺថា ខាងសហព្រះរាជអាជ្ញា គឺថា គឺការឯកភាព ឬមិនឯកភាពលើបញ្ហានេះ គឺជាពិសេសរឿងភស្តុតាង ដើម្បីគឺថាយើងត្រូវបង្ហាញឲ្យហួសពីមតិសង្ស័យនៅក្នុងខណៈនេះ ។ អ៊ីចឹងថាដើម្បីនឹងធ្វើដូច្នោះបាន ល្អបំផុតនោះ គឺថាយើងចាំថាថ្ងៃនេះសាក្សីបានបញ្ជាក់ថាគាត់បានឃើញរូបវីដេអូដែលថតដោយវៀតណាមនោះ ហើយគាត់ទទួលស្គាល់ខ្លួនគាត់ចេញពីវីដេអូនោះ ។ ខ្ញុំស្នើថា លោកចៅក្រម ដូចមានលទ្ធភាពដើម្បីបង្ហាញវីដេអូនេះជូនសាក្សី ដើម្បីឲ្យគាត់បញ្ជាក់ថាតើគាត់បានស-២១ ឬអត់ហ្នឹង? គឺថានេះជាមធ្យោបាយតែមួយគត់ ហើយវាជាធម្យោបាយមួយប្រសិនបើអង្គជំនុំជម្រះអាច

ធ្វើទៅបានថ្ងៃនេះ មុននឹងធ្វើសេចក្ដីសម្រេចទៅលើវីដេអូនេះ យើងសាក្សីគឺថាអាចនឹងឲ្យគាត់កោះមកសាជាថ្មី ដើម្បីឲ្យគាត់បញ្ជាក់ ឲ្យបញ្ជាក់ថា រូបគាត់មែន ឬមិនមែននៅក្នុងវីដេអូ ថាតើគាត់បាននៅ ស-២១ នោះ មែនឬមិនមែន?

[១៥:៣៤:០១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញជនជាប់ចោទ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! គ្រប់ភស្តុតាងទាំងអស់ដែលមានឥទ្ធិពលលើខ្ញុំ គឺភស្តុតាងដែលចេញពីស-២១ ។ ខ្ញុំមិនទទួលស្គាល់ភស្តុតាងណាដែលមិនចេញពីស-២១ ទេ ។ សូមបញ្ជាក់ជូនប៉ុណ្ណេះដោយគោរព ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្ដី ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន។ ចំពោះខ្ញុំជាមេធាវីការពារក្ដី ខ្ញុំសូមជម្រាបជូនលោកព្រះរាជអាជ្ញាអន្តរជាតិថា ខ្ញុំអត់មានជំទាស់ទេ រឿងការទទួលស្គាល់ ឲ្យតែមានភស្តុតាងច្បាស់លាស់ គឺខ្ញុំទទួលស្គាល់ភ្លាម ពីព្រោះក្នុងចំណោម ១២.៣៨០នាក់ ដែលស្លាប់នៅស-២១ កូនក្ដីខ្ញុំទទួលយកទាំងអស់ គាត់អត់ឆ្លើយដាក់កូនចៅគាត់ណាមួយទេ គឺគាត់ទទួលយក ។ អ៊ីចឹងឪពុកម្ដាយលោក នង ចាន់ផល មួយ ខ្ញុំអត់ខ្លាចអីនឹងទទួលទៀតទេ មិនខ្លាចទទួលទេ កូនក្ដីខ្ញុំអត់ខ្លាចទទួលទេ ។

ប៉ុន្តែ គេចង់បានជាក់ស្ដែងអ្វីដែលពិត ដែលវាកើតមានពិតនៅស-២១ ប៉ុនណា សូមឲ្យវាមានប៉ុណ្ណឹង ចៀសវាងការដូចថា វាមានពិតប៉ុនណា ហើយយើងប្រតិដ្ឋថែម អានេះជារឿងមួយដែលមិនអាចទទួលយកបាន ។ អ៊ីចឹងទទួលយកបានតែអ្វីដែលវាជាក់ស្ដែងពិត ហើយជាក់ស្ដែងពិត គឺមានភស្តុតាង ។ ដូចជាលោក នង ចាន់ផល អ៊ីចឹង គាត់ថា “អ្ហឺ! ឪពុកគាត់ គាត់មានភស្តុតាង មានប្រវត្តិរូប” គ្រាន់តែថាមាត់ទទេ ខ្ញុំអត់ទាន់ជឿទេ ។ ដល់តែលោកព្រះរាជអាជ្ញាដាក់ភស្តុតាងចូលនៅក្នុងវីដេអូនេះ ឃើញប្រវត្តិរូប TSL ភ្លាម កូនក្ដីខ្ញុំក៏ជឿ ខ្ញុំក៏ជឿថាពិតជាស្លាប់នៅទួលស្លែងមែន ។ អ៊ីចឹង

លោកបង្ហាញភស្តុតាងមកថា ម្តាយលោក នង ចាន់ផល នេះពិតជាចាប់មកនៅទួលស្លែង បង្ហាញភស្តុតាងមក វាចប់ហើយ អត់មានអីតវ៉ាទៀតទេ ។ សូមអរគុណ ។

[១៥:៣៦:១៨]

**លោក អាឡាំង វែនណឺ៖**

ខ្ញុំសូមរយៈពេលមួយនាទីលោកប្រធាន ។ ខ្ញុំសូមគាំទ្រដោយខ្លីៗ ទៅលើអ្វីដែលលើកឡើងដោយសហព្រះរាជអាជ្ញា ។ ជាបឋមខ្ញុំសូមលើកឡើងថា មេធាវីការពារក្តី នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ នៅពេលដែលមេធាវីការពារក្តីឆ្លើយតបទៅលើបញ្ជីសាក្សី ដែលនិយាយអំពី នង ចាន់ផល នៅពេលនោះ ការលើកឡើងនោះ គឺបានបញ្ជាក់ថា គាត់ថាមិនមានផលប្រយោជន៍ក្នុងការស្តាប់លោក នង ចាន់ផល ហើយជនជាប់ចោទ គាត់បានលើកឡើងថា វាមិនមានភាពអាចផ្តល់ទៅលើយថាភាព និងភាពត្រឹមត្រូវទៅលើចំណុចនេះ ។ ដូច្នេះហើយខ្ញុំសូមលើកឡើងថា ក្នុងនាមជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើអង្គសវនាការនៅពេលណាមួយ អាចបង្ហាញទៅលើរូបភាពនេះ ហើយយើងគួរតែបង្ហាញនៅថ្ងៃនេះ ។ ដូច្នេះហើយ វាជាការឈឺចាប់ណាស់ចំពោះសាក្សីរូបនេះ ដែលយើងត្រូវតែហៅគាត់ម្តងទៀតនោះ ដូច្នេះប្រសិនបើយើងបង្ហាញខ្សែរូបភាពវីដេអូនៅថ្ងៃនេះ គឺជាការល្អ ។ ដូច្នេះហើយ ខ្ញុំគាំទ្រទៅខាងសហព្រះរាជអាជ្ញា ដែលថាយើងគួរតែបញ្ចាំងនូវខ្សែរូបភាពនេះ នៅថ្ងៃនេះ មិនចាំបាច់ឲ្យគាត់មកសាជាថ្មី ហើយយើងដឹងហើយថា មានភាពឈឺចាប់ណាស់ ចំពោះគាត់នៅក្នុងនេះ ។

[១៥:៣៨:០៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៣:១០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គសវនាការបានសម្រេចថា ផ្នែកមួយនៅក្នុងខ្សែរូបភាព ដែលយើងកំពុងតែដេញដោលនេះ នឹងបង្ហាញជូន ហើយនិងសាក្សីនឹងត្រូវសួរឲ្យផ្តល់យោបល់ទៅលើចំណុចហ្នឹង អ៊ីចឹងគឺរូបភាពហ្នឹង គឺរូបភាពនឹង មិនមែនជាការចាក់ប៉ុន្មានសឹកុងនៃឯកសារនោះទេ ។ ដូច្នេះខ្ញុំស្នើសុំខាងសោតទស្សន៍ឲ្យបង្កើតរកផ្នែកហ្នឹង ហើយថាតើក្រឡាបញ្ជី អាចបញ្ជាក់ថា តើវានៅត្រង់ណា

ដែលនៅក្នុងរូបភាពខ្សែវីដេអូនោះ ដើម្បីឲ្យភាគីគាត់បានដឹងទៅលើចំណុចជាក់លាក់នៅក្នុងនោះ ។

គឺនៅត្រង់នាទី៧ និង៨វិនាទី លោក នង ចាន់ផល លោកនឹងឃើញរូបភាពបញ្ចាំងនៅលើផ្ទាំងអេក្រង់របស់លោកនៅពេលបន្តិចទៀតនោះ ។ ហើយខ្ញុំនឹងសួរសំណួរលោកមួយសំណួរទាក់ទងទៅនឹងរូបភាពនោះ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** លោកឃើញរូបភាពនេះច្បាស់ដែរឬទេ?

**ឆ៖** ខ្ញុំបាទឃើញច្បាស់ហើយបាទ ។

**ស៖** តើលោកប្រាប់ខ្ញុំបានដែរឬទេថា តើលោកស្គាល់ក្មេងមួយណាដែរឬទេក្នុងរូបភាពនេះ?

**ឆ៖** បាទ, សូមជម្រាបថា រូបភាពធំជាងគេហ្នឹង ដែលមានខ្លួនទទេ ហើយឈរបែរមុខមកចំមកហ្នឹង គឺរូបភាពខ្ញុំ ហើយរូបភាពខាង បើនៅខាងមុខកញ្ចក់ទូរទស្សន៍មុខខ្ញុំនេះ គឺនៅខាងឆ្វេងគឺជារូបខ្ញុំ នៅខាងស្តាំ គឺជារូបប្អូនប្រុសខ្ញុំ ។ បច្ចុប្បន្នពួកខ្ញុំរស់នៅទាំងពីរនាក់ ។ សូមបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** សូមអរគុណ ។ ថាតើលោកចង់និយាយបន្ថែមអ្វីទៀតដែរឬទេ អំពីរូបភាពនេះ?

**ឆ៖** បាទ, នៅក្នុងរូបនេះ ខ្ញុំចង់និយាយបញ្ជាក់ថា ពេលដែលពួកកងទ័ព គេសួរខ្ញុំហ្នឹង ខ្ញុំអត់ដឹងថាមានកាមេរ៉ាថតអី ដូចអី ឃើញអ៊ីចឹងទេ ។ គ្រាន់តែខ្ញុំដឹងថា គេសួរខ្ញុំពីនេះ ពីនោះ ។ ហេតុអីបានគេយកខ្ញុំមកនេះ អ៊ីចឹង? គេសួរច្រើនសាច្រើនដង ហើយខ្ញុំប្រាប់ថា ខ្ញុំជាកូន ឪពុកខ្ញុំឈ្មោះ តា ចិន ម្តាយឈ្មោះ យ៉ូវ ។ ហើយប្អូនខ្ញុំហ្នឹង វាអត់ដឹងទេ គ្រាន់តែវាតាមតែខ្ញុំទេ គេសួរអី ក៏វាអត់ដឹង ប៉ុន្តែខ្ញុំបានដឹងតែស្គាល់តែឈ្មោះឪពុក តែប៉ុណ្ណឹង ។ សូមជម្រាបបាទ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណច្រើន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** មុននេះបន្តិច ប្រសិនបើខ្ញុំចាំត្រឹមត្រូវនោះ លោកបាននិយាយថា លោកមិនបានចាំថាមានគេថតលោកនោះទេ នៅពេលដែលលោកឃើញការមកដល់នៃទាហានវៀតណាម ។ តើលោកចាំទេថា នៅក្រោយមក លោកបានចូលរួមនៅក្នុងថតខ្សែវីដេអូ?

**ឆ៖** ខ្ញុំអត់យល់សំណួរនេះទេ បើលោកសួរខ្ញុំថា នេះជារូបរបស់ខ្ញុំ ហើយខ្ញុំបានប្រាប់បញ្ជាក់ប្រាប់ទៅលោកថា នេះជារូបភាពខ្ញុំពិតមែន ។ ប៉ុន្តែ ពេលដែលគេកំពុងតែសួរខ្ញុំហ្នឹង ខ្ញុំអត់មានបានចាប់អារម្មណ៍ ឬដឹងថាមានគេថតខ្ញុំទេ ។ សូមបញ្ជាក់តែប៉ុណ្ណឹង ។

**ស៖** យោងតាមលោក នេះគឺជារូបភាពនៅពេលដែលគេសួរសំណួរលោកនៅពេលដែលទាហានវៀតណាមចូលមក មិនមែនជាខ្សែរូបភាពវីដេអូដែលគេថតនៅពេលក្រោយនោះទេ គឺបានន័យថា នៅពេលក្រោយពេលដែលទាហានវៀតណាមចូលមកនោះទៀត?

**ឆ៖** នៅពេលខ្ញុំបញ្ជាក់ថា នៅពេលដែលពួកកងទ័ពទៀត ក៏មានអ្នកផ្សេងសួរដូចេ្នះដែរដូចកាលពីទាហានពីរនាក់មកសួរខ្ញុំមុនដំបូងអ៊ីចឹង ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ត្រឡប់វិលទៅរូបភាពប្រក្រតីឡើងវិញ ។ ជាកិច្ចបន្តនេះ សូមប្រគល់វេទិកានេះ ទៅដល់មេធាវីការពារក្តី ថាតើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះដែរឬទេ?

សូមអញ្ជើញ ។

**សួរដោយលោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

សូមអរគុណលោកចៅក្រម ។ ខ្ញុំមានសំណួរតែមួយចំនួនតូចប៉ុណ្ណោះ គឺចង់សួរទៅកាន់លោក នង ចាន់ផល ។ លោកបាននិយាយថា លោកបានជួប តាគង់ ដែលជាជាងដែក ហើយគាត់នោះបានស្គាល់លោក ហើយគាត់បាននិយាយជាមួយលោកថា លោកនៅទួលស្លែង ។

**ស៖** តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ? តើលោកបានជួបតាគង់នោះនៅពេលណាដែរ?

**ឆ៖** បាទ,នៅពេលដែលខ្ញុំជួបតាគង់នោះ ខ្ញុំជួបក្រោយថ្ងៃបែកហើយ នៅពេលដែលខ្ញុំនៅកុមារកំព្រាកូលាបទីពីរ មជ្ឈមណ្ឌលកុមារកំព្រាកូលាបទីពីរ ។ ពេលដែលខ្ញុំដើរទៅដល់ក្នុងទួលស្លែងហ្នឹងខ្ញុំចូលទៅមើល ជួនកាលខ្ញុំនឹកម្តាយខ្ញុំអ៊ីចឹង ខ្ញុំក៏បានធ្វើដំណើរដើរទៅអ៊ីចឹង ខ្ញុំបានស្គាល់គាត់ ដូចសព្វដងអ៊ីចឹង។ នេះខ្ញុំតែងតែចូលទៅមើល ហើយជួប តាគង់ នៅហ្នឹង ហើយតាគង់ គាត់បានស្គាល់ខ្ញុំមុន ។ គាត់ស្រែកសួរខ្ញុំ ហើយគាត់សួរពីខ្ញុំនៅឯណាឥឡូវនេះ? ខ្ញុំថា ត្រូវគេយកទៅនៅកុមារកំព្រា ហើយគាត់សួរថា ខ្ញុំស្គាល់គាត់ទេ? ខ្ញុំថា ខ្ញុំអត់ស្គាល់ទេ ។ ចុះកាលពីមុន ឯងនៅខាងក្រោយគុកនោះ ឃើញអញកំពុងតែធ្វើជាងនៅក្នុងនោះទេ? ខ្ញុំថា ខ្ញុំមើលទៅឃើញចាស់ៗដែរ ប៉ុន្តែមិនដឹងថា តា ឬក៏មិនតាទេ ។ ខ្ញុំជម្រាបប៉ុណ្ណឹងបាទ ។ ខ្ញុំមើលពីចម្ងាយទៅឃើញចាស់ៗ ធ្វើការ ធ្វើជាងនៅក្នុងមែនប៉ុន្តែខ្ញុំអត់ដឹងថា

គាត់ជាតាគង់ ឬជាក៏អ្នកណាទេ ។ ទើបតែថ្ងៃក្រោយរំដោះជួបគាត់ទេ ។

**ស៖** ក្រៅពី តាគង់ ដែលបានប្រាប់លោកថាលោកបាននៅទួលស្លែងនោះ ថាតើពេលដែលគាត់បានប្រាប់លោកនិងបញ្ជាក់ប្រាប់លោក ថាតើលោករស់នៅទួលស្លែងយ៉ាងម៉េច ហើយលោកស្នាក់នៅទួលស្លែងយ៉ាងម៉េច? ហើយវាកើតឡើងយ៉ាងម៉េច? គាត់មានប្រាប់ដែរឬទេ?

**ឆ៖** បាទ, គាត់និយាយថា គាត់ថា អ្នកដែលនៅក្នុងនេះ គឺមានការជឿចាប់ខ្មោចផ្សារណាស់ ។ ដូច្នេះចៅកុំគិតពីរឿងនេះ ទៅនៅកុមារកំព្រានោះគិតតែពីខំរៀនទៅបានហើយ គាត់និយាយតែប៉ុណ្ណេះ ។ គាត់អត់មាននិយាយថែមទៀត ច្រើនក្រៅពីការឲ្យខ្ញុំទៅរៀន ខិតខំរៀនតែប៉ុណ្ណឹងទេ កាលពីខ្ញុំនៅកុមារកំព្រានោះ ។

**ស៖** សំណួរបន្តទៀត ។ លោកបានលើកឡើងថា តាំងពីឆ្នាំ១៩៧៩ លោកបានត្រឡប់ទៅទួលស្លែងវិញ ថាតើលោកទៅទួលស្លែងនៅថ្ងៃណា? ហើយតើលោកទៅនោះនៅពេលណា? ស្ថានភាពអ្វីដែលបាននាំឲ្យលោកទៅទួលស្លែង?

**ឆ៖** ខ្ញុំនៅចាំបាន ពេលដែលខ្ញុំត្រឡប់ទៅទួលស្លែងហ្នឹងវិញ មានជួនកាលគណ:ប្រតិភូ គេចុះមកទស្សនកិច្ចនៅមជ្ឈមណ្ឌលកុមារកំព្រាកូលាបទីពីរ ។ ហើយភ្ញៀវទាំងនោះ គេចង់ទៅឃើញកន្លែងដែលខ្ញុំជាប់នៅខាងក្រោយនៅទួលស្លែងហ្នឹង ហើយភ្ញៀវគណ:ប្រតិភូហ្នឹង ក៏គេបានសុំអញ្ជើញខ្ញុំទៅជួយបង្ហាញកន្លែងដែលខ្ញុំ នៅរស់កាលពីជំនាន់ខ្មែរក្រហម ជំនាន់នៅក្នុងគុកហ្នឹង ។ ខ្ញុំប្រាប់គេ រៀបរាប់ប្រាប់គេអ៊ីចឹងទៅ ចង្អុលបង្ហាញគេនូវអ្វីដែលខ្ញុំនៅចាំ ។ តាំងពីហ្នឹងមក ខ្ញុំបាទជម្រាបបានប៉ុណ្ណឹង ។

**ស៖** នៅថ្ងៃណាដែលអ្នកតំណាងមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា បានទៅលេងលោកនៅខេត្តកំពង់ស្ពឺ?

**ឆ៖** មជ្ឈមណ្ឌលឯកសារកម្ពុជា គាត់ដឹងដំណឹងថា ខ្ញុំពិតជាក្មេងសល់ពីការស្លាប់ក្នុងចំណោមក្មេងបួននាក់ហ្នឹង នៅក្នុងផុតពីការសម្លាប់នៅទួលស្លែងហ្នឹង គាត់ដឹងថា ខ្ញុំនៅធ្វើការនៅខេត្តកំពង់ស្ពឺដល់ខ្ញុំធ្វើជាអ្នកបើក*ប៊ុលដូហ្ស៊រ* ឈូសផ្លូវគេហ្នឹង ហើយគាត់ក៏បានតាមរកខ្ញុំ តាមសួរ សាកសួរខ្ញុំពីព័ត៌មានពិត អ៊ីចេះមួយអ៊ីចេះពី ។ ប៉ុន្តែ ខ្ញុំបាទអត់បានចាំថ្ងៃខែទេ ដោយសារការងារវាដើររកអ្នកជំនួសអត់បាន អ្នកបើក*ប៊ុលដូហ្ស៊រ*ហ្នឹងវាក្រនៅស្រុកខ្មែរ មានអ្នកចេះតែបើកឡាន ដល់បើកអា*ប៊ុលដូហ្ស៊រ*ហ្នឹងអត់សូវមានអ្នកចេះ ។ អ៊ីចឹងការងារយើងខ្ញុំអត់សូវបានទំនេរ អត់បានគិតពីពេលវេលា គ្រាន់តែគាត់ទៅសួរហើយ ខ្ញុំក៏បានឡើងធ្វើការទៅវិញទៅ ។

**ស៖** ខ្ញុំមិនសួរថ្ងៃជាក់លាក់នោះទេ ប៉ុន្តែលោកអាចផ្តល់ជាគំនិតដែរឬទេ ថានៅពេលណាដែលលោកជួបអ្នកដែលមកពី *ឌីស៊ីខេម* នោះ ឬមជ្ឈមណ្ឌលឯកសារកម្ពុជានោះ សូមឲ្យធ្វើការស្មានប្រហាក់ប្រហែលទៅមើល?

**ឆ៖** បាទ,ខ្ញុំមិនអាចចាំបាន ប៉ុន្តែ-- សុំសំណួរនេះម្តងទៀត ដូចខ្ញុំស្មានតែគាត់មិនមែនសួរខ្ញុំអំមិញ ។ សុំសួរម្តងទៀត ។

**ស៖** លោកខ្ញុំចង់ដឹង ឲ្យលោកធ្វើការស្មាន ដោយមិនចាំបាច់បញ្ជាក់ថ្ងៃឲ្យបានច្បាស់លាស់ថា ស្មានទៅមើលនៅពេលណា ដែលលោកបានជួបអ្នកតំណាងមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា? សូមឲ្យលោកធ្វើការស្មានទៅមើល ថាតើឆ្នាំនេះ ឆ្នាំទៅមិញ ឬក៏ប៉ុន្មានឆ្នាំទៅមុន? នៅក្នុងឆ្នាំ២០០៥ ឬក៏ ២០០៦ ឬក៏មុនហ្នឹងសូមឲ្យលោកធ្វើការស្មាន ។

**ឆ៖** បើខ្ញុំស្មានថា ជួបជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជានោះ វាហាក់បីដូចជាយឺតពេល-- ដូចជាពេលឆាប់ យឺណាស់ ពេលតិចណាស់ ដោយខ្ញុំនឹកឃើញថា ពាក្យបណ្តឹងដើមបណ្តឹងរដ្ឋប្បវេណីហ្នឹងគេបានត្រូវបានគេបិទហើយ ។ ខ្ញុំមកហួសថ្ងៃគេបិទបានបួនថ្ងៃហើយ ។ ខ្ញុំក៏បានដាក់ពាក្យចូលទៅ បានគេណែនាំនៅក្នុងទទួលពាក្យជំនុំជម្រះហ្នឹង ក្នុងតុលាវិសាមញ្ញហ្នឹង ខ្ញុំដាក់ពាក្យទៅគេថា ហួសពេលហើយ។ អ៊ីចឹងបើដាក់ហ្នឹង អាចបើសិនណាជាមេធាវីគេព្រម បើអាចតុលាការគេព្រមៗ បើគេមិនព្រម យើងសុំដាក់ជាពាក្យដើមបណ្តឹង ។ ដល់ពេលនោះខ្ញុំទៅរកឯកសារខ្លះដើម្បីបញ្ជាក់ថា ខ្ញុំពិតជាក្មេងសល់ពីទួលស្លែង ។ ខ្ញុំទៅសារមន្ទីរទួលស្លែងហើយ សួររកថា មានរូបថតអីណាសល់ពីការ-- មាននៅទួលស្លែងទៅក្រែងមានឪពុកខ្ញុំខ្លះ អីខ្លះអ៊ីចឹងទៅ ។ ខ្ញុំទៅរកអត់ឃើញទៅបានអ្នកធ្វើការនៅទួលស្លែងថា បើអាចចង់ដឹងរូបភាពខ្លះៗមែន អ្នកឯងត្រូវទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សូមជម្រាប ។

[១៥:៥៨:២៣]

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

ខ្ញុំអត់មានសំណួរសួរទៅកាន់សាក្សីនោះទេ ។ ប៉ុន្តែ លោកប្រធានខ្ញុំសូមធ្វើការឆ្លើយតបទៅនឹងសេចក្តីសង្កេតរបស់ អាឡាំង វែនណឺ អម្បាញ់មិញនេះ ។ គឺហាក់ដូចជាគាត់បានលើកឡើងថា ជនជាប់ចោទនេះ គឺហាក់ដូចជាធ្វើការមើលនឹងកែប្រែនូវអ្វីដែលគាត់លើកឡើងនោះ ។ ហើយគឺគាត់មិនដែលធ្វើការតវ៉ាទៅលើការឃុំខ្លួនកូនក្មេងនៅស-២១ នោះទេ។ ដូច្នេះហើយ យើងខ្ញុំចង់បញ្ជាប់ទៅលើសវនាការនៅថ្ងៃនេះដោយសុំការអនុញ្ញាតពីលោកប្រធាននិងអង្គសវនាការ ។ ខ្ញុំស្នើសុំឲ្យលោក កាំង ហ្គេកអ៊ាវ

ជម្រាបយើងខ្ញុំថាគាត់មិនបាននិយាយទៅលើចំណុចទៅលើចំណុចទាំងអស់នោះទេ ។ ហើយគាត់នៅតែឆ្លល់ទៅលើអង្គហេតុទាំងអស់នេះ ទៅលើអ្វីដែលសាក្សីនេះត្រូវបានគេឃុំនៅស-២១ ។

**ប្រធានអង្គជំនុំ៖**

លោក កាំង ហ្គេកអ៊ាវ មានអ្វីចង់កត់សម្គាល់បន្ថែមទេ? ពាក្យបន្ថែមមានន័យថា អត់ដដែលទេ មានន័យថាអ្វីដែលលោកបាននិយាយរួចហើយចៀសវាងការនិយាយដដែល ។ បើសិនអត់មានអីបន្ថែមទេគឺអត់ទេ តែបើបន្ថែមបានន័យថា គឺបន្ថែមទៅលើអ្វីដែលលោកបានធ្វើការកត់សម្គាល់រួចហើយ ។ បើមានសូមអញ្ជើញ ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! បើសិនជានិយាយថា ចំពោះកុមារចូលទៅអត់ដែលសល់ទេ មនុស្សចាស់ក៏ដោយក៏ផុតអស់រលីងនៅថ្ងៃ២ ឬថ្ងៃ៣ មករា នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។ ដូច្នេះ ខ្ញុំអត់ដែលបដិសេធថាមិនបានឃុំឃាំងកុមារទេ គឺពិតជាបានឃុំឃាំង។ ក៏ប៉ុន្តែ កុមារអត់រស់ទេ អត់សល់ទេ មនុស្សធំក៏ដោយក៏មិនសល់ដែរ គ្មានសល់ទេ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង អត់សល់ទេ។ អ៊ីចឹងហើយបាន លោក ចាន់ផល មកហ្នឹង ខ្ញុំស្តាប់ ខ្ញុំទទួលស្គាល់ទុក្ខវេទនារបស់គេ ដល់ឃើញឯកសារមួយសន្លឹកនេះ ខ្ញុំថា អូ! ឪពុកគេទៅនុ៎ងមែន ។ ឥឡូវនៅតែម្តាយគេទេ ខ្ញុំអត់ទាន់យល់ ។ នេះសូមជម្រាបប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដំណើរការសវនាការស្តាប់សក្ខីកម្មរបស់សាក្សី នង ចាន់ផល ដែលជាអ្នករស់រានមានជីវិតម្នាក់នៅមន្ទីរស-២១ ពិតមែនតែមានការជជែកពិភាក្សាគ្នា មានការចម្រូងចម្រាសខ្លះនៅក្នុងការអទិភាពនៃ នង ចាន់ផល នៅក្នុងមន្ទីរស-២១ ក្នុងអំឡុងពេលចុងឆ្នាំ១៩៧៨ នោះមែន ក៏ប៉ុន្តែការដេញដោលនោះគឺសមល្មមដែលឲ្យអង្គជំនុំជម្រះមានមូលដ្ឋានក្នុងការគិតគូរពិចារណាអំពីបញ្ហានេះហើយ ។

[១៦:០១:៤០]

ដូច្នេះ អង្គជំនុំជម្រះប្រកាសថា សវនាការសម្រាប់ថ្ងៃនេះ គឺផ្អាកត្រឹមនេះសិន ហើយអង្គសវនាការលើកទៅបន្តធ្វើសវនាការនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៩ ចាប់ពីវេលាម៉ោងប្រាំបួនព្រឹកទៅ ដោយសវនាការនោះស្តាប់សក្ខីកម្មរបស់សាក្សី អ្នកដែលរស់រានមានជីវិតម្នាក់មួយរូបទៀតពីមន្ទីរសន្តិសុខ គឺ E2/61 ។ ដោយឡែក គឺអ្នករស់រានមានជីវិតម្នាក់ទៀតដែលបានបម្រុងទុក គឺ E2/80 នោះគឺអង្គជំនុំជម្រះនឹងកំណត់ធ្វើសវនាការស្តាប់សក្ខីកម្មរបស់គាត់ តាមកាលដែលបានគ្រោងទុក កាលបរិច្ឆេទដែល

បានគ្រោងទុក គឺនៅថ្ងៃទី៨ ខែ កក្កដា ឆ្នាំ២០០៩ ។

ហើយមន្ត្រីតុលាការសម្របសម្រួលដល់លោក នង ចាន់ផល ដើម្បីជូនជាមួយនឹងខាងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ដើម្បីគាត់សម្របសម្រួលជូនគាត់ត្រឡប់ទៅផ្ទះវិញ ។ ហើយអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់ទីនេះនៅព្រឹក ថ្ងៃច័ន្ទឲ្យបានមុនម៉ោង ប្រាំបួន ៕

*[សវនាការផ្អាកនៅម៉ោង ១៦:០៣នាទី]*